ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធីសិក្សាស្តីពី

# កម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

## សៀវភៅសំរាប់សិក្ខាកាម

## សប្តាហ៍ទី ២

## ខែ មីនា ២០០៧

សហការឧបត្ថម្ភដោយ:

CDC
CENTERS FOR DISEASE
CONTROL AND PREVENTION

unicef

បកប្រែក្រៅផ្លូវការជាភាសាខ្មែរពីភាសាអង់គ្លេស
សូមមេត្តាអធ្យាស្រ័យចំពោះកំហុសឆ្គងនៃអក្ខរាវិរុទ្ធទាំងឡាយ

# មាតិកា

**អារម្ភកថា**.......... ៣
**សេចក្តីថ្លែងអំណរគុណ**.......... ៤
**សេចក្តីផ្តើមនៃកម្មវិធីសិក្សា**.......... ៥
**បញ្ជីរាយនាមអក្សរកាត់**.......... ៦
**ម៉ូឌុលទី៧:** ជំនាញផ្តល់ប្រឹក្សាជាមូលដ្ឋាន.......... ៩
**ម៉ូឌុលទី៨:** ការផ្តល់ប្រឹក្សានៅក្នុងបរិបទនៃមេរោគអេដស៍-ជំងឺអេដស៍.......... ២៥
**ម៉ូឌុលទី៩:** ក្រមសីលធម៌.......... ៣៧
**ម៉ូឌុលទី១០:** ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម.......... ៤៧
**ម៉ូឌុលទី១១:** ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម.......... ៦៥
**ម៉ូឌុលទី១២:** ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូននិងការគាំទ្រ.......... ៨៣
**ចម្លើយ:** ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន និងការគាំទ្រ.......... ៩៥
**បញ្ជីរាយឯកសារយោង**.......... ៩៩

# អារម្ភកថា

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាគឺជាប្រទេសដែលកំពុងតែប្រឈមនឹងការរីករាលដាលនៃមេរោគអេដស៍-ជំងឺអេដស៍ដ៏ខ្លាំងជាងគេនៅក្នុងតំបន់អាស៊ី ។ ខណៈដែលប្រេវ៉ាឡង់នៃអ្នកឆ្លងមេរោគអេដស៍នៅកម្ពុជាបានធ្លាក់ចុះក្នុងចំណោមក្រុមប្រឈមខ្ពស់ គេបានសង្កេតឃើញថាប្រេវ៉ាឡង់នៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានមកទទួលសេវាថែទាំផ្ទៃពោះហាក់ដូចជាមិនមានការប្រែប្រួលឡើយ (២.២% នៅឆ្នាំ២០០៣) ។ កំណើនអត្រានៃអ្នកឆ្លងមេរោគអេដស៍ថ្មី បានកើតឡើងតាមរយៈការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ។

ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនគឺជាបញ្ហាចំពោះមុខមួយដែលរាជរដ្ឋាភិបាល ជាពិសេសក្រសួងសុខាភិបាលត្រូវដោះស្រាយជាបន្ទាន់ ដើម្បីជួយទប់ស្កាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលចេះតែមានកំណើនកើនឡើងជាលំដាប់ ។ ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយពីចំណេះដឹងស្តីអំពីមេរោគអេដស៍-ជំងឺអេដស៍ ជាពិសេសការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដល់មន្ត្រីព្រមទាំងបុគ្គលិកសុខាភិបាលនានា ក្រសួងសុខាភិបាលបានសម្រេចអនុញ្ញាតឱ្យមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក រៀបរៀងជាសៀវភៅសម្រាប់បណ្តុះបណ្តាលនេះឡើង ។

សៀវភៅបណ្តុះបណ្តាលស្តីអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននេះគឺជាមគ្គុទេសក៍មួយដ៏សំខាន់ និងជាជំនួយដល់មន្ត្រី-បុគ្គលិកទាំងឡាយក្នុងការអនុវត្តន៍ផ្តល់សេវាថែទាំ ព្យាបាលនិងគាំទ្រដ៏មានប្រសិទ្ធិភាពខ្ពស់ដល់ស្ត្រីមានផ្ទៃពោះទាំងឡាយ ជាពិសេសស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ព្រមទាំងកូននិងគ្រួសាររបស់គាត់ ។

ភ្នំពេញ,ថ្ងៃទី ៦ ខែមេសា ឆ្នាំ២០០៧

ឯ.ឧ. សាស្ត្រាចារ្យ **អេង ហួត**

រដ្ឋលេខាធិការក្រសួងសុខាភិបាល

# សេចក្តីថ្លែងអំណរគុណ

សៀវភៅសម្រាប់បណ្តុះបណ្តាលស្តីអំពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលបានរៀបរៀងកែសម្រួលជាថ្មី ត្រូវបានបញ្ចប់ជាស្ថាពរដោយមានការចូលរួមពីគ្រប់ដៃគូរួមការងារជាច្រើនដែលបានផ្តល់ជាមតិយោបល់ដ៏មានសារៈសំខាន់ ។

ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់សមាជិក សមាជិកានៃក្រុមការងារបច្ចេកទេសនៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមផ្តល់ជាជំនួយបច្ចេកទេសក្នុងការរៀបចំសៀវភៅបណ្តុះបណ្តាលនេះឡើង ។

ខ្ញុំសូមថ្លែងអំណរគុណជាពន្លឺកដល់អង្គការសុខភាពពិភពលោក មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ និង មូលនិធិសកលប្រយុទ្ធនឹងជំងឺអេដស៍ របេងនិង គ្រុនចាញ់ ដែលបានឧបត្ថម្ភគាំទ្រជាថវិកាសម្រាប់រៀបចំសៀវភៅបណ្តុះបណ្តាលស្តីអំពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលជាមគ្គុទេសក៏សម្រាប់មន្ត្រី-បុគ្គលិកនៅតាមមន្ទីរពេទ្យ និងមណ្ឌលសុខភាពនានា ក្នុងការអនុវត្តន៏ផ្តល់សេវាថែទាំបន្តមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃការទទួលបានជាសកលនៃអ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍ក្នុងការបង្ការថែទាំ ព្យាបាល និងការគាំទ្រ ។

ខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់មន្ត្រី-បុគ្គលិកនៃការិយាល័យកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនដែលបានចំណាយអស់កម្លាំងកាយចិត្ត និងពេលវេលាក្នុងការពិនិត្យកែតម្រូវអត្ថន័យ និងបកប្រែឯកសារសម្រាប់ការបណ្តុះបណ្តាលនេះ ។

សមិទ្ធិផលដ៏ធំធេងនេះគឺផ្តើមចេញពីការគាំទ្រយ៉ាងពេញទំហឹងរបស់ក្រសួងសុខាភិបាល ។ ជាចុងបញ្ចប់ ខ្ញុំសូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងសុខាភិបាល ដែលជានិច្ចកាលតែងតែគាំទ្រដល់កិច្ចគាំពារសុខភាពមាតានិងទារក ជាពិសេសកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូនឱ្យមានដំណើរការរលូនទៅមុខជានិរន្តរ៍ ។

ភ្នំពេញ,ថ្ងៃទី៦ ខែមេសា ឆ្នាំ ២០០៧

សាស្ត្រាចារ្យ **គុំ ភាណាល់**

ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

# សេចក្តីផ្តើមនៃកម្មវិធីសិក្សា

## របៀបប្រើប្រាស់សៀវភៅ

សៀវភៅសម្រាប់សិក្ខាកាមនេះ គឺជាមគ្គុទេសក៏ដ៏សំខាន់របស់អ្នកនៅក្នុងការសិក្សានេះ។ អ្នកត្រូវរក្សាវាជាប់នឹងខ្លួនអ្នកគ្រប់ពេលវេលា។ នៅក្នុងទំព័របន្ទាប់ទៅនេះ អ្នកនឹងឃើញមានវត្ថុបំណងនៃការបណ្តុះបណ្តាល សកម្មភាពនៃការបណ្តុះបណ្តាល ស្លាយសម្រាប់បញ្ចាំងនិងចំណុចសំខាន់ៗនៃម៉ូឌុលនីមួយៗ។ អ្នកមិនចាំបាច់ធ្វើការកត់សម្គាល់ជាលំអិត នៅក្នុងពេលសិក្សាទេ។ តែទោះបីជាយ៉ាងណាក្តី អ្នកអាចឃើញមានចំណុចគួរឱ្យចាប់អារម្មណ៏ខ្លះដែលអ្នកត្រូវការកត់ត្រាទុក ដូចជាឧទាហរណ៏ដែលបានមកពីការពិភាក្សា។ អ្នកនឹងឃើញមានសេចក្តីអធិប្បាយខ្លីៗនៃសកម្មភាពសិក្សា។ គ្រូសម្របសម្រួលនឹងពន្យល់អ្នកឱ្យកាន់តែលំអិតពីសកម្មភាពនីមួយៗ។

សៀវភៅនេះក៏មានផ្ទុកនូវទម្រង់បែបបទ ករណីសិក្សា និងបញ្ជីផ្ទៀងផ្ទាត់សម្រាប់ធ្វើលំហាត់ ព្រមទាំងព័តិមានជាមូលដ្ឋានសម្រាប់ម៉ូឌុលខ្លះ។ ចម្លើយនៃសំណួរនីមួយៗមានភ្ជាប់នៅផ្នែកខាងក្រោយនៃសៀវភៅនីមួយៗ។

សូមរក្សាសៀវភៅនេះទុកនៅក្រោយពេលបញ្ចប់វគ្គសិក្សា និងសូមប្រើប្រាស់វាជាឯកសារយោងសម្រាប់ការអនុវត្តន៏របស់អ្នក។

# បញ្ជីរាយពាក្យសរសេរជាអក្សរកាត់

| | |
|---|---|
| 3TC | ឡាមីវ៉ុយឌីន (Lamivudine) |
| AIDS | ចង្កោមរោគសញ្ញាដែលធ្វើឱ្យប្រព័ន្ធសរីរាង្គកាយចុះខ្សោយ (Acquired Immune Deficiency Syndrome) |
| ANC | ការថែទាំផ្ទៃពោះមុនពេលសម្រាល (Antenatal Care) |
| ART | ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ (Antiretroviral Therapy) |
| ARV | ឱសថប្រឆាំងមេរោគអេដស៍ (Antiretroviral “drug”) |
| AZT | ហ្ស៊ីដូវ៉ុយឌីន (Zidovudine) |
| BCC | ការប្រាស្រ័យទាក់ទងដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបថ (Behaviour Change Communication) |
| CBO | អង្គការដែលធ្វើការនៅតាមសហគមន៍ (Community-based Organization) |
| CoC | ការថែទាំព្យាបាលបន្ត (Continuum of Care) |
| CoCCC | គណៈកម្មការសម្របសម្រួលការថែទាំព្យាបាលបន្ត (Continuum of Care Coordination Committee) |
| CPA | កញ្ចប់សកម្មភាពបង្គ្រប់ (Complementary Package of Activities) |
| CPN+ | បណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅប្រទេសកម្ពុជា (Cambodian Network of PLHA) |
| CSW | ស្ត្រីរកស៊ីផ្លូវភេទ (Commercial Sex Worker) |
| FBO | អង្គការសាសនា (Faith-based Organization) |
| Hb | អេម៉ូក្លូប៊ីន (Haemoglobin) |
| HBC | ការថែទាំនៅតាមផ្ទះ (Home-based Care) |
| HC | មណ្ឌលសុខភាព (Health Center) |
| HCBC | ការថែទាំនៅតាមសហគមន៍និងនៅតាមផ្ទះ (Home-and Community-based Care) |
| HCW(s) | បុគ្គលិកសុខាភិបាល (Health Care Worker”s”) |
| HFBC | ការថែទាំនៅតាមគ្រឹះស្ថានសុខាភិបាល (Health Facility-based Care) |
| HIV | មេរោគអេដស៍ (Human Immunodeficiency Virus) |
| HIV+ | មានផ្ទុកមេរោគអេដស៍ (HIV infected or HIV positive) |
| HIV- | គ្មានផ្ទុកមេរោគអេដស៍ (HIV negative) |
| HSS | ការធ្វើអង្កេតស្រាវជ្រាវប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ (HIV Sentinel Survey “Cambodia”) |
| NMCHC | មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក (National Maternal and Child Health Center) |
| NVP | ណេវីរ៉ាពីន (Nevirapine) |
| IDU | អ្នកចាក់គ្រឿងញៀន (Injecting Drug User) |

| | |
|---|---|
| IEC | ព័ត៌មាន អប់រំ និង ទំនាក់ទំនង (Information Education Communication) |
| IPD | អគារសម្រាប់អ្នកជំងឺសម្រាកព្យាបាល (Inpatient Department) |
| M&E | ការតាមដាននិងវាយតម្លៃ (Monitoring and Evaluation) |
| MMM | មណ្ឌលមិត្តជួយមិត្ត (Mondul Mith Chuoy Mith “Friends Help Friends Centre”) |
| mmm | មណ្ឌលមិត្តជួយមិត្តសម្រាប់កុមារ (Little Mondul Mith Chouy Mith “for children”) |
| MoH | ក្រសួងសុខាភិបាល (Ministry of Health) |
| MPA | កញ្ចប់សកម្មភាពអប្បបរិមា (Minimum Package of Activities) |
| MSM | បុរសដែលរួមភេទជាមួយបុរស (Men who have sex with men) |
| MTCT | ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (Mother-to-Child transmission of HIV infection) |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ (National Center for HIV/AIDS, Dermatology an STD) |
| OD | ស្រុកប្រតិបត្តិ (សម្រាប់ការគ្រប់គ្រងសុខាភិបាលដែលអាចមាន២ ឬ ច្រើនស្រុករដ្ឋបាល) (Operational District) |
| OI | ជំងឺឱកាសនិយម (Oppointunistic Infection) |
| OPD | អគារពិនិត្យជំងឺក្រៅ (Outpatient Department) |
| PCP | ជំងឺហើមសួតដែលបង្កដោយមេរោគ (*Pneumocystis carinii* Pneumonia) (renamed Pneumocystic jirovecii) |
| PHD | មន្ទីរសុខាភិបាលខេត្ត (Provincial Health Departement) |
| PLHA | អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ (Person or people Living with HIV/AIDS) |
| PLHA-SG | ក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ (People Living wth HIV/AIDS Support Group) |
| PMTCT | ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (Prevention of Mother-to-Child Transmission of HIV infection) |
| RH | មន្ទីរពេទ្យបង្អែក (Referral Hospital) |
| RTI | ការបង្ករោគឆ្លងនៅផ្លូវបន្តពូជ (Reproductive Tract Infection) |
| STD | ជំងឺកាមរោគ (Sexually Transmitted Disease) |
| STI | ជំងឺកាមរោគ (Sexually Transmitted Infaction) |
| TB | ជំងឺរបេង (Tuberculosis) |
| TB/HIV | ជំងឺរបេង/អេដស៍ (Dual or co-infection with both TB and HIV) |
| TWG | ក្រុមការងារបច្ចេកទេស (Technical Working Group) |
| UNICEF | មូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីកុមារ (United Nations Children’s Fund) |
| USAID | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (United States Agency for International Development) |
| VCCT | ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ (Voluntary Confidential Counselling and Testing) |
| WHO | អង្គការសុខភាពពិភពលោក (World Health Organization) |

# ម៉ូឌុលទី៧

# ជំនាញផ្តល់ប្រឹក្សាជាមូលដ្ឋាន

## វត្ថុបំណង

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. ឱ្យនិយមន័យនៃការផ្តល់ប្រឹក្សានិងកំណត់បានអំពីគោលបំណងនៃការផ្តល់ប្រឹក្សា

២. រៀបរាប់សមាសភាគនៃការផ្តល់ប្រឹក្សា

៣. អធិប្បាយនិងបង្ហាញអំពីជំនាញនៃការផ្តល់ប្រឹក្សា

៤. ពន្យល់អំពីដំណាក់កាលគន្លឹះនៃដំណើរការផ្តល់ប្រឹក្សា

៥. សង្ខេបអំពីជំនាញនិងគុណភាពនៃអ្នកផ្តល់ប្រឹក្សាដែលត្រូវការចាំបាច់

៦. កំណត់បានអំពីចំណុចខ្វះខាតដែលតែងតែកើតមានឡើងនៅពេលផ្តល់ប្រឹក្សា



*រយៈពេល:* ***៣ម៉ោង***

## សកម្មភាពទី១: បំផុសគំនិត: តើការផ្តល់ប្រឹក្សាគឺជាអ្វី?

» នៅក្នុងលំហាត់នេះគ្រូនឹងឱ្យអ្នកគិតអំពីៈ

១. តើអ្វីទៅដែលហៅថាការផ្តល់ប្រឹក្សា?
២. តើគេផ្តល់ប្រឹក្សាដើម្បីអ្វី?
៣. តើការផ្តល់ប្រឹក្សាមានគោលបំណងយ៉ាងដូចម្តេច?

### តើការផ្តល់ប្រឹក្សាគឺជាអ្វី?

គឺជាការសន្ទនាជាសម្ងាត់រវាងមនុស្សពីរនាក់ ដែលក្នុងនោះអ្នកផ្តល់ប្រឹក្សាដែលបានទទួលការបណ្តុះបណ្តាល អាចជួយអតិថិជនឱ្យៈ

- ◆ ទំលាយចេញនូវបញ្ហាផ្ទាល់ខ្លួន
- ◆ ធ្វើការសំរេចចិត្ត
- ◆ អនុវត្តគំរោងការរបស់ពួកគេ

នៅខណៈពេលផ្តល់ប្រឹក្សា អ្នកផ្តល់ប្រឹក្សាត្រូវគោរព :

- ◆ តម្លៃរបស់អតិថិជន
- ◆ ធនធានរបស់អតិថិជន
- ◆ សមត្ថភាពផ្ទាល់ខ្លួនដើម្បីធ្វើការសំរេចចិត្តដោយខ្លួនឯងរបស់អតិថិជន

5

### តើគេធ្វើការផ្តល់ប្រឹក្សាដើម្បីអ្វី?

ការផ្តល់ប្រឹក្សាអាចសមស្របនៅពេលដែលបុគ្គលម្នាក់ត្រូវការអ្នកជំនាញឱ្យជួយដើម្បីៈ

- ◆ ស្វែងយល់ពីអារម្មណ៍ខ្លួនឯង
- ◆ ស្វែងយល់ពីវិបត្តិផ្ទៃក្នុងដែលអាចកើតមានឡើង ( ឧៈ ចិត្តខ្ញុំប្រាប់ថាចង់រួមភេទជាមួយបុរសនេះ ។ តែបេះដូងខ្ញុំប្រាប់ថា វាជាការមិនល្អឡើយព្រោះបុរសនោះមានប្រពន្ធហើយ )
- ◆ ដោះស្រាយសំរបខ្លួនជាមួយនឹងវិបត្តិ
- ◆ ធ្វើឱ្យទំនាក់ទំនងជាមួយអ្នកដទៃកាន់តែប្រសើរឡើង
- ◆ ធ្វើការសំរេចចិត្ត

6

### គោលបំណងនៃការផ្តល់ប្រឹក្សា

អតិថិជន និង អ្នកផ្តល់ប្រឹក្សាធ្វើការរួមគ្នាដើម្បីៈ

- ◆ កំណត់រកបញ្ហា ឬ ចម្ងល់ទាំងឡាយរបស់អតិថិជន
- ◆ ផ្លាស់ប្តូរព័ត៌មានដែលជាប់ទាក់ទងឱ្យបានច្បាស់លាស់
- ◆ កំណត់ និង រាវរកជំរើស ឬដំណោះស្រាយដែលសមរម្យ
- ◆ ឱ្យអតិថិជនអាចឈានទៅដល់ការសំរេចចិត្ត
- ◆ រៀបចំគំរោងសំរាប់ពេលអនាគត

7

## តួនាទីរបស់អ្នកផ្តល់ប្រឹក្សា

តួនាទីរបស់អ្នកផ្តល់ប្រឹក្សាគឺ :

- ✓ ផ្តល់ព័ត៌មាន
- ✗ មិនមែនទូន្មានទេ
- ✓ បង្ហាញទិសដៅ
- ✗ មិនមែនប្រាប់អតិថិជនថាពួកគេត្រូវធ្វើអ្វីនោះទេ
- ✓ គាំទ្រអតិថិជនឱ្យធ្វើការសំរេចចិត្តដោយខ្លួនឯង
- ✗ មិនមែនបញ្ចុះបញ្ចូលអតិថិជនឱ្យធ្វើអ្វីតាមតែចិត្តអ្នកផ្តល់ប្រឹក្សានោះទេ

8

## អ្នកផ្តល់ប្រឹក្សាដែលល្អ

អ្នកផ្តល់ប្រឹក្សាដែលល្អ គឺតំរូវឱ្យៈ

- មានចំណេះដឹង
- មានជំនាញខាងផ្តល់ប្រឹក្សា
- ទទួលស្គាល់និងគោរពដល់អ្នកដទៃ
- មានជំនឿថាអ្នកដទៃក៏អាចធ្វើការសំរេចចិត្តដែលល្អសំរាប់ខ្លួនគេដែរ
- មានចិត្តចង់ជួយដល់អ្នកដទៃដោយស្មោះ

9

## ជំនឿនិងតម្លៃរបស់បុគ្គល

- ជំនឿនិងតម្លៃរបស់បុគ្គលម្នាក់ៗកើតចេញពីជីវប្រវត្តិ វប្បធម៌ សាសនា ការអប់រំ បទពិសោធន៍ និងរបៀបគិតរបស់បុគ្គលម្នាក់ៗ ។
- ជំនឿនិងតម្លៃរបស់មនុស្សម្នាក់ៗមានលក្ខណៈខុសៗគ្នា ជាហេតុដែលនាំឱ្យមានអាកប្បកិរិយា ទស្សនៈ និងការគិត និងឥរិយាបថរបស់មនុស្សម្នាក់ៗ ចំពោះអ្នកដទៃមានការខុសៗគ្នាដែរ ។

10

## ការស្គាល់ពីខ្លួនឯង

អ្នកផ្តល់ប្រឹក្សាត្រូវតែៈ

- យល់ដឹងពីអារម្មណ៍ និងគំនិតរបស់ខ្លួន នៅពេលកំពុងនិយាយជាមួយអតិថិជន
- មិនត្រូវឱ្យអារម្មណ៍ និងគំនិតផ្ទាល់ខ្លួនចូលមកជ្រៀតជ្រែកក្នុងការងាររបស់ខ្លួនឡើយ

អ្នកផ្តល់ប្រឹក្សាគួរតែ :

- ដឹងឱ្យបានទូលំទូលាយពីទស្សនៈរបស់ខ្លួន
- មានឆន្ទៈយល់ដឹងពីអ្នកដទៃនិងបញ្ហារបស់គាត់
- ទុកឱ្យអតិថិជនគិតដោយខ្លួនឯង ប្រសើរជាងគិតជំនួសគាត់

11

## សកម្មភាពទី ២ : លំហាត់ដើម្បីឱ្យស្គាល់ពីខ្លួនឯង

- » គោលបំណងនៃលំហាត់នេះគឺដើម្បីបង្កើនការយល់ដឹងពីខ្លួនឯង ដើម្បីពិនិត្យអំពីតម្លៃនិងជំនឿបុគ្គល ព្រមទាំងដើម្បីឱ្យសិក្ខាកាមបានយល់ថាតើឥរិយាបថទាំងនោះប៉ះពាល់ដល់ការផ្តល់ប្រឹក្សាយ៉ាងណាខ្លះ?
- » គ្រូនឹងចែកក្រដាសថតចម្លងសំណួរស្តីអំពីឥរិយាបថទៅសិក្ខាកាម ។ អ្នកមិនចាំបាច់សរសេរឈ្មោះរបស់អ្នកនៅលើក្រដាសទេ
- » សូមអានសំណួរដែលរៀបរាប់អំពីឥរិយាបថរបស់មនុស្សឱ្យបានរហ័ស ។ បន្ទាប់មកត្រូវគូសក្នុងប្រអប់ដែលត្រូវជាមួយនឹងអារម្មណ៍ ឬគំនិតរបស់អ្នកដោយស្មោះត្រង់តាមដែលអាចធ្វើបាន
- » អ្នកត្រូវគិតនិងឆ្លើយឱ្យបានរហ័ស ដោយមិនចាំបាច់ចំណាយពេលវេលាច្រើនទៅលើសំណួរនីមួយៗទេ
- » គ្រូនឹងប្រមូលក្រដាសពីសិក្ខាកាមទាំងអស់ ហើយបន្ទាប់មកចែកក្រដាសមួយសន្លឹកៗទៅឱ្យសិក្ខាកាមវិញដោយមិនដឹងថាជារបស់នរណាម្នាក់ទេ
- » គ្រូនឹងឱ្យសិក្ខាកាមម្នាក់ៗឡើងមកគូសចម្លើយដែលមាននៅលើក្រដាសផ្ទាំងធំដែលដាក់នៅចំពីមុខបន្ទប់
- » នៅពេលដែលគ្រប់គ្នាបានបំពេញក្នុងក្រដាសធំរួចអស់ហើយ គ្រូនឹងដឹកនាំការពិភាក្សានៅលើគំនិតមួយចំនួនដែលបានលើកឡើង និង ពិនិត្យពីឥរិយាបថនិងជំនឿដែលឆ្លុះបញ្ចាំងពីបុគ្គល ព្រមទាំងសួរពីមូលហេតុរបស់វាផង

### ចំណុចដែលត្រូវឆ្លុះបញ្ចាំង

- » តើអ្នកគិតថាឥរិយាបថទាំងនោះឧស្សាហ៍កើតមានញឹកញាប់ដែរឬទេ?
- » តើអ្នកផ្តល់ប្រឹក្សាអាចធ្វើអ្វីខ្លះ នៅពេលជួបអតិថិជនដែលមានឥរិយាបថបែបនេះ?
- » ប្រសិនជាអ្នកជួបអតិថិជនដែលមានឥរិយាបថបែបនេះ តើអ្នកនឹងមានអារម្មណ៍បែបណា?
- » ប្រសិនជាអតិថិជននៅតែបន្តមានឥរិយាបថបែបនេះតទៅទៀត តើអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្តេចដែរ?

## សំណួរស្តីពីឥរិយាបថ

| សំណួរ | តើអ្នកគិតយ៉ាងដូចម្តេចចំពោះអាកប្បកិរិយាខាងក្រោម? | យល់ព្រម | មិនយល់ព្រម |
|---|---|---|---|
| ១ | បុរសរួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទ | | |
| ២ | នារីបំរើស្រាបៀររួមភេទជាមួយភ្ញៀវដើម្បីរកប្រាក់ឱ្យបានច្រើនថែមទៀត | | |
| ៣ | បុរសរួមភេទជាមួយគូសង្សារច្រើន | | |
| ៤ | បុរសមានប្រពន្ធច្រើន | | |
| ៥ | បុរសដែលលួចលាក់មានប្រពន្ធទី២ដោយមិនឱ្យប្រពន្ធទី១ដឹង | | |
| ៦ | ស្ត្រីដែលរៀបការហើយរួមភេទជាមួយមិត្តប្រុស | | |
| ៧ | បុរសដែលរួមភេទជាមួយបុរសដូចគ្នា | | |
| ៨ | សិស្សស្រីរួមភេទជាមួយបុរសអ្នកមានដែលរៀបការរួចហើយ តែនាងមិនស្រលាញ់បុរសនោះទេ | | |
| ៩ | ប៉ូលិសដែលមានប្រពន្ធរួចហើយ បានរួមភេទជាមួយនារីបំរើស្រាបៀរក្រោយពេលស្រវឹង | | |
| ១០ | ស្ត្រីដែលរួមភេទជាមួយស្ត្រីដូចគ្នា | | |
| ១១ | នារីដែលមានមិត្តប្រុសច្រើន | | |
| ១២ | បុរសដែលមានទំនាក់ទំនងផ្លូវភេទជាមួយប្រពន្ធអ្នកដទៃ | | |
| ១៣ | សិស្សស្រីដែលធ្វើជាស្ត្រីរកស៊ីផ្លូវភេទនៅពេលយប់ | | |
| ១៤ | សិស្សអ្នកមានដែលចាក់គ្រឿងញៀនម្តងម្កាល | | |
| ១៥ | យុវវ័យអនាថាចាក់គ្រឿងញៀន | | |
| ១៦ | នារីរកស៊ីផ្លូវភេទមានផ្ទៃពោះ តែសម្រេចចិត្តធ្វើការពន្លូតកូន | | |
| ១៧ | សន្តិសុខដែលមានកូន៤នាក់បានប្រាប់ប្រពន្ធរបស់គាត់ឱ្យយកកូនចេញ | | |
| ១៨ | ជនរងគ្រោះដែលមានផ្ទៃពោះដោយការចាប់រំលោភចង់យកកូនចេញ | | |
| ១៩ | នារីដែលមានទំនាក់ទំនងផ្លូវភេទមុនពេលរៀបការ | | |
| ២០ | បុរសដែលមានទំនាក់ទំនងផ្លូវភេទមុនពេលរៀបការ | | |

## សកម្មភាពទី៣: សមាសភាគនៃការផ្តល់ប្រឹក្សា

# សមាសភាគនៃការផ្តល់ប្រឹក្សា

១-មិនធ្វើការវិនិច្ឆ័យ

២-រក្សាការសម្ងាត់

៣-ទុកអតិថិជនជាមនុស្សសំខាន់

៤-ការយល់ចិត្ត

៥-ជំនាញទំនាក់ទំនងល្អ

៦-មានលទ្ធភាពក្នុងការបញ្ជូនសមស្រប

14

# ១_មិនធ្វើការវិនិច្ឆ័យ

អ្នកផ្តល់ប្រឹក្សា:

- ត្រូវដឹងពីអារម្មណ៍និងអាកប្បកិរិយារបស់ខ្លួនដែលខុសគ្នាពីឥរិយាបថរបស់អ្នកដទៃ
- ត្រូវដឹងពីអាកប្បកិរិយារបស់សង្គមដែលឥរិយាបថរបស់មនុស្សម្នាក់ៗនៅក្នុងសង្គមមានភាពខុសៗគ្នា
- ត្រូវដឹងឮ និងយល់ដឹងឱ្យបានទូលំទូលាយពីសកម្មភាពនិងឥរិយាបថរបស់មនុស្សដទៃ
- ត្រូវទទួលយកនូវការសំរេចចិត្តរបស់អ្នកដទៃ

15

# ធ្វើការវិនិច្ឆ័យ

ធ្វើការវិនិច្ឆ័យមានន័យថា
ជាការប្រើប្រាស់ជំនឿរបស់បុគ្គលដើម្បីឱ្យតម្លៃទៅលើសកម្មភាពរបស់អតិថិជនដោយមិនក្រឡេកមើលពីមូលហេតុ ឬក៏កាលប្បវត្តិនៃស្ថានភាព។
ការវិនិច្ឆ័យអាចៈ

- ធ្វើឱ្យអតិថិជនមានអារម្មណ៍ថាខ្លួនយល់ច្រឡំ
- ប៉ះពាល់ដល់ទំនាក់ទំនងដែលមានជាមួយអតិថិជន
- រារាំងអតិថិជនមិនឱ្យនិយាយអស់ពីរឿងរបស់គាត់
- រារាំងការយល់ដឹងពិតនៃអារម្មណ៍និងបញ្ហារបស់អតិថិជន

ការវិនិច្ឆ័យអាចជាឧបសគ្គចំពោះការផ្តល់ប្រឹក្សា។
អ្វីដែលយើងបានដឹងពីអ្នកដទៃគ្រាន់តែជាផ្នែកមួយនៃរឿងតែប៉ុណ្ណោះ។

16

# ២. ការរក្សាការសម្ងាត់

ការរក្សាការសម្ងាត់មានន័យថាជា ការលាក់ការសម្ងាត់របស់អតិថិជនៈ

- មានសារៈសំខាន់ក្នុងការធ្វើឱ្យអតិថិជនមានជំនឿទុកចិត្តលើអ្នកផ្តល់ប្រឹក្សា
- បើគ្មានការជឿទុកចិត្តពីអតិថិជនទេនោះ ទំនាក់ទំនងរវាងអ្នកផ្តល់ប្រឹក្សានិងអតិថិជនពិតជាមិនអាចប្រព្រឹត្តទៅដោយជោគជ័យបានទេ។
- ការធានានិងការដឹងពីការរក្សាការសម្ងាត់ គឺជាគន្លឹះដ៏សំខាន់ក្នុងការធ្វើឱ្យសេវាផ្តល់ប្រឹក្សាបានទទួលជោគជ័យ។

17

## ៣. អតិថិជនជាមនុស្សដ៏សំខាន់

**អតិថិជនគឺជាមនុស្សដ៏សំខាន់នៅក្នុងដំណើរការផ្តល់ប្រឹក្សា**

អ្នកផ្តល់ប្រឹក្សាមានតួនាទីផ្តល់ព័ត៌មាន និងផ្តល់កំលាំងចិត្តដល់អតិថិជន ដើម្បី:

- ជួយអតិថិជនឱ្យយល់ពីបញ្ហារបស់ពួកគេ
- បង្ហាញឱ្យអតិថិជនឃើញថាមានវិធីច្រើនយ៉ាងសំរាប់ដោះស្រាយបញ្ហា
- បង្ហាញពីគុណវិបត្តិ និងគុណសម្បត្តិ នៃដំណោះស្រាយនីមួយៗ
- ជួយអតិថិជនជ្រើសរើសជំរើសដ៏ល្អបំផុតមួយដោយខ្លួនគេផ្ទាល់
- ឱ្យអតិថិជនត្រៀមចិត្តប្រឈមមុខនឹងលទ្ធផលដែលនឹងកើតឡើងចំពោះការសំរេចចិត្តរបស់ពួកគេ។

18

## ការសំរេចចិត្តជំនួសអតិថិជន

បើសិនជាអ្នកផ្តល់ប្រឹក្សាធ្វើការសំរេចចិត្តជំនួសអតិថិជនៈ

- ការសំរេចចិត្តជំនួសនេះអាចមិនសមស្របសំរាប់អតិថិជន
- តើអ្នកផ្តល់ប្រឹក្សាត្រូវទទួលខុសត្រូវចំពោះលទ្ធផលនៃការសំរេចចិត្តនេះ

គួរជៀសវាងៈ

- ប្រាប់អតិថិជនពីអ្វីដែលពួកគេត្រូវធ្វើ
- បង្ហាញទិសដៅដល់អតិថិជន
- បង្រៀន ឬធ្វើការសំរេចចិត្តជំនួសអតិថិជន

19

## ៤- ការយល់ចិត្តអ្នកដទៃ

ការយល់ចិត្តអ្នកដទៃ មានន័យថាៈ

- ជាការបង្ហាញឱ្យឃើញថាអ្នកយល់ពីអារម្មណ៏របស់អ្នកដទៃ
- កំណត់បាននូវស្ថានភាព ឬ អារម្មណ៏របស់អ្នកដទៃ
- មើលឃើញស្ថានភាពមួយតាមរយៈក្រសៃភ្នែករបស់អ្នកដទៃ
- ផ្តោតការយកចិត្តទុកដាក់លើអ្នកដទៃ

- ស្តាប់យ៉ាងយកចិត្តទុកដាក់ និងព្យាយាមយល់ពីអ្នកដទៃដោយមិនធ្វើការវិនិច្ឆ័យ។
- ការយល់ចិត្តអ្នកដទៃមិនមែនជាការអាណិតអាសូរទេ។

ការអាណិតអាសូរមានន័យថាៈ

- អ្នកមានចិត្តអាណិតមនុស្សម្នាក់ និងមានអារម្មណ៏ដឹងពីស្ថានភាពរបស់មនុស្សនោះ
- អ្នកមើលទៅស្ថានភាពនោះតាមការយល់ឃើញរបស់ខ្លួន
- ផ្តោតអារម្មណ៏តែលើខ្លួនឯង

20

## តើការយល់ចិត្តអតិថិជនមានសារៈសំខាន់អ្វីខ្លះ?

- អតិថិជនមកជួបអ្នកផ្តល់ប្រឹក្សានៅពេលដែលពួកគេមានសំណួរបញ្ហា ឬមានភាពស្មុគស្មាញក្នុងចិត្ត
- អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់ភាពងាយស្រួលដល់អតិថិជន ដើម្បីឱ្យពួកគេអាច :
  - បញ្ចេញអារម្មណ៏
  - និយាយពីបញ្ហា
  - បន្ធូរអារម្មណ៏តានតឹងរបស់ពួកគេ។
- ប្រសិនបើអ្នកផ្តល់ប្រឹក្សាបង្ហាញថាបានយល់ពីអារម្មណ៏ និងស្ថានភាពរបស់ អតិថិជន តាមរយៈពាក្យសំដីក្តី ឬកាយវិការក្តី, ការផ្តល់ប្រឹក្សានឹងអាចឈានដល់ការរកឃើញបញ្ហាចំបង ឬសំខាន់ដទៃទៀត។

21

## ៥_ជំនាញទំនាក់ទំនង

- ស្តាប់យ៉ាងយកចិត្តទុកដាក់
- សួរ និង ស្ទាបស្ទង់មើល
- ផ្តោតអារម្មណ៍
- បញ្ជាក់ឱ្យបានច្បាស់លាស់
- កែតំរូវព័តិមានដែលខុស
- ធ្វើការសង្ខេប

ការពណ៌នាលំអិតមាននៅក្នុងសកម្មភាពទី ៥នៃម៉ូឌុលនេះ ។

22

## ៦_ការបញ្ជូនសមស្រប

អ្នកផ្តល់ប្រឹក្សាត្រូវ:

- ដឹងថាពេលណាដែលត្រូវបញ្ជូនអតិថិជនទៅទទួលសេវាថែទាំនៅកន្លែងផ្សេងទៀតដែលមណ្ឌលមិនអាចមានលទ្ធភាពផ្តល់ជូនអតិថិជនបាន ។
- ដឹងឱ្យបានទូលំទូលាយពីសេវាផ្សេងៗ ឬយន្តការគាំទ្រផ្សេងៗដែលអាចឱ្យអតិថិជនទទួលបាននូវផលប្រយោជន៍ពីសេវាទាំងនោះបាន
- ដឹងថា តើអតិថិជនអាចទទួលសេវាទាំងនោះបានយ៉ាងដូចម្តេច ។

ការអាចទាក់ទងនិងទទួលសេវានានាដែលសមស្រប អាចនឹងឆ្លើយតបទៅនឹងតំរូវការសុខភាព សង្គមឬសេដ្ឋកិច្ចរបស់អតិថិជនបាន ។

23

## សកម្មភាពទី៤: ករណីសិក្សា: ការផ្តល់ដំបូន្មានឬការផ្តល់ប្រឹក្សា

| រឿងរបស់ "ស្រីមុំ" |
|---|
| ខ្ញុំឈ្មោះ "**ស្រីមុំ**" ជានារីរកស៊ីផ្លូវភេទ ។ ខ្ញុំរកប្រាក់បាន៣០ដុល្លារក្នុង១ខែ ។ ខ្ញុំមានសង្សារម្នាក់ ។ ពេលខ្លះគាត់ធ្វើជាកម្មករសំណង់ ។ គាត់រកលុយបានតិចណាស់ ។ ពួកយើងបានរស់នៅជាមួយគ្នាអស់រយៈពេល២ឆ្នាំហើយ ។ ខ្ញុំពិតជាស្រលាញ់គាត់ខ្លាំងណាស់ ហើយចង់បង្កើតគ្រួសារមួយជាមួយគាត់ ។ ពួកយើងរស់នៅជិតទីក្រុងភ្នំពេញ ។<br>ថ្មីៗនេះ ខ្ញុំបានធ្វើតេស្តឈាមរកមេរោគអេដស៍ ។ លទ្ធផលតេស្តរបស់ខ្ញុំគឺវិជ្ជមានបញ្ជាក់ថាខ្ញុំមានផ្ទុកមេរោគអេដស៍ ។ ខ្ញុំមិនដឹងថាសង្សាររបស់ខ្ញុំមានផ្ទុកមេរោគអេដស៍ឬក៏អត់ទេ ។ ខ្ញុំចង់មានកូនមួយ ។ ខ្ញុំគិតថាប្រសិនជាខ្ញុំមានកូន វានឹងធ្វើឱ្យខ្ញុំសប្បាយចិត្ត ។ ខ្ញុំនឹងមានគ្រួសារមួយដូចជាអ្នកដទៃដែរ ហើយនឹងធ្វើឱ្យទំនាក់ទំនងរវាងខ្ញុំនិងសង្សារខ្ញុំកាន់តែជិតស្និទ្ធឡើង ។ ហើយវាក៏អាចបញ្ជាក់ឱ្យគាត់ឃើញថាខ្ញុំពិតជាស្រលាញ់នឹងលះបង់ដើម្បីគាត់មែន ។ ខ្ញុំសូមសួរអ្នកថា: |
| សំណួររបស់ "ស្រីមុំ": តើខ្ញុំគួរមានកូនដែរឬអត់? |

» ចូរសរសេរចម្លើយនៅក្នុងសំណួរនៃរឿងស្រីមុំនិងពន្យល់ពីហេតុផល

» គ្រូនឹងបែងចែកអ្នកជាក្រុមទៅតាមចម្លើយ

» ការពិភាក្សានឹងធ្វើទៅតាមសំណួរដូចតទៅនេះ

១-តើអ្នកមានអារម្មណ៍យ៉ាងណាដែរនៅពេលដែលអតិថិជនមិនធ្វើតាមសំណូមពររបស់អ្នក ?

២-តើអ្នកត្រៀមខ្លួននឹងទទួលខុសត្រូវចំពោះផលវិបាកទាំងឡាយដែលបណ្តាលមកពីសំណើរបស់អ្នកដែរឬទេ ?

៣-តើអ្នកគិតថាអ្នកណាជាអ្នកទទួលបាននូវផលប្រយោជន៍ ប្រសិនជាអតិថិជនធ្វើតាមសំណើរបស់អ្នក

## សកម្មភាពទី៥: ជំនាញក្នុងការទំនាក់ទំនង

### ១. ការស្តាប់យ៉ាងយកចិត្តទុកដាក់

- គោរពដល់អតិថិជន:
  - ផ្តល់សេរីភាពឱ្យអតិថិជនបញ្ចេញគំនិត ឬ ការបារម្ភរបស់គាត់
  - មិនត្រូវនិយាយលូកមាត់នៅពេលអតិថិជនកំពុងស្ងាត់ស្ងៀមទេ គឺត្រូវទុកពេលឱ្យ គាត់គិត
  - មិនត្រូវសួរសំណួរនាំមុខដែលអតិថិជនបំរុងនឹងនិយាយប្រាប់
- បង្ហាញនូវចំណាប់អារម្មណ៍ និងការយល់ចិត្តចំពោះអតិថិជន
  - ព្យាយាមយល់ពីបញ្ហាឱ្យបានស៊ីជំរៅ
  - ព្យាយាមយល់ពីអារម្មណ៍របស់អតិថិជនចំពោះស្ថានភាពរបស់គាត់
- យកចិត្តទុកដាក់:
  - ស្តាប់នូវអ្វីដែលអតិថិជនបាននិយាយប្រាប់
  - សង្កេតពីអារម្មណ៍របស់អតិថិជនដែលមិននិយាយចេញមកក្រៅ និងទឹកមុខព្រួយ បារម្ភរបស់គាត់តាមរយៈ ការបន្លឺសំលេង ទឹកមុខ និងកាយវិការ ។

26

### ២. ការសួរនិងការស្ទាបស្ទង់

សំណួរបើក :

- លើកទឹកចិត្តអតិថិជនឱ្យនិយាយនិងផ្តល់ព័ត៌មាន
- ជារឿយៗសំណួរតែងផ្តើមដោយពាក្យ " យ៉ាងដូចម្តេច....តើអ្វី...ពេលណា...ឬ ហេតុអ្វី "
- ទាមទារឱ្យមានចម្លើយលើសពីមួយ

  ឧ: តើអ្នកមានអារម្មណ៍យ៉ាងណាដែរចំពោះជម្ងឺប្តីរបស់អ្នក?

ការស្ទាបស្ទង់ :

- មានន័យថា ជាការប្រើសំណួរដើម្បីសួរឱ្យយល់ពីស្ថានភាពមួយឱ្យបានកាន់តែច្បាស់ និងកាន់តែលំអិត ។ ឧ: សូមប្រាប់ខ្ញុំបន្ថែមទៀតអំពី........

សំណួរបិទ :

- ត្រូវបានប្រើដើម្បីស្វែងរកព័ត៌មានពិត ឬបញ្ជាក់ពីព័ត៌មានអ្វីមួយ
- តំរូវឱ្យមានតែចម្លើយ ចាំ ឬ ទេ ឬចម្លើយខ្លីបំផុត ប៉ុណ្ណោះ ។ ឧ: តើអ្នកមានកូនដែរឬទេ?

27

### ៣. ការផ្តោតអារម្មណ៍

អតិថិជនអាចមានបញ្ហាច្រើន ឬស្មុគស្មាញ និងអាចមានការរំជួលចិត្តខ្លាំងដោយសារតែស្ថានភាពរបស់គាត់ ។

ការផ្តោតអារម្មណ៍អាចជួយ:

- កំណត់រកបញ្ហា និងគោលដៅនៃការផ្តល់ប្រឹក្សា ហើយនិងនៅតែផ្តោតអារម្មណ៍លើបញ្ហាទាំងនោះ
- ទាញអារម្មណ៍ការសន្ទនាឱ្យត្រឡប់ទៅរកចំណុចសំខាន់ៗ ឬទៅរកគោលដៅ

ជាការសំខាន់ណាស់ដែលការសន្ទនាឈានចូលដល់ចំណុចដទៃទៀតនៅពេលបន្ទាប់ក្នុងពេលតែមួយ ឬនៅពេលក្រោយទៀត ដើម្បីបានធ្វើការដោះស្រាយ ។

28

### ៤. ការបញ្ជាក់ឱ្យច្បាស់លាស់ឡើងវិញ

បើសិនជាអតិថិជននិយាយប្រាប់រឿងមិនសូវច្បាស់លាស់ ឬមួយអ្នកផ្តល់ប្រឹក្សាត្រូវការព័ត៌មានបន្ថែមទៀត: អ្នកផ្តល់ប្រឹក្សាអាចព្យាយាមសួរបញ្ជាក់បញ្ហា ឬរឿងឡើងវិញឱ្យច្បាស់លាស់ ដោយនិយាយឡើងវិញនូវអ្វីដែលអតិថិជនបាននិយាយដោយប្រើប្រយោគផ្សេង ។

របៀបនេះគេហៅ ការឆ្លុះបញ្ចាំងត្រឡប់ ឬ ប៉ារ៉ាហ្វ្រេស៊ីង **Paraphrasing.**

ឧទាហរណ៍:

- អតិថិជននិយាយ: "ខ្ញុំខឹងខ្លាំងណាស់ដែលប្តីរបស់ខ្ញុំក្បត់ខ្ញុំ"

  អ្នកផ្តល់ប្រឹក្សាអាចនិយាយថា:

  "ដូច្នេះអ្នកមិនសប្បាយចិត្តចំពោះឥរិយាបថរបស់ប្តីអ្នកមែនទេ?"ឬ
- អតិថិជននិយាយថា: "ក្នុងអាទិត្យនេះ កូនខ្ញុំហាក់ដូចជាឃ្លានខ្លាំងណាស់ ខ្ញុំគិតថាទឹកដោះរបស់ខ្ញុំមិនគ្រប់គ្រាន់ទេ"

  អ្នកផ្តល់ប្រឹក្សា: "កូនរបស់អ្នកហាក់ដូចជាឃ្លានខ្លាំងជាងមុនឬនៅក្នុងអាទិត្យនេះ?"

29

## ៥. ការកែតំរូវព័ត៌មានដែលខុស

អ្នកផ្តល់ប្រឹក្សា ត្រូវទទួលខុសត្រូវក្នុងការៈ

- ផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់
- កែតំរូវគំនិតភ័ន្តច្រឡំទាំងឡាយ

ក្នុងកំឡុងពេលផ្តល់ប្រឹក្សា អ្នកផ្តល់ប្រឹក្សាគួរតែ

- កំណត់រកនូវព័ត៌មានដែលខុស ឬ ទស្សនៈភ័ន្តច្រឡំ
- កែតំរូវព័ត៌មានទាំងនោះឱ្យបានឆាប់រហ័ស តែត្រឹមត្រូវ

ឧៈ "មនុស្សជាច្រើនគិតថា........... ក៏ប៉ុន្តែ............."

30

## ៦. ការសង្ខេប

នៅចុងបញ្ចប់នៃការសន្ទនា អ្នកផ្តល់ប្រឹក្សាគួរតែ**សង្ខេប ឬរំលឹកឡើងវិញ**ពី :

- អ្វីដែលពួកគេបានពិភាក្សាក្នុងពេលនោះ
- ជំរើសដែលពួកគេបានពិចារណា
- ការសំរេចចិត្តដែលអតិថិជនបានធ្វើ
- ផែនការដែលពួកគេបានគិតទុករួចស្រេច

31

### សកម្មភាពទី៦: ដំណើរការនៃការផ្តល់ប្រឹក្សា

## ដំណើរការនៃការផ្តល់ប្រឹក្សា

ដំណើរការនៃការផ្តល់ប្រឹក្សាមាន៣ដំណាក់កាលៈ

១. ដំណាក់កាលរាវរកបញ្ហា :

តើខ្ញុំមានបញ្ហាអ្វី រឿងអ្វី និងការព្រួយបារម្ភពីអ្វី?

២. ដំណាក់កាលយល់ពីបញ្ហា

តើខ្ញុំត្រូវការអ្វី និងចង់បានអ្វី យោងតាមលទ្ធភាពសព្វថ្ងៃដែលខ្ញុំមាន?

៣. ដំណាក់កាលអនុវត្តវិធានការណ៍

តើខ្ញុំត្រូវធ្វើអ្វី ដើម្បីទទួលបាននូវរបស់ដែលខ្ញុំត្រូវការ?

ដំណាក់កាលទាំងនេះ អាចកើតឡើងជាបន្តបន្ទាប់គ្នា ឬកើតមានដំណាលគ្នា ។

33

## ១. ដំណាក់កាលរាវរកបញ្ហា

នៅក្នុងដំណាក់កាលរាវរកបញ្ហា អ្នកផ្តល់ប្រឹក្សាត្រូវបង្កើតទំនាក់ទំនងដែលធ្វើឱ្យអតិថិជនមានអារម្មណ៍ថាមានសុវត្ថិភាពគ្រប់គ្រាន់ ក្នុងការ :

- រាវរកនូវការលំបាក បញ្ហា រឿងរ៉ាវ ការព្រួយបារម្ភរបស់ពួកគេ
- និយាយប្រាប់រឿងផ្ទាល់ខ្លួនរបស់គាត់
- ជ្រើសរើសបញ្ហា ឬឱកាសត្រឹមត្រូវ ដើម្បីដោះស្រាយជាមួយអ្នកផ្តល់ប្រឹក្សា

អ្នកផ្តល់ប្រឹក្សាៈ

- ប្រើជំនាញដូចជា ស្តាប់យ៉ាងយកចិត្តទុកដាក់ ឆ្លុះបញ្ចាំង យល់ចិត្ត និងការគោរព
- ផ្តោតអារម្មណ៍ទៅលើបញ្ហារបស់អតិថិជន
- ជួយអតិថិជនឱ្យប្រាកដក្នុងចិត្ត និងផ្តោតទៅលើបញ្ហាដែលគាត់បារម្ភខ្លាំងបំផុត ។

34

## ២. ដំណាក់កាលយល់ពីបញ្ហា

នៅក្នុងដំណាក់កាលនេះ អ្នកផ្តល់ប្រឹក្សាត្រូវជួយនិងលើកទឹកចិត្តអតិថិជនឱ្យ :

- យល់ពីបញ្ហា ឬស្ថានភាពរបស់គាត់ឱ្យកាន់តែស៊ីជំរៅ
- កំណត់នូវអ្វីដែលពួកគាត់ត្រូវការ និងចង់បាន
- រៀបចំផែនការដើម្បីផ្លាស់ប្តូរ
- រៀបចំគោលដៅ និងផែនការឱ្យបានសមស្រប ដើម្បីឱ្យបានសំរេចគោលដៅនោះ ។

អ្នកផ្តល់ប្រឹក្សាអាចត្រូវ :

- លើកឡើងនូវគំនិតទាំងអស់ដែលមាន
- ផ្តល់គំនិតថ្មីៗ
- គាំទ្រលើកទឹកចិត្តឱ្យអតិថិជនទំលាយអាថិកំបាំងរបស់គាត់ដោយខ្លួនឯង ។

35

## ៣. ដំណាក់កាលអនុវត្តវិធានការណ៍

នៅក្នុងដំណាក់កាលនេះ អ្នកផ្តល់ប្រឹក្សាជួយអតិថិជនៈ

- ឱ្យរកគិតមើលនូវអ្វីដែលពួកគាត់ចង់បាន
- ឱ្យឃើញថាមានវិធីផ្សេងៗជាច្រើនដែលអាចជួយគាត់ឱ្យសំរេចគោលបំណងបាន
- ជ្រើសរើសជំរើសប្រសើរបំផុតដែលសមស្របទៅនឹងស្ថានភាព និងកាលៈទេសៈរបស់គាត់
- រៀបចំផែនការ
- រៀបចំសកម្មភាពសំរាប់អនុវត្តផែនការ

អតិថិជនប្រើប្រាស់យុទ្ធវិធីផ្សេងៗគ្នាក្នុងការសំរេចចិត្ត និង ប្រើប្រាស់បច្ចេកទេសផ្សេងៗដើម្បីដោះស្រាយបញ្ហា ។

អតិថិជនជ្រើសរើសវិធីអនុវត្តដោយខ្លួនឯង (ផ្លូវបដិបត្តិ course of action)

36

## សមាសភាគនៃដំណើរការផ្តល់ប្រឹក្សា

ដំណាក់កាលដែលត្រូវអនុវត្តក្នុងពេលផ្តល់ប្រឹក្សាមានៈ

១. បង្កើតទំនាក់ទំនងជាមួយអតិថិជន

២. កំណត់រកបញ្ហា

៣. ផ្តល់ព័ត៌មាន និងបញ្ជាក់ឱ្យបានច្បាស់លាស់បើសិនចាំបាច់

៤. ពិចារណាពីជំរើសជាក់លាក់

៥. លើកទឹកចិត្តអតិថិជនឱ្យចេះដោះស្រាយបញ្ហា

៦. សង្ខេបការសន្ទនា

37

## ១. បង្កើតទំនាក់ទំនងជាមួយអតិថិជន

នៅពេលចាប់ផ្តើមពិភាក្សា អ្នកផ្តល់ប្រឹក្សាត្រូវៈ

- ស្វាគមន៍អតិថិជន
- ណែនាំខ្លួនប្រាប់អតិថិជន
- សង្កត់ធ្ងន់ពីការរក្សាការសម្ងាត់
- សង្ខេបពីដំណើរការនៃការផ្តល់ប្រឹក្សា (ថ្ងៃនេះយើងនឹង..........?)

38

## ២. កំណត់រកបញ្ហា

បន្ទាប់មក អ្នកផ្តល់ប្រឹក្សាត្រូវៈ

- សួរអតិថិជនអំពីការព្រួយបារម្ភរបស់គាត់
- រកមើលបន្ថែមពីផលប៉ះពាល់នៃបញ្ហាជីវិតរបស់គាត់ (បើកបង្អួចដើម្បីឱ្យខ្យល់ចូល)

39

## ៣. ផ្តល់ព័ត៌មាននិងបញ្ជាក់ឱ្យច្បាស់លាស់

អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់ព័ត៌មានដល់អតិថិជនឱ្យបាន :

- ច្បាស់លាស់ពិតប្រាកដ
- ត្រូវចំសាច់រឿង
- បង្ហាញឱ្យបានច្បាស់លាស់

អ្នកផ្តល់ប្រឹក្សាត្រូវសួរសំណួរដែលត្រឹមត្រូវដើម្បី :

- យល់ពីបញ្ហា ឬស្ថានភាពរបស់អតិថិជនឱ្យកាន់តែច្បាស់ឡើង
- បញ្ជាក់ពីចំណុចសំខាន់ៗឱ្យបានច្បាស់ល្អ

40

## ៤. ជំរើសដែលត្រូវពិចារណា

អ្នកផ្តល់ប្រឹក្សាត្រូវណែនាំអតិថិជនឱ្យ :

- គិតពីជំរើសដែលគាត់អាចធ្វើទៅបាន
- ពិនិត្យពីគុណសម្បត្តិ និង គុណវិបត្តិនៃជំរើសនីមួយៗ
- គិតដល់ផលវិបាកនៃជំរើសនីមួយៗដែលអាចកើតមានឡើង
- ចេះថ្លឹងថ្លែង វាយតម្លៃ និងសំរេចចិត្ត លើជំរើសដែលគាត់បានជ្រើសរើស ។

41

## ៥. លើកទឹកចិត្តអតិថិជនឱ្យចេះដោះស្រាយបញ្ហា

អ្នកផ្តល់ប្រឹក្សានិងអតិថិជនត្រូវធ្វើការរួមគ្នាដើម្បី :

- រាវរកនូវចំណុចបញ្ហាជាអាទិភាព ដើម្បីគ្រប់គ្រងជាបន្ទាន់ និងរាវរកពីតំរូវការសំរាប់ពេលក្រោយ
- រៀបចំគំរោងសំរាប់អនុវត្តជាបន្ទាប់ទៀត
- រាវរកជំរើសផ្សេងៗទៀត ដើម្បីផ្តល់ការគាំទ្រ

42

| ៦. សង្ខេបការសន្ទនា | |
|---|---|
| ដើម្បីបញ្ចប់ អ្នកផ្តល់ប្រឹក្សាគួរតែ :<br>■ សង្ខេបលទ្ធផលដែលពួកគាត់ទទួលបាន និងអ្វីដែលនៅសល់មិនទាន់ដោះស្រាយ<br>■ ពិនិត្យពីកំរិតនៃការយល់ដឹងរបស់អតិថិជន និងបកស្រាយឱ្យបានច្បាស់នូវចំណុចនានាដែលអតិថិជនមិនទាន់យល់<br>■ បញ្ជាក់អោយច្បាស់ថា "ទ្វារនៅបើកចំហជានិច្ច"សំរាប់អតិថិជនដែលត្រឡប់មកវិញ<br>■ ផ្តល់សេចក្តីក្លាហានដល់អតិថិជន<br>■ ធ្វើការណាត់ជួបពេលក្រោយដើម្បីតាមដានបន្ថែម<br>43 | |

## សកម្មភាពទី៧: ល្បែងដើរតួ

» អ្នកនឹងមានឱកាសអនុវត្តនូវជំនាញប្រឹក្សា តាមរយៈរឿងរបស់ស្រីល័ក្ខណ៍

» គ្រូនឹងចែកសិក្ខាកាមជាក្រុមតូចៗ និងស្នើឱ្យក្រុមនីមួយៗដើរតួ ម្នាក់ជាអ្នកផ្តល់ប្រឹក្សានិងមានម្នាក់ទៀតជាអតិថិជន អ្នកនៅសល់ត្រូវដើរតួជាអ្នកសង្កេតការណ៍

» សូមអានសាច់រឿងនិងបន្ទាប់មកត្រៀមខ្លួនសំដែងរឿង

» ប្រសិនជាអ្នកដើរតួជា "អ្នកផ្តល់ប្រឹក្សា" ត្រូវអនុវត្តតាមដំណើរការនៃការផ្តល់ប្រឹក្សានិងផ្តោតអារម្មណ៍ជាពិសេសទៅលើសមាសភាគនៃការផ្តល់ប្រឹក្សាដែលអ្នកបានរៀន

ប្រសិនអ្នកជា "អ្នកសង្កេតការណ៍" ត្រូវប្រើក្រដាសវាយតម្លៃ។ បន្ថែមពីលើការសង្កេតការណ៍ និងត្រៀមផ្តល់យោបល់ដល់ការប្រឹក្សា អ្នកត្រូវព្យាយាមរកវិធីសួរសំណួរ ធ្វើការស្រាយបំភ្លឺឬក៏ធ្វើការសង្ខេបផងដែរ។

| រឿងរបស់ស្រីល័ក្ខណ៍ |
|---|
| "ស្រីល័ក្ខណ៍" មានអាយុ២៤ឆ្នាំ។ ប្តីរបស់នាងគឺជាប៉ូលីស។ គាត់ធ្លាប់ធ្វើការនៅព្រំដែនជាមួយវៀតណាម។ ឥឡូវនេះពួកគេកំពុងរស់នៅជាមួយគ្នានៅខេត្តតាកែវ។ នាងមានផ្ទៃពោះកូនទីមួយ៥ខែហើយ។ ថ្មីៗនេះមិត្តភក្តិរួម ការងាររបស់ប្តីនាងម្នាក់បានឈឺហើយស្លាប់។ អ្នកភូមិនាំគ្នានិយាយថាគាត់ស្លាប់ដោយសារជំងឺអេដស៍។ "ស្រីល័ក្ខណ៍" មានក្តីព្រួយបារម្ភណ៍ជាខ្លាំង។ នាងចង់ដឹងថា តើនាងគួរធ្វើអ្វីខ្លះ។ |

នៅពេលដែលអ្នកបានបញ្ចប់ការដើរតួហើយ គ្រូនឹងឱ្យអ្នកពិភាក្សាពីការដើរតួរបស់អ្នក

## ម៉ូឌុលទី៧: ចំណុចគន្លឹះ

បុគ្គលិកលក្ខណៈនៃអ្នកផ្តល់ប្រឹក្សាល្អ

- **ស្វាគមន៍**អតិថិជនដោយការគោរពណែនាំខ្លួនទៅកាន់អតិថិជន ពន្យល់ប្រាប់អតិថិជនអំពីតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកផ្តល់ប្រឹក្សា
- **យល់**អំពីបញ្ហានិងនៅតែផ្តោតទៅលើវាជានិច្ច
- **ដឹង**អំពីវប្បធម៌ សាសនា និងចិត្តវិទ្យាដែលជាកត្តាដែលអាចមានឥទ្ធិពលលើអតិថិជន
- **បង្ហាញការគោរព** ទឹកចិត្តសប្បុរសធម៌ និងការមិនធ្វើការវិនិច្ឆ័យលើអតិថិជន
- **បង្ហាញព័ត៌មាន**យ៉ាងត្រឹមត្រូវដោយប្រើភាសាដែលអតិថិជនអាចយល់បាន
- **លើកទឹកចិត្ត**ឱ្យអតិថិជនសួរសំណួរផ្សេងៗ
- **ស្តាប់យ៉ាងយកចិត្តទុកដាក់** និងត្រូវចាប់អារម្មណ៍ដល់ទំនាក់ទំនងកាយវិការ
- **ដឹងច្បាស់**អំពីពេលដែលត្រូវបញ្ជូនអតិថិជនទៅទទួលសេវាថែទាំគាំទ្របន្ថែម ។

**កំហុសដែលតែងតែកើតមានក្នុងពេលផ្តល់ប្រឹក្សា**

- **ការវិនិច្ឆ័យ** — អំពីជីវិតឬឥរិយាបថរបស់អតិថិជន
- **សីលធម៌** ឬ ការប្រៀនប្រដៅ — ប្រាប់អតិថិជនអំពីឥរិយាបថដែលគាត់គួរធ្វើ
- **ការពាក់ស្លាក** — មិនស្វែងយល់អំពីទឹកចិត្ត ការភ័យខ្លាច និងការបារម្ភរបស់អតិថិជន ។ ឧ. អ្នកផ្តល់ប្រឹក្សាគិតថា នារីរកស៊ីផ្លូវភេទសុទ្ធតែដូចគ្នាទាំងអស់ ។
- **មានទំនុកចិត្តហួសពេក**- ព្យាយាមបង្កើតឱ្យមានសុទិដ្ឋិនិយមដោយធ្វើឱ្យបញ្ហារឿងរ៉ាវរបស់អតិថិជន ទៅជារឿងធូរស្រាល
- **មិនទទួលយកអារម្មណ៍**របស់អតិថិជន-ដោយនិយាយថាអារម្មណ៍ទាំងអស់មានការខុសគ្នា ឬប្រាប់ពួកគេមិនឱ្យបារម្ភពីបញ្ហានោះ
- **មិនចាត់ទុកការ**បារម្ភរបស់អតិថិជនជារឿងសំខាន់
- **ការទូន្មាន**-ផ្តល់ការណែនាំមុនពេលអតិថិជនឈានទៅរកការសម្រេចចិត្ត
- **ការសួរ**-ដោយប្រើសំណួរដូចជាចោទប្រកាន់ "ហេតុអ្វី"? សំណួរនេះឮសូរហាក់ដូចជាការចោទប្រកាន់ដល់អតិថិជន ។
- **លើកទឹកចិត្តអតិថិជន**ឱ្យពឹងផ្អែកទាំងស្រុង- ដោយបង្កើននូវតម្រូវការរបស់អតិថិជនឱ្យត្រូវការជាប្រចាំនូវវត្តមាន និងការជួយបង្ហាញផ្លូវពីអ្នកផ្តល់ប្រឹក្សា ។

## ឧបសម្ព័ន្ធទី៧

### ក្រដាសវាយតម្លៃសម្រាប់ល្បែងដើរតួ

| **តើអ្នកផ្ដល់ប្រឹក្សាមានអនុវត្តតាមដំណាក់កាលនៃការផ្ដល់ប្រឹក្សាដែរឬទេ?** | **មាន** | **គ្មាន** |
|---|---|---|
| បង្កើតឱ្យមានភាពជិតស្និទ្ធជាមួយអតិថិជន | | |
| កំណត់រកនូវបញ្ហា | | |
| ផ្ដល់ព័ត៌មាន | | |
| ពិចារណាពីជម្រើសដែលប្រាកដនិយម | | |
| លើកទឹកចិត្តអតិថិជនឱ្យចេះដោះស្រាយបញ្ហា | | |
| ធ្វើការសង្ខេប | | |
| **តើអ្នកផ្ដល់ប្រឹក្សាមានបង្ហាញពីជំនាញទំនាក់ទំនងល្អដែរឬទេ?** | | |
| ស្ដាប់ដោយយកចិត្តទុកដាក់ | | |
| សួរសំណួរអម | | |
| ផ្ដោតលើបញ្ហារបស់អតិថិជន | | |
| ការស្រាយបំភ្លឺនិងសួរបញ្ជាក់ | | |
| កែព័ត៌មានដែលនាំឱ្យយល់ខុស | | |
| សង្ខេប | | |

# ម៉ូឌុលទី៨
# ការផ្តល់ប្រឹក្សានៅក្នុងបរិបទនៃមេរោគអេដស៍-ជំងឺអេដស៍

## វត្ថុបំណង

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. កំណត់បានអំពីប្រភេទនៃការផ្តល់ប្រឹក្សាដែលអាចមានការខុសគ្នានៅក្នុងបរិបទនៃមេរោគអេដស៍-ជំងឺអេដស៍
២. ពន្យល់អំពីសារៈសំខាន់ និងរាយបញ្ជីសមាសភាគនៃការរក្សាការសម្ងាត់នៅក្នុងការផ្តល់ប្រឹក្សាស្តីអំពីមេរោគអេដស៍-ជំងឺអេដស៍
៣. កំណត់បាននូវមូលហេតុដែលនាំឱ្យមានគំនិតមាក់ងាយឬបញ្ចេញឥរិយាបថរើសអើង
៤. ពិភាក្សាអំពីទស្សនៈភ័ន្តច្រឡំអំពីមេរោគអេដស៍-ជំងឺអេដស៍ និងការឆ្លើយតបទៅនឹងទស្សនៈភ័ន្តច្រឡំទាំងនេះ
៥. ពិភាក្សាអំពីបែបផែនសំខាន់ៗនៃការផ្តល់ប្រឹក្សាដល់យុវវ័យ ស្ត្រីមិនទាន់រៀបអាពាហ៍ពិពាហ៍ និងក្រុមមនុស្សដែលសង្គមមិនសូវចាប់អារម្មណ៍
៦. អធិប្បាយអំពីវិធីផ្តល់ប្រឹក្សាផ្សេងៗគ្នា និងកំណត់បានអំពីគុណសម្បត្តិនិងគុណវិបត្តិនៃការផ្តល់ប្រឹក្សា



*រយៈពេល:* ***៣ម៉ោង***

## សកម្មភាពទី១: ការផ្តល់ប្រឹក្សានៅក្នុងបរិបទនៃមេរោគអេដស៍-ជំងឺអេដស៍

### តើមេរោគអេដស៍_ជម្ងឺអេដស៍មានអ្វីជាពិសេស?

ជម្ងឺអេដស៍គឺជា:

- ជម្ងឺដែលត្រូវកើតមានរហូតអស់មួយជីវិត គំរាមកំហែងដល់ជីវិត និងមិនអាចព្យាបាលឱ្យជាសះស្បើយបានឡើយ
- ជម្ងឺឆ្លង និងឆ្លងជាពិសេសតាមរយៈការរួមភេទផ្ទុយគ្នា
- ជម្ងឺដែលមានច្រើននៅលើមនុស្សពេញវ័យ
- ជម្ងឺដែលមិនអាចដឹងទុកជាមុនបាន និងមានភាពស្មុគស្មាញដោយមានភ្ជាប់មកជាមួយនូវផលវិបាកនៃរូបកាយ ផ្លូវចិត្ត និងសង្គម
- រួមផ្សំជាមួយនឹងការមាក់ងាយនិងរើសអើង

បញ្ហាពាក់ព័ន្ធនឹងការឆ្លងមេរោគអេដស៍-ជម្ងឺអេដស៍អាចធ្វើឱ្យមានការឈឺចាប់ភ័យខ្លាច និងគំរាមកំហែងដល់អ្នកជម្ងឺ និងបុគ្គលិកសុខាភិបាល ។

**ការផ្តល់ប្រឹក្សាអាចជួយដោះស្រាយបញ្ហាទាំងអស់បាន**

5

### ផលប៉ះពាល់នៃការធ្វើរោគវិនិច្ឆ័យមេរោគអេដស៍

ការទទួលរោគវិនិច្ឆ័យថាមានផ្ទុកមេរោគអេដស៍ អាចមានផលប៉ះពាល់ដូចជា:

- **ផលប៉ះពាល់ខាងផ្លូវចិត្ត** ដូចជា: វន្ទត់ ភ័យខ្លាច ខ្មាស់អៀន
- **ផលប៉ះពាល់ខាងសេដ្ឋកិច្ច** ដូចជា: មិនអាចធ្វើការបាន បាត់បង់ការងារឬបាត់បង់អតិថិជន ត្រូវចំណាយថវិកាសំរាប់ថែទាំសុខភាព
- **ផលប៉ះពាល់ដល់សង្គម** ដូចជា: ការមាក់ងាយនិងរើសអើង ខ្លាចអ្នកដទៃដឹងរឿងខ្លួន បាត់បង់នូវការគោរព ឬទ្រព្យសម្បត្តិ ឬក៏មិត្តភ័ក្រ្ត
- **ផលប៉ះពាល់ដល់គ្រួសារ** ដូចជា: ព្រួយបារម្ភអំពីគ្រួសារ និងកូន តើនឹងមានអ្វីកើតឡើងចំពោះសមាជិកគ្រួសារដទៃទៀត

6

### តើការផ្តល់ប្រឹក្សាអាចទទួលបាននូវអ្វីខ្លះ?

ការផ្តល់ប្រឹក្សាអាចជួយអ្នកផ្ទុកមេរោគអេដស៍:

- ផ្លាស់ប្តូរឥរិយាបថប្រឈមនិងរក្សាបាននូវការផ្លាស់ប្តូរនោះ
- ដឹងពីវិធីរួមភេទដែលមានសុវត្ថិភាពជាងមុន និងឆ្លើយតបទៅនឹងទំនាក់ទំនងសង្គម
- រៀនរស់នៅជាមួយជម្ងឺរបស់គាត់
- ចេះដោះស្រាយបញ្ហាយ៉ាងសកម្ម ដើម្បីធ្វើឱ្យជីវិតរបស់គាត់កាន់តែប្រសើរឡើង
- ចេះត្រួតពិនិត្យលើជីវិតរបស់គាត់ដោយរៀនដោះស្រាយបញ្ហា និងអាចធ្វើការសំរេចចិត្តដោយខ្លួនឯងបាន ។

7

### តើការផ្តល់ប្រឹក្សាស្តីពីមេរោគអេដស៍_ជម្ងឺអេដស៍ខុសគ្នាយ៉ាងដូចម្តេច?

ការផ្តល់ប្រឹក្សានៅក្នុងបរិបទនៃមេរោគអេដស៍-ជម្ងឺអេដស៍ តំរូវឱ្យមានការពិភាក្សាយ៉ាងជាក់លាក់ អំពី:

- ការអនុវត្តន៍រួមភេទ
- ភាពមានជម្ងឺ ការរៀបស្លាប់ និងការស្លាប់

ការផ្តល់ប្រឹក្សានេះមានភាពស្មុគស្មាញដោយសារតែការភ័យខ្លាចនិងដោយសារតែប្រឈមនឹងការមាក់ងាយនិងរើសអើង ។

8

## អ្នកផ្តល់ប្រឹក្សាអំពីមេរោគអេដស៍_ជម្ងឺអេដស៍

អ្នកផ្តល់ប្រឹក្សាអំពីមេរោគអេដស៍-ជម្ងឺអេដស៍:

- អាចធ្វើការជាមួយអតិថិជនដែលមានទស្សនៈនិងតម្លៃខុសគ្នាឆ្ងាយពីទស្សនៈនិងតម្លៃរបស់ខ្លួន
- នឹងត្រូវតស៊ូជំនះលើខ្លួនឯងដើម្បីស្វែងយល់ពីភាពលំអៀងនិងផ្នត់គំនិតពីកំណើតរបស់ខ្លួន
- អ្នកផ្តល់ប្រឹក្សាត្រូវគិតដល់ដៃគូ និងសមាជិកគ្រួសារដទៃទៀត ព្រមទាំងអតិថិជនផងដែរ ។

> អ្នកផ្តល់ប្រឹក្សាត្រូវដឹងអំពីចំណុចវសើបនៃបញ្ហារក្សាការសម្ងាត់
> និងការបង្ហាញឱ្យគេដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ ។

9

## ការផ្តល់ប្រឹក្សានៅក្នុងបរិបទនៃការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

| ប្រធានបទនៃការផ្តល់ប្រឹក្សា | សមាសភាគនៃការផ្តល់ប្រឹក្សា |
|---|---|
| ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ | ■ ព័ត៌មានទាក់ទងទៅនឹងមេរោគអេដស៍-ជម្ងឺអេដស៍<br>■ ការប៉ាន់ប្រមាណពីគ្រោះប្រឈម<br>■ ការសំរេចចិត្តក្នុងការធ្វើតេស្ត<br>■ ការផ្តល់ប្រឹក្សាក្រោយតេស្ត |
| ការបង្ការការចម្លងមេរោគអេដស៍ | ■ នៅពេលផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត ( ព្រមឬមិនព្រមធ្វើតេស្ត)<br>■ នៅពេលផ្តល់ប្រឹក្សាក្រោយតេស្ត ( ទាំងលទ្ធផលតេស្តវិជ្ជមាននិងអវិជ្ជមាន)<br>■ បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន |
| ការបង្ហាញឱ្យគេដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ | ■ ថាតើត្រូវបង្ហាញឱ្យគេដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ដែរឬទេ<br>■ តើត្រូវប្រាប់ទៅនរណា<br>■ ប្រាប់ដូចម្តេច និង នៅពេលណា |
| ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន | ■ ព័ត៌មានស្តីពីអាហារូបត្ថម្ភ<br>■ ជំរើសនៃការចិញ្ចឹមកូន<br>■ ការពាក់ព័ន្ធទៅនឹងការបង្ហាញឱ្យគេដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ |
| ការផ្តល់ប្រឹក្សាសំរាប់សំរបទៅនឹងមេរោគ អេដស៍-ជម្ងឺអេដស៍ ការថែទាំនិងគាំទ្រ | ■ ការចូលរួមពីក្រុមគ្រួសារ<br>■ ការបញ្ជាន<br>■ ទំនាក់ទំនងជាមួយនឹងសហគមន៍ |

10

## សកម្មភាពទី២: យល់ដឹងអំពីការរក្សាការសម្ងាត់

## ការរក្សាការសម្ងាត់

### ត្រូវរក្សាព័ត៌មានឯកជនដែលបានដឹងរវាងអតិថិជន និងអ្នកផ្តល់ប្រឹក្សា

## ការរក្សាការសម្ងាត់នៅក្នុងបរិបទនៃមេរោគអេដស៍_ជម្ងឺអេដស៍

ការរក្សាការសម្ងាត់មានសារៈសំខាន់ជាពិសេសក្នុងការផ្តល់ប្រឹក្សាដោយសារតែ :

- បញ្ហាអេដស៍មានជាប់ទាក់ទងនឹងការមាក់ងាយនិងរើសអើង
- ទំនាក់ទំនងរវាងការចម្លងមេរោគអេដស៍ជាមួយនឹង
  - ឥរិយាបថរួមភេទ
  - ឥរិយាបថប្រឈមឬក៏ឥរិយាបថប្រព្រឹត្តខុសច្បាប់ ដូចជាការប្រើប្រាស់គ្រឿងញៀន ការរកស៊ីផ្លូវភេទ។

13

## សមាសភាគនៃការរក្សាការសម្ងាត់

១. ការជឿទុកចិត្ត

២. ការសុំអនុញ្ញាតដើម្បីបង្ហាញព័ត៌មាន

៣. ភាពជាឯកជន

៤. កំណត់ត្រាសម្ងាត់

៥. ការបញ្ជូនសមស្រប

14

## ១.ការជឿទុកចិត្ត

ការរក្សាការសម្ងាត់ ៖

- មានសារៈសំខាន់សំរាប់បង្កើតឱ្យមានការជឿទុកចិត្ត
- ការជឿទុកចិត្តគឺជាចំណុចសំខាន់ក្នុងការធ្វើឱ្យដំណើរការនៃការផ្តល់ប្រឹក្សាទទួលបានជោគជ័យដែលជោគជ័យទាំងនេះអាស្រ័យទៅលើទំនាក់ទំនងជឿទុកចិត្តរវាងអតិថិជន និងអ្នកផ្តល់ប្រឹក្សា។

ដើម្បីឱ្យការផ្តល់ប្រឹក្សាបានទទួលជោគជ័យ អតិថិជនត្រូវជឿជាក់លើអ្នកផ្តល់ប្រឹក្សា មិនត្រូវផ្តល់ព័ត៌មានទៅអ្នកដទៃទៀតទេ។

15

## ២. ការសុំអនុញ្ញាតដើម្បីបង្ហាញព័ត៌មាន

ដើម្បីអាចផ្តល់ការថែទាំនិងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍បានល្អត្រឹមត្រូវ បុគ្គលិកសុខាភិបាលដទៃទៀត និងអ្នកគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍ ចាំបាច់ត្រូវដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់អ្នកជម្ងឺ ៖

- ព័ត៌មានសម្ងាត់ អាចឱ្យអ្នកដទៃដឹងបាន លុះត្រាតែ៖
  - មានការអនុញ្ញាតពីអតិថិជន
  - នៅពេលណាដែលព័ត៌មានត្រូវដឹងជាចាំបាច់ដោយបុគ្គលិកដទៃទៀត ដើម្បីផ្តល់ការថែទាំព្យាបាល
- ការសំរេចចិត្តប្រាប់ពីស្ថានភាពរបស់ខ្លួនឱ្យអ្នកដទៃដឹងអាចត្រូវការពេលវេលា
- អ្នកផ្ទុកមេរោគអេដស៍គឺជាអ្នកសំរេចចិត្តក្នុងការបង្ហាញព័ត៌មានឱ្យអ្នកដទៃដឹងមិនមែនអ្នកដទៃផ្សេងទេ។

សូមទុកអ្នកផ្ទុកមេរោគអេដស៍រក្សាការត្រួតពិនិត្យស្ថានភាពរបស់គាត់ដោយខ្លួនឯង។

16

## ៣. ភាពជាឯកជន

ការផ្តល់ប្រឹក្សាជាបុគ្គល ឬជាលក្ខណៈប្តីប្រពន្ធត្រូវធ្វើឡើងនៅក្នុងបន្ទប់ស្ងាត់។

ធ្វើដូច្នេះអ្នកដទៃមិនអាចឮនូវអ្វីដែលគេបានជជែកគ្នាទេ។

17

## ៤. កំណត់ត្រាលាក់ការណ៍

អ្នកផ្តល់ប្រឹក្សាត្រូវរក្សារបាយការណ៏ការងារដែលគាត់បានធ្វើជាមួយអតិថិជន និងចាត់វិធានការរក្សាទុកនូវព័ត៌មានសម្ងាត់ដែលបានទទួលឱ្យបាន ។

- កំណត់ត្រារបស់អតិថិជន ឬឯកសារៈ
  - មិនត្រូវដាក់សញ្ញាសំគាល់ណាមួយដែលបង្ហាញពីស្ថានភាពផ្ទុកមេរោគអេដស៏ទេ
  - ត្រូវរក្សាទុកឱ្យមានសុវត្ថិភាព ដែលគ្មាននរណាផ្សេងទៀតអាចមើលបាន
  - ត្រូវបោះចោលដោយមធ្យោបាយណាមួយដែលមិនធ្វើឱ្យខូរខ្ចាយការសម្ងាត់
- របាយការណ៏ដែលបានមកពីទិន្នន័យ ត្រូវផ្ញើទៅខាងក្រៅមិនត្រូវដាក់ឈ្មោះរបស់អតិថិជនទេ ។

18

## ៥. ការបញ្ជូនសមស្រប

- សេវាថែទាំសុខភាពដល់អ្នកផ្ទុកមេរោគអេដស៏មាននៅភ្នំពេញនិងនៅខេត្ត-ក្រុងមួយចំនួន
- អ្នកជម្ងឺអាចមានការភ័យខ្លាចអ្នកដទៃវិនិច្ឆ័យពីខ្លួន បើសិនជាគាត់ទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៏នៅឯមន្ទីរពេទ្យ ឬទៅចូលរួមការប្រជុំនៅមណ្ឌលមិត្តជួយមិត្ត
- ការបញ្ជូននេះអាចមានការងាយស្រួល បើសិនជាបុគ្គលមើលឃើញពីផលប្រយោជន៏នៃការថែទាំ និងគាំទ្រដែលផ្តល់ឱ្យគាត់តាមរយៈមណ្ឌលមិត្តជួយមិត្ត ។ល ។
- ជួនកាលបុគ្គលសំរេចចិត្តមិនព្រមឱ្យគេបញ្ជូនគាត់ទៅសេវាដែលនៅជិតមូលដ្ឋានរបស់គាត់ទេ ក៏ប៉ុន្តែគាត់ព្រមទទួលយកសេវាដែលនៅឆ្ងាយពីសហគមន៏របស់គាត់ ។

អ្នកផ្តល់ប្រឹក្សាត្រូវផ្តល់ព័ត៌មានច្បាស់លាស់អំពីសេវាដទៃទៀតដែលមាននៅទាំងនៅជិតនិងនៅឆ្ងាយ និងត្រូវធ្វើការបញ្ជូនឱ្យបានសមស្រប ឬគាំទ្របុគ្គលឱ្យទទួលសេវាទាំងនោះដោយខ្លួនឯង ។

19

## សកម្មភាពទី៣: លំហាត់ ( មានជម្រើសពីរ ) : ការរក្សាការសម្ងាត់

**ជម្រើសទី១: ល្បែងដើរតួ**

» គ្រូនឹងស្នើឱ្យអ្នកសំដែង អ្នកដើរតួពិនិត្យជាលំអិតអំពីការរក្សាការសម្ងាត់

» នៅចុងបញ្ចប់នៃលំហាត់នេះ គ្រូនឹងសួរសំណួរដែលមាននៅម្ខាងទៀតនៃប្រអប់នេះ ដើម្បីជួយអ្នកឱ្យគិតអំពីបញ្ហារក្សាការសម្ងាត់ដែលមានបញ្ជាក់នៅក្នុងល្បែងដើរតួ

**សំណួរ**

- តើកន្លែងសម្រាប់ការសន្ទនានេះសមស្របដែរឬទេ?
- តើអ្នកគិតថា "ម៉ារី" មានអារម្មណ៏យ៉ាងដូចម្តេចអំពីទីកន្លែងនេះ និងអំពីភាពស្ងាត់កំបាំងនៃកន្លែងនេះ?
- តើអ្នកនឹងធ្វើឱ្យវាកាន់តែប្រសើរយ៉ាងដូចម្តេចទៅ?
- តើអ្នកណាផ្សេងទៀតនៅក្នុងគ្លីនិកនេះដែលត្រូវបានអនុញ្ញាតឱ្យមើលកំណត់ហេតុរបស់ "ម៉ារី" ?

តើអ្នកពន្យល់រឿងនេះទៅនាង "ម៉ារី" ដោយរបៀបណា?

**សង្ខេប**

- សង្ខេបអំពីអារម្មណ៏របស់អ្នកនៅពេលសំដែង
- តើបញ្ហាលំបាកបំផុតអ្វីខ្លះក្នុងការរក្សាការសម្ងាត់នៅក្នុងគ្លីនិកដែលអ្នកធ្វើការ ?

## អត្ថបទនៃល្បែងដើរតួស្ដីអំពីការរក្សាការសម្ងាត់

| **អត្ថបទល្បែងដើរតួ ស្ដីអំពីការរក្សាការសម្ងាត់** | |
|---|---|
| សេចក្ដីផ្ដើមៈ “ម៉ារី” កំពុងត្រឡប់ទៅកាន់សេវាថែទាំផ្ទៃពោះ ដើម្បីទទួលយកលទ្ធផលធ្វើតេស្តឈាមរកមេរោគអេដស៍របស់នាង។ នាងបានរៀបការអស់រយៈពេល៦ខែហើយ ហើយនាងរំភើបចិត្តនឹងការមានផ្ទៃពោះរបស់នាងណាស់។ នៅគ្លីនិកមានការមមាញឹកខ្លាំងណាស់ ហើយអ្នកផ្ដល់ប្រឹក្សាបានរៀបចំកន្លែងខាងក្រោយបន្ទប់ ដើម្បីអង្គុយនិយាយជាមួយនាង។ | |
| អ្នកផ្ដល់ប្រឹក្សា | ជម្រាបសួរ “ម៉ារី”! ខ្ញុំរីករាយណាស់ដោយឃើញអ្នកមកទាន់តាមការណាត់ជួប។ សូមអញ្ជើញអង្គុយចុះមក។ |
| ម៉ារី | ជម្រាបសួរ អ្នកគ្រូពេទ្យ! ខ្ញុំដូចជាមានការភ័យញាប់ញ័រខ្លាំងណាស់ក្នុងការរង់ចាំមើលលទ្ធផលតេស្តឈាមរបស់ខ្ញុំ។ តើអ្នកគ្រូពេទ្យមានដំណឹងល្អសម្រាប់ខ្ញុំទេ? |
| អ្នកផ្ដល់ប្រឹក្សា | ចាំ “ម៉ារី” តើនាងមានចាំនូវអ្វីដែលពួកយើងបានពិភាក្សាគ្នាកាលពីពេលដែលនាងមកលើកមុនដែរឬទេ? |
| ម៉ារី | ចាំស! អ្នកគ្រូបាននិយាយថានឹងបើកស្រោមសំបុត្រ ហើយប្រាប់លទ្ធផលដល់ខ្ញុំ។ *“ម៉ារី” ក្រឡេកមើលជុំវិញ។ នាងមើលពីកន្លែងដែលនាងអង្គុយទៅកន្លែងរង់ចាំ ឃើញហាក់ដូចជាមានមនុស្សអ៊ូអរណាស់។ អ្នកផ្ដល់ប្រឹក្សាសង្កេតមើល “ម៉ារី” ដែលកំពុងតែសម្លឹងមើលទៅកន្លែងរង់ចាំ។* |
| អ្នកផ្ដល់ប្រឹក្សា | ខ្ញុំចង់ឱ្យពួកយើងមានបន្ទប់ឯកជនមួយដើម្បីអង្គុយជជែកគ្នាណាស់ ម៉ារី។ ក៏ប៉ុន្តែនៅទីនេះកន្លែងមានកំណត់។ ខ្ញុំប្រាកដថាគ្មាននរណាម្នាក់អាចឮពីអ្វីដែលយើងជជែកគ្នានៅទីនេះទេ។ តើនាងចង់ឱ្យខ្ញុំបើកស្រោមសំបុត្រឥឡូវនេះទេ? |
| ម៉ារី | ខ្ញុំគ្រាន់តែចង់ឱ្យអ្នកគ្រូដឹងថា បើលទ្ធផលតេស្តឈាមរបស់ខ្ញុំវិជ្ជមាន ហើយនៅពេលដែលប្ដីរបស់ខ្ញុំដឹង នោះខ្ញុំនឹងមានបញ្ហាធំហើយ។ សូមកុំប្រាប់ខ្ញុំថា លទ្ធផលរបស់ខ្ញុំវិជ្ជមានអី។ |
| អ្នកផ្ដល់ប្រឹក្សា | ឱ្យខ្ញុំសូមទោសណា “ម៉ារី”! លទ្ធផលតេស្តរបស់នាងគឺវិជ្ជមាន ហើយ។ *អ្នកផ្ដល់ប្រឹក្សាឈប់និយាយមួយភ្លែតដើម្បីទុកឱ្យ “ម៉ារី” ពីអ្វីដែលគាត់បាននិយាយ។* |
| អ្នកផ្ដល់ប្រឹក្សា | ខ្ញុំដឹងថាវាពិបាកណាស់សម្រាប់នាង។ ប៉ុន្តែខ្ញុំនៅទីនេះដើម្បីជួយនាងដោះស្រាយរឿងនេះ។ |
| ម៉ារី | ឱ! អ្នកគ្រូពេទ្យ តើខ្ញុំត្រូវធ្វើដូចម្ដេចទៅ? ខ្ញុំនិងប្ដីខ្ញុំមានការរំជួលចិត្តខ្លាំងណាស់។ មុនពេលដែលពួកយើងរៀបការ ខ្ញុំមានសង្សារម្នាក់ហើយខ្ញុំមិនបានការពារខ្លួនគ្រប់ពេលដែលយើងបានរួមភេទ ទេ។ *“ម៉ារី” ចាប់ផ្ដើមយំ។* |
| អ្នកផ្ដល់ប្រឹក្សា | “ម៉ារី”! នាងប្រហែលជាមានអារម្មណ៍រន្ធត់ខ្លាំងណាស់ឥឡូវនេះ។ សូមនាងដឹងថា គ្រប់យ៉ាងដែលនាងបានប្រាប់ខ្ញុំៗនឹងរក្សាទុកយ៉ាងអាថិកំបាំងជាទីបំផុតរួមទាំងលទ្ធផលតេស្តរបស់នាងផង។ តោះ! ឥឡូវនេះយើងពិភាក្សាពីអ្វីដែលនាងត្រូវធ្វើតទៅទៀតក្នុងថ្ងៃនេះ? |

## ជម្រើសទី២: លំហាត់: ស្រោមសំបុត្រលាក់ការ

គ្រូសម្របសម្រួលនឹងពន្យល់ពីលំហាត់រក្សាការសម្ងាត់ដល់អ្នក

## សកម្មភាពទី៤: ការមាក់ងាយនិងរើសអើង : លំហាត់វិភាគពីខ្លួនឯង

» នៅក្នុងលំហាត់នេះ គ្រូនឹងសុំឱ្យសិក្ខាកាមឆ្លុះបញ្ចាំងពីខ្លួនឯងផ្ទាល់ដោយស្មោះត្រង់ ប៉ុន្តែមិនត្រូវឱ្យគេនិយាយពីរឿងផ្ទាល់ខ្លួនប្រាប់ដល់អ្នកណាម្នាក់ឡើយ

» ចូរអ្នកគិតមើលថាគាត់ធ្លាប់:
  - ○ មានការភ័យខ្លាចមិនសមហេតុផលដែរឬទេ
  - ○ អនុវត្តការថែទាំនិងសមស្របដែលឬទេ
  - ○ ប្រើភាសាមាក់ងាយគេដែលឬទេ
  - ○ មានឥរិយាបថបែបរើសអើងដែរឬទេ

» ប្រសិនជាមានចម្លើយមែនចំពោះសំណួរណាមួយ ចូរគិតថាហេតុអ្វីបានជាអ្នកភ័យខ្លាច ឬក៏តើមូលហេតុអ្វីបានជាបណ្តាលឱ្យអ្នកអាចចេញជាសំដី ឬឥរិយាបថមាក់ងាយបែបនេះបាន

» បំផុសគំនិតរកហេតុផលទាំងនេះឱ្យបានទាំងអស់គ្នា

**ចំណាំ:** អ្នកមិនបាច់បញ្ចេញឥរិយាបថរបស់អ្នកឱ្យអ្នកដទៃដឹងទេ គ្រាន់តែបញ្ចេញគំនិត ថាតើហេតុអ្វីបានជាឥរិយាបថទាំងនេះកើតមានឡើង ។

### ហេតុផលដែលអាចនាំឱ្យមានគំនិតមាក់ងាយ ឬស្តែងចេញជាអាកប្បកិរិយារើសអើង

អ្នកផ្តល់ប្រឹក្សាអាចមានគំនិតមាក់ងាយ ឬមានអាកប្បកិរិយារើសអើង ពីព្រោះពួកគេ:

- ខ្វះចំណេះដឹង ឬការយល់ដឹងពីមេរោគអេដស៍-ជម្ងឺអេដស៍
- ធ្លាប់ឮពាក្យចចាមអារាមពីសហគមន៍ ឬពីមិត្តភ័ក្តិអំពីមេរោគអេដស៍-ជម្ងឺអេដស៍ ហើយគិតថាវាប្រហែលជាការពិត
- ធ្វើសកម្មភាពដោយស្វ័យប្រវត្តិដោយគ្មានពិចារណាពីលទ្ធផលដែលអាចកើតមានឡើងដែលទាក់ទងនឹងអាកប្បកិរិយាទាំងនោះ
- ភ័យខ្លាចនូវអ្វីដែលមិត្តភ័ក្តិឬអ្នករួមការងារគិតដល់
- ចង់ដកខ្លួនឱ្យឆ្ងាយមិនឱ្យពាក់ព័ន្ធនឹងមេរោគអេដស៍-ជម្ងឺអេដស៍
- បុគ្គលនោះធ្លាប់មានបទពិសោធន៍ផ្ទាល់ខ្លួនដោយរងនូវការមាក់ងាយដែលគាត់ធ្លាប់ទាក់ទងជាមួយអ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍
- មិនបានដឹងថាឥរិយាបថ ឬភាសាដែលនិយាយចេញមកថាជាការមាក់ងាយ
- ខ្លាចឆ្លងមេរោគអេដស៍

22

## សកម្មភាពទី៥: បំផុសគំនិត: ទស្សនះភ័ន្តច្រឡំទាក់ទងទៅនឹងមេរោគអេដស៍

» គ្រូនឹងស្នើឱ្យអ្នកកំណត់រកទស្សនះភ័ន្តច្រឡំអំពីមេរោគអេដស៍-ជំងឺអេដស៍ដែលអ្នកធ្លាប់ជួបប្រទះចំពោះខ្លួនឯងឬនៅកន្លែងធ្វើការ ។ សូមប្រើសារដែលស្ថិតជាប់គ្នានេះធ្វើជាជំនួយ ប្រសិនចាំបាច់

» ក្រោយពីឆ្លើយចម្លើយរួចហើយ គ្រូនឹងដឹកនាំការពិភាក្សាដែលស្តីអំពីទស្សនះភ័ន្តច្រឡំ

» ត្រូវឱ្យប្រាកដថា តើគំនិតភ័ន្តច្រឡំនោះត្រូវឬខុស ។ បើអ្នកមិនច្បាស់ទេសូមសួរគ្រូ ។

» ប្រើប្រធានបទទាំងនេះដើម្បីជាជំនួយដល់អ្នក ក្នុងការគិតអំពីទស្សនះភ័ន្តច្រឡំដែលមានទំនាក់ទំនងនឹងមេរោគអេដស៍

១. តើមេរោគអេដស៍ជាអ្វីឬតើអ្វីទៅដែលបង្កឱ្យមានមេរោគអេដស៍?

២. ផ្លូវចម្លងនៃមេរោគអេដស៍

៣. អត្ថន័យនៃមេរោគអេដស៍-ជំងឺអេដស៍

៤. ការពាក់ព័ន្ធនៃរោគវិនិច្ឆ័យទៅនឹងមេរោគអេដស៍-ជំងឺអេដស៍

៥. លទ្ធភាពក្នុងការព្យាបាលART ការព្យាបាលជំងឺដទៃទៀត

៦. ការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

## សកម្មភាពទី៦: ធ្វើការជាក្រុម: ការផ្តល់ប្រឹក្សាដល់ក្រុមមនុស្សដែលសង្គមមិនសូវនឹកនាដល់

» គ្រូនឹងចែកសិក្ខាកាមជាក្រុមដែលមានគ្នាពី៤-៥នាក់

» ទោះបីជាមេរោគអេដស៍រាតត្បាតចូលក្នុងចំណោម ប្រជាជនទូទៅក៏ដោយ ក៏មានស្ត្រីផ្ទុកមេរោគអេដស៍ជាច្រើនស្ថិតនៅក្នុងចំណោមក្រុមស្ត្រីដែលសង្គមមិនសូវនឹកនាដល់ ដូចជា ស្ត្រីរកស៊ីផ្លូវភេទ ម្តាយដែលមិនបានរៀបការ យុវវ័យស្ត្រីប្រើប្រាស់គ្រឿងញៀន ។ល។

» ចូរត្រិះរិះពិចារណាដល់គំនិតដែលធ្លាប់គិតទុកជាមុន អំពីស្ត្រីដែលស្ថិតនៅក្នុងក្រុមទាំងនេះ

» ចូលរួមក្នុងការពិភាក្សាដើម្បីរកគំនិតដែលអាចប៉ះពាល់ដល់ការទទួលសេវាផ្តល់ប្រឹក្សាដែលមានគុណភាពខ្ពស់ចំពោះស្ត្រី

## សកម្មភាពទី៧: ធ្វើការជាក្រុម: វិធីសាស្ត្រក្នុងការផ្តល់ប្រឹក្សា

» គ្រូចែកសិក្ខាកាមជា៣ក្រុម:
ក្រុមទី១: ការផ្តល់ប្រឹក្សាជាក្រុម
ក្រុមទី២: ការផ្តល់ប្រឹក្សាជាបុគ្គល
ក្រុមទី៣: ការផ្តល់ប្រឹក្សាជាប្តីប្រពន្ធ

» ចូរពិចារណាលើសំណួរដូចតទៅ:
១. តើការផ្តល់ប្រឹក្សានៅក្នុងស្ថានភាពបែបណាដែល:
សមស្របជាពិសេស?
មិនសមស្រប?
២.តើវិធីផ្តល់ប្រឹក្សាដែលអ្នកធ្វើមានគុណសម្បត្តិយ៉ាងដូចម្តេចខ្លះ?
៣.តើនឹងមានបញ្ហាអ្វីកើតឡើងនៅពេលដែលអ្នកផ្តល់ប្រឹក្សាធ្វើតាមវិធីនោះ?

» សិក្ខាកាមម្នាក់ក្នុងចំណោមក្រុមនីមួយៗ ត្រូវឡើងមកបង្ហាញលទ្ធផលរបស់ក្រុមពួកគេ

### វិធីសាស្ត្រក្នុងការផ្តល់ប្រឹក្សា

ការផ្តល់ប្រឹក្សាអាច:

- ធ្វើជាក្រុម
- ធ្វើជាលក្ខណ:បុគ្គល
- ធ្វើជាលក្ខណ:ប្តីប្រពន្ធ

26

## ការផ្តល់ប្រឹក្សាជាក្រុម

ការផ្តល់ប្រឹក្សាជាក្រុមៈ

- អាចត្រូវបានធ្វើដើម្បីផ្តល់ព័ត៌មាននិងការអប់រំជាមូលដ្ឋានស្តីពីមេរោគអេដស៍-ជម្ងឺអេដស៍ ឬអំពីការចិញ្ចឹមកូន ឬការផ្តល់ព័ត៌មានមុនធ្វើតេស្តឈាមរកមេរោគអេដស៍ ដល់ក្រុមស្ត្រីនិង ដៃគូរបស់គាត់
- ធ្វើឱ្យព័ត៌មានស្តីពីមេរោគអេដស៍-ជម្ងឺអេដស៍ត្រូវបានផ្សព្វផ្សាយដល់គ្រប់ស្រទាប់មនុស្សរួមទាំងសមាជិកគ្រួសារ ឬមិត្តភ័ក្តិ ដែលមិនបានទទួលការផ្តល់ប្រឹក្សាជាបុគ្គល
- ត្រូវសំរបទៅតាមតំរូវការរបស់ក្រុមមនុស្ស
- អាចបន្ថែមជាមួយការប្រឹក្សាជាបុគ្គល បើសិនជាចាំបាច់
- ត្រូវការឱ្យអ្នកផ្តល់ប្រឹក្សាមានចំណេះដឹងនិងជំនាញគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងសំណួរដោយមានទំនុកចិត្ត
- មិនសមស្របក្នុងការរាវរកឥរិយាបថប្រឈមរបស់បុគ្គលទេ។

27

## ការផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល

ការផ្តល់ប្រឹក្សាជាបុគ្គលៈ

- អាចធ្វើបាន បើសិនជាស្ត្រីមិនមានដៃគូ ឬ អវត្តមានដៃគូ
- មានលក្ខណៈសមស្របក្នុងការពិភាក្សាពីឥរិយាបថបុគ្គលនៅពេលវាយតម្លៃពីការប្រឈម ឬនៅពេលផ្តល់ប្រឹក្សាអំពីការកាត់បន្ថយការប្រឈម
- មានលក្ខណៈសាមញ្ញជាងការផ្តល់ប្រឹក្សាជាក្រុមដោយសារតែសន្ទនាជាមួយមនុស្សតែម្នាក់

ឧបសគ្គនៃការផ្តល់ប្រឹក្សាជាបុគ្គលៈ

- ស្ត្រីត្រូវបង្ហាញពីស្ថានភាពផ្ទុកមេរោគអេដស៍ដោយខ្លួនឯងផ្ទាល់ បើសិនជាដៃគូ ឬ សមាជិកគ្រួសារ មិនមកជាមួយនាងទេ
- ស្ត្រីអាចទទួលរងនូវការស្តីបន្ទោសចំពោះការឆ្លងមេរោគអេដស៍របស់នាង
- មិនបានទទួលការគាំទ្រចូលរួមទទួលខុសត្រូវពីដៃគូ ឬពីគ្រួសារ

28

## ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ (១)

ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធគួរតែត្រូវបានលើកទឹកចិត្តនៅពេលណាដែលអាចធ្វើបាន ដោយសារតែវារួមចំណែកក្នុងការៈ

- កាត់បន្ថយការបន្ទោសដោយផ្ទាល់ដល់ស្ត្រីផ្ទុកមេរោគអេដស៍
- ធ្វើឱ្យដៃគូចាប់អារម្មណ៍ដល់តួនាទីរបស់ខ្លួនក្នុងការចម្លងមេរោគអេដស៍
- សង្កត់ធ្ងន់ដល់ការចូលរួមទទួលខុសត្រូវនៃប្តីប្រពន្ធក្នុងការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- កាត់បន្ថយការមាក់ងាយដល់ស្ត្រី។

ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធមានការស្មុគស្មាញជាងការផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល ដោយហេតុតែ អ្នកផ្តល់ប្រឹក្សាត្រូវផ្តោតការសន្ទនាលើប្តីប្រពន្ធទាំងពីរនាក់ និងទៅលើទំនាក់ទំនងដែលគេមានរួមគ្នា។

29

## ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ (២)

ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ ផ្តល់ឱកាសដើម្បីៈ

- លើកទឹកចិត្តដល់ដៃគូជាបុរសក្នុងការអនុវត្តន៍ការរួមភេទដែលមានសុវត្ថិភាពដោយការប្រើប្រាស់ស្រោមអនាម័យនិងកាត់បន្ថយចំនួនដៃគូ
- សង្កត់ធ្ងន់ពីការទទួលខុសត្រូវរបស់បុរសជាដៃគូក្នុងការការពារសុខភាពរបស់ប្រពន្ធគាត់ ឬដៃគូ និងគ្រួសាររបស់គាត់
- អ្នកទាំងពីរបានធ្វើតេស្តនិងកាត់បន្ថយការស្តីបន្ទោសដល់ស្ត្រីក្នុងការឆ្លងមេរោគអេដស៍ដែលអាចកើតមានឡើង
- កំណត់បាននូវលទ្ធផលតេស្តនៃអ្នកទាំងពីរដែលមិនដូចគ្នា (ដៃគូម្នាក់មានលទ្ធផលតេស្តវិជ្ជមាននិងដៃគូម្នាក់ទៀតមានលទ្ធផលតេស្តអវិជ្ជមាន) និងផ្តល់ប្រឹក្សាជាក់លាក់ក្នុងការជួយដៃគូដែលមានលទ្ធផលអវិជ្ជមានឱ្យនៅតែអវិជ្ជមានជានិច្ច។ 30

# ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ (៣)

នៅពេលផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ អ្នកផ្តល់ប្រឹក្សាត្រូវៈ

- បង្កើតទំនាក់ទំនងជាមួយនឹងដៃគូម្នាក់ៗ
- ធានាបាននូវការរក្សាការសម្ងាត់និងការគាំទ្រនៃដៃគូម្នាក់ៗ
- វាយតម្លៃពីការយល់ដឹងនូវបញ្ហារបស់ដៃគូម្នាក់ៗ
- ធ្វើឱ្យគេទាំងពីរនាក់ដឹងថាគំនិតរបស់គាត់ទាំងពីរសុទ្ធតែមានសារៈសំខាន់ទាំងអស់
- ទុកពេលឱ្យដៃគូដែលមានប្រៀបចាប់ផ្តើមបញ្ចេញអារម្មណ៍និងគំនិតរបស់គេមុន តែត្រូវប្រាកដថា អ្នកដែលនៅស្ងៀមអាចមានឱកាសនឹងបញ្ចេញអារម្មណ៍ និងគំនិតផងដែរ
- យកចិត្តទុកដាក់ដល់ការសន្ទនារវាងអ្នកទាំងពីរទាំងកាយវិការនិងពាក្យសំដី
- មិនត្រូវវិនិច្ឆ័យឬកាន់ជើងម្ខាងៗទេ
- រក្សាតម្លៃ ភាពលំអៀង និងជំនឿរបស់អ្នកទៅម្ខាង។ បន្តធ្វើការផ្តល់ប្រឹក្សាជាមួយប្តីប្រពន្ធតាមតួនាទី។

31

# វិធីសាស្ត្រនៃការផ្តល់ប្រឹក្សាផ្សេងៗគ្នា

| វិធីសាស្ត្រផ្តល់ប្រឹក្សា | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| ក្រុម | ■ ផ្តល់ព័ត៌មាននិងការអប់រំដល់មនុស្សជាច្រើននាក់<br>■ ចំណេញពេលវេលានិងធនធានមនុស្ស | ■ អ្នកផ្តល់ប្រឹក្សាត្រូវតែមានសេចក្តីក្លាហាននិយាយទៅកាន់ក្រុម<br>■ តំរូវការបុគ្គលអាចមិនត្រូវបានលើកឡើង |
| បុគ្គល | ■ សមស្រមសំរាប់ការពិភាក្សាពីឥរិយាបថបុគ្គល<br>■ ងាយស្រួលដោយសារមានតែអតិថិជនតែម្នាក់ចូលរួម | ■ ស្ត្រីរងនូវការស្តីបន្ទោសពីការឆ្លងមេរោគអេដស៏<br>■ ការចំហលទ្ធផល ការរួមចំណែកទទួលខុសត្រូវ ឬការសំរេចចិត្តមិនត្រូវបានគាំទ្រ |
| ប្តីប្រពន្ធ | ■ មានការទទួលខុសត្រូវរួមគ្នា<br>■ គាំទ្រការចំហលទ្ធផលតេស្ត<br>■ កាត់បន្ថយការស្តីបន្ទោសនិងការមាក់ងាយ | ■ មានភាពស្មុគស្មាញជាងការផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល |

32

**ម៉ូឌុលទី៨: ចំណុចគន្លឹះ**

- ការផ្តល់ប្រឹក្សាស្តីអំពីមេរោគអេដស៍ មានរួមទាំងការពិភាក្សាបញ្ហាបុគ្គលខ្លាំងក្លា និងប្រធានបទ ដែលជារឿយៗមានការពិបាកឬគួរឱ្យភ័យខ្លាច
- ការលាក់ការសម្ងាត់ គឺជាបញ្ហាសំខាន់នៃការផ្តល់ប្រឹក្សាស្តីអំពីមេរោគអេដស៍-ជំងឺអេដស៍ និងជាបញ្ហាសំខាន់ទាក់ទងនឹងលទ្ធផលតេស្តរកមេរោគអេដស៍
- ការមាក់ងាយនិងរើសអើងទាក់ទងនឹងមេរោគអេដស៍-ជំងឺអេដស៍ នៅតែបន្តរីករាលដាលគ្រប់ទីកន្លែងនៅឡើយ ។ អ្នកផ្តល់ប្រឹក្សាមានតួនាទីយ៉ាងសំខាន់ក្នុងការបកស្រាយបញ្ជាក់ឱ្យច្បាស់អំពីការភ័ន្តច្រឡំទាំងឡាយ និងចូលរួមតស៊ូប្រឆាំងទៅនឹងការមាក់ងាយនិងរើសអើង
- ព័ត៌មានទាក់ទងនឹងមេរោគអេដស៍-ជំងឺអេដស៍ និងព័ត៌មាន អំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ អាចផ្តល់ជាក្រុមដល់អតិថិជននៅក្នុងថ្នាក់អប់រំម្តាយ ឬដល់ម្តាយម្នាក់ៗដែលមកម្នាក់ឯងឬមកជាមួយដៃគូ
- ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធគួរតែបានលើកទឹកចិត្តឱ្យធ្វើនៅពេលណាដែលសមស្រប ។

# ម៉ូឌុលទី៩
## ក្រមសីលធម៌

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. រាយពាក្យគោលការណ៍ណែនាំស្តីអំពីការអនុវត្តន៍ក្រមសីលធម៌

២. ពន្យល់អំពីគោលការណ៍នីមួយៗ

៣. យកគោលការណ៍ក្រមសីលធម៌ ទៅអនុវត្តនៅពេលផ្តល់ប្រឹក្សា

៤. កំណត់បាននូវវិទ្វេគ្រោះ (Dilemma) នៃក្រមសីលធម៌ និងពិភាក្សាអំពីយុទ្ធវិធីដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនោះ



*រយៈពេល:* ***៣ម៉ោង***

## សកម្មភាពទី១: សេចក្តីផ្តើមស្តីអំពីក្រមសីលធម៌នៃការផ្តល់ប្រឹក្សា

### ច្បាប់នៃក្រមសីលធម៌

- ច្បាប់នៃក្រមសីលធម៌មានតួនាទីយ៉ាងសំខាន់ក្នុងការណែនាំជាស្តង់ដារ និង អនុវត្តវិជ្ជាជីវៈ នៃការផ្តល់ប្រឹក្សា និងជួយធានាដល់ការផ្តល់សេវាដល់អតិថិជន
- ច្បាប់នៃក្រមសីលធម៌ គឺជាច្បាប់វិជ្ជាជីវៈមូលដ្ឋានគ្រឹះមួយដែលមានតម្លៃសំរាប់ការផ្តល់ប្រឹក្សា
- អ្នកផ្តល់ប្រឹក្សាត្រូវតែមានចំណេះដឹងពីតម្លៃទាំងនេះ ដើម្បីរក្សាទំនាក់ទំនងជាមួយអតិថិជនក្នុងវិជ្ជាជីវៈ និងមានភាពស្មោះត្រង់ មិនលំអៀង និងមានការគោរពគ្នាទៅវិញទៅមក
- ច្បាប់នៃក្រមសីលធម៌មានគោលការណ៍ណែនាំមួយចំនួន

5

## សកម្មភាពទី២: គោលការណ៍ណែនាំសម្រាប់ការផ្តល់ប្រឹក្សា

### គោលការណ៍ណែនាំសម្រាប់ការផ្តល់ប្រឹក្សា

១. មានសមត្ថភាព
២. មានការអនុញ្ញាតយល់ព្រម
៣. លាក់ការសម្ងាត់
៤. ការទទួលខុសត្រូវ
៥. ប្រកាន់នូវឥរិយាបថប្រព្រឹត្តនិងភាពស្មោះត្រង់នៃបុគ្គល
៦. គោរពសិទ្ធិមនុស្ស

### ១. សមត្ថភាព

អ្នកផ្តល់ប្រឹក្សាៈ

- ត្រូវឱ្យប្រាកដថា បានទទួលការបណ្តុះបណ្តាលនូវជំនាញ និងបច្ចេកទេសនៃការផ្តល់ប្រឹក្សា
- ត្រូវផ្តល់តែសេវា និងប្រើប្រាស់តែជំនាញនិងបច្ចេកទេសណាដែលខ្លួនមានតាមរយៈការបណ្តុះបណ្តាល និងតាមរយៈការអនុវត្តន៏
- ត្រូវធ្វើការបញ្ជូនអតិថិជនឱ្យទៅទទួលសេវានៅកន្លែងផ្សេង ដោយភាពប៉ិនប្រសប់
- ត្រូវតែបានតាមដានត្រួតពិនិត្យជាប្រចាំនូវជំនាញផ្តល់ប្រឹក្សារបស់ខ្លួន និងរក្សាឱ្យបាននូវកំរិត សមត្ថភាពដែលខ្លួនមាន
- ត្រូវទទួលបាននូវការតាមដានជាប្រចាំពីអ្នកអភិបាល

8

## ២. កិច្ចព្រមព្រៀងពីអតិថិជន

- **Consent:**
  គឺជាការព្រមព្រៀងដោយអតិថិជនក្នុងការចូលរួមនៅក្នុងការងារណាមួយ ដូចជា ការស្រាវជ្រាវ ការសិក្សាពីអ្វីមួយ ការធ្វើតេស្ត ឬ ការព្យាបាល ។
- **Informed Consent:** ទាមទារឱ្យមានការផ្តល់ព័ត៌មានពិត ដើម្បីឱ្យអតិថិជនបានយល់ច្បាស់ មុននឹងសំរេចចិត្តចូលរួម ។ ព័ត៌មានទាំងនោះមាន:
  - ទិសដៅ ឬ គោលបំណង
  - ដំណើរការដែលនឹងត្រូវធ្វើ
  - លទ្ធភាព ឬការប្រឈមនឹងការប៉ះពាល់ ឬគ្រោះថ្នាក់របួស
  - តើអតិថិជនត្រូវទាក់ទងមកអ្នកផ្តល់ប្រឹក្សាយ៉ាងដូចម្តេច ប្រសិនបើគាត់ត្រូវការ

9

## ការព្រមព្រៀងទទួលការផ្តល់ប្រឹក្សា ក្រោយពេលទទួលបាននូវព័ត៌មាន (១)

អ្នកផ្តល់ប្រឹក្សា:

- ត្រូវមានការយល់ព្រមពីអតិថិជនជាមុនសិន មុននឹងផ្តល់ប្រឹក្សាធ្វើតេស្តឈាម ឬ ព្យាបាល
- ត្រូវពន្យល់អតិថិជនពីលក្ខណ: និងដំណើរការនៃការផ្តល់ប្រឹក្សា ដូចជា: ពេលវេលា រយ:ពេល ការរក្សាការសម្ងាត់ និងតម្លៃនៃសេវា
- ត្រូវធានាថា អតិថិជនយល់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាម មុនពេលគាត់យល់ព្រមធ្វើតេស្តឈាម ។

10

## ការព្រមព្រៀងក្នុងការធ្វើតេស្តឈាម ក្រោយពេលទទួលបាននូវព័ត៌មាន (២)

អតិថិជនម្នាក់ៗមានសិទ្ធិនឹង:

- ទទួលព័ត៌មានច្បាស់លាស់និងពិតប្រាកដ ស្តីពីការធ្វើតេស្តឈាមរកមេរោគអេដស៍ ។ ដូច្នេះ គេនឹងយល់ពី:
  - -គោលបំណង និងគុណសម្បត្តិនៃការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍
  - -គោលបំណង និងគុណសម្បត្តិនៃសេវាដទៃទៀតដែលគាត់អាចទទួលបាន បើសិនជា គាត់មានផ្ទុកមេរោគអេដស៍
  - -ដំណើរនៃការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម
- បដិសេធការធ្វើតេស្តឈាម ហើយអ្នកផ្តល់ប្រឹក្សាត្រូវផ្តល់សិទ្ធិដល់គាត់
- សំរេចចិត្តក្នុងការធ្វើតេស្តឈាម ដែលការសំរេចចិត្តរបស់គាត់ត្រូវបានគេគោរព ។

**មិនត្រូវបង្ខំនរណាម្នាក់ឱ្យធ្វើតេស្តឈាមរកមេរោគអេដស៍ទេ**

11

## ៣. ការរក្សាការសម្ងាត់

អ្នកផ្តល់ប្រឹក្សានៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- មិនអាចបញ្ចេញព័ត៌មាន រឿងផ្ទាល់ខ្លួនឬព័ត៌មានផ្នែកវេជ្ជសាស្ត្ររបស់អ្នកជម្ងឺ ទៅបុគ្គលិកសុខាភិបាលដទៃទៀត ឬសាច់ញាតិរបស់គាត់ឬមនុស្សទីពទេ និង
- ត្រូវការពារអត្តសញ្ញាណរបស់បុគ្គល ឬមិនត្រូវផ្តល់ព័ត៌មានរបស់អតិថិជនដល់ អ្នកដទៃទេ
- លុះណាតែមានការអនុញ្ញាតពីអតិថិជន ។

* នេះរាប់បញ្ចូលការពិភាក្សាពីករណីនានា នៅពេលចុះអភិបាលការផ្តល់ប្រឹក្សា

12

## ទំនាក់ទំនងនៃការរក្សាការសម្ងាត់

អ្នកផ្តល់ប្រឹក្សាត្រូវចាត់រាល់វិធានការសមស្របក្នុងការទំនាក់ទំនងឱ្យបាន ច្បាស់លាស់ជាមួយអតិថិជន ។ ការរក្សាការសម្ងាត់បានគត់ម៉ត់ល្អ និង មិនបណ្តាលឱ្យមានការយល់ច្រឡំនឹងគ្នាទេ ។

13

## ៤. ការទទួលខុសត្រូវ

អ្នកផ្តល់ប្រឹក្សាត្រូវមានការទទួលខុសត្រូវចំពោះ:

- សមត្ថភាព ប្រសិទ្ធិភាព ការប្រព្រឹត្ត និងសុវត្ថិភាពរបស់ខ្លួនឯងផ្ទាល់
- អ្នកផ្តល់ប្រឹក្សាដទៃទៀត នឹងមានឆន្ទៈក្នុងការកែតំរូវ ឬរាយការណ៍ពីអ្នកដទៃ បើសិនជាឃើញគេធ្វើខុស
- អតិថិជន និងស្ថាប័នដែលខ្លួនធ្វើការ ដើម្បីរក្សាបាននូវការអនុវត្តនីវិជ្ជាជីវៈឱ្យ មានលក្ខណៈស្តង់ដាខ្ពស់
- សហគមន៍ដែលខ្លួនរស់នៅ និងកន្លែងដែលខ្លួនធ្វើការ ។

អតិថិជនត្រូវទទួលខុសត្រូវចំពោះអំពើ និង លទ្ធផលជាយថាហេតុរបស់ខ្លួនឯង ។

14

## ៥.ការប្រព្រឹត្តនិងភាពស្មោះត្រង់នៃបុគ្គល (១)

អ្នកផ្តល់ប្រឹក្សា:

- ត្រូវអនុវត្តការផ្តល់ប្រឹក្សាតាមវិធីម៉្យាងដែលមិនធ្វើឱ្យខូចខាតផលប្រយោជន៍ របស់អតិថិជន ឬធ្វើឱ្យអន្តរាយដល់ការទុកចិត្តជាសាធារណៈដល់សេវាឬអ្នករួម ការងារ
- ត្រូវសំដែងនូវភាពស្មោះត្រង់ យុត្តិធម៌ និងការគោរពដល់អ្នកដទៃ
- ត្រូវរក្សាឱ្យបាននូវការគោរពដល់អតិថិជនដោយ:
  - -មិនធ្វើសកម្មភាពណាដែលទាក់ទាញប្រាក់ពីអតិថិជន ដើម្បីបំពេញសេចក្តីត្រូវ ការរបស់ខ្លួនឯងទេ
  - -មិនត្រូវព្យាយាមរក្សាលំនឹងថវិកា ឬទាញផលប្រយោជន៍ដទៃទៀតក្រៅពី ប្រាក់ខែដែលខ្លួនបានទទួលនោះទេ។

15

## ការប្រព្រឹត្តនិងភាពស្មោះត្រង់នៃបុគ្គល (២)

អ្នកផ្តល់ប្រឹក្សា:

- ជៀសវាងការបំពានលើរាងកាយ ភាពអយុត្តិធម៌ ការរើសអើង ការមាក់ងាយ និងបញ្ចេញការប្រមាថមើលងាយ ។
- មិនត្រូវផ្តល់ប្រឹក្សាទេ បើសិនជា
  - -ស្ថានភាពរាងកាយនិងចិត្តរបស់គាត់មិនប្រក្រតីដោយសារការប្រើគ្រឿងស្រវឹង ឬ គ្រឿងញៀន
  - -ការវិនិច្ឆ័យពីវិជ្ជាជីវៈ និងលទ្ធភាពរបស់គាត់មានភាពមិនប្រក្រតីដោយសារ ហេតុផលណាមួយ ។

16

| ៦. ការគោរពសិទ្ធិមនុស្ស (១) | ការគោរពសិទ្ធិមនុស្ស(២) |
| --- | --- |
| អ្នកផ្តល់ប្រឹក្សា:<br>■ ត្រូវទទួលស្គាល់ និងគោរពសិទ្ធិ ភាពថ្លៃថ្នូរនិងតម្លៃមនុស្សជាមូលដ្ឋាន<br>■ ត្រូវរំពឹងថានឹងផ្តល់សេវាដល់មនុស្សគ្រប់រូប ដោយមិនគិតពី វប្បធម៌ សាសនា តម្លៃ ឬប្រព័ន្ធជំនឿទេ<br>■ ត្រូវធានាថា អតិថិជននឹងមិនមានទទួលរងនូវការឈឺចាប់ ទាំងផ្លូវកាយ និងផ្លូវចិត្ត ទេនៅអំឡុងពេលប្រឹក្សាយោបល់<br>■ ត្រូវខិតខំជំរុញឱ្យអតិថិជនត្រួតពិនិត្យពីជីវិតរបស់គាត់ឱ្យបាន និងគោរពដល់សមត្ថភាព ក្នុងការសំរេចចិត្ត និងផ្លាស់ប្តូររបស់អតិថិជន ដោយយោងទៅតាមជំនឿនិងតម្លៃរបស់គាត់<br>17 | ■ ការផ្តល់ប្រឹក្សា**មិនមែន**ជាការបង្ខំអតិថិជនឱ្យទទួលយកនូវអ្វីដែលមានជាស្តង់ដានៅក្នុងមជ្ឈដ្ឋានដែលគេរស់នៅទេ<br>■ ការផ្តល់ប្រឹក្សា **ជំរុញលើកទឹកចិត្ត**ឱ្យអតិថិជនមើលពីតម្លៃ និង ឥរិយាបថរបស់គាត់ដោយស្មោះត្រង់ និងអាចឱ្យគាត់ធ្វើការសំរេចចិត្តដោយខ្លួនឯងថាតើគាត់ត្រូវផ្លាស់ប្តូរឥរិយាបថយ៉ាងដូចម្តេច ។<br>18 |

## សកម្មភាពទី៣: ករណីសិក្សា

» គោលបំណងនៃលំហាត់នេះ គឺដើម្បីឱ្យអ្នកផ្តល់ប្រឹក្សារកមើលសេណារីយ៉ូនៃការផ្តល់ប្រឹក្សាខ្លះដែលទាក់ទងទៅនឹងក្រមសីលធម៌ដែលមានក្នុងសកម្មភាពខាងដើម

» លើកឧទាហរណ៍ដែលមានស្រដៀងនឹងករណីសិក្សា នៅពេលដែលពិភាក្សាអំពីករណីនោះ

» គ្រូចែកសិក្ខាកាមជា៥ក្រុមនិងចែកករណីសិក្សាទៅឱ្យក្រុមនីមួយៗ

» ចូរអានករណីរបស់ក្រុមខ្លួននិងសរសេរពីក្រមសីលធម៌ផ្សេងៗ

» ឧ: តើការសម្ងាត់ត្រូវបានធ្វើឱ្យលេចឮដល់អ្នកផ្សេងដែរឬទេ? តើមានសំណួរអំពីសមត្ថភាពវិជ្ជាជីវៈដែរឬទេ?

» ប្រសិនជាអ្នកមិនសូវច្បាស់ទេ ចូរមើលស្លាយទី៧-១៨

» អ្នកនឹងធ្វើការពិភាក្សាករណីសិក្សាម្តងមួយក្រុមៗ ដោយកំណត់រកការលំបាកដែលមាននៅក្នុងករណីនីមួយៗ

» នៅចុងបញ្ចប់នៃការពិភាក្សានីមួយៗ គ្រូនឹងបង្ហាញស្លាយសង្ខេបសម្រាប់ករណីសិក្សានីមួយៗ ( ស្លាយទី២០-២៤ )

## ករណីសិក្សាទី១

- អ្នកកំពុងធ្វើការនៅគ្លីនិកមួយនៅទីក្រុងភ្នំពេញ ជាមួយអ្នកផ្តល់ប្រឹក្សាមួយចំនួន
- ថ្មីៗនេះ អ្នកបានសង្កេតឃើញថា បុគ្គលិកម្នាក់ដែលធ្វើការជាមួយអ្នកហាក់ដូចជាបង្ហាញឱ្យអ្នកឃើញថា គាត់មានភាពនឿយហត់ មិនសប្បាយចិត្ត និង រយោលពីការងារ ។
- អ្នកព្យាយាមសួរនាង ថាតើមានបញ្ហាអ្វីកើតឡើង តែនាងហាក់ដូចជាមិនចង់និយាយប្រាប់អ្នក
- អ្នកព្រួយបារម្ភចំពោះនាង និង ចំពោះអតិថិជនរបស់នាង
- តើបញ្ហានោះជាអ្វី?

## ករណីសិក្សាទី២

- "ស្រីហុង" ជាស្ត្រីមានផ្ទៃពោះដំក្មេងម្នាក់ ដែលបានមកទទួលការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាមជាមួយអ្នក។ នាងប្រាប់អ្នកថា ប្តីរបស់នាងបានស្លាប់ដោយសារជំងឺអេដស៍កាលពីឆ្នាំមុន ហើយនាងក៏បានបាត់បង់កូនស្រីតូចម្នាក់កាលពី២ឆ្នាំមុនដែរ
- អ្នកបានចំណាយពេលដ៏យូរក្នុងការប្រឹក្សាជាមួយនាង និងបានផ្តល់ព័ត៌មានដល់នាងអំពីអន្តរាគមន៍នានា ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- នៅពេលដែលអ្នកសួរនាងថា តើនាងមានបំណងធ្វើតេស្តឈាមរកមេរោគអេដស៍ដែរឬទេ? នាងបានឆ្លើយបដិសេធ
- អ្នកមានការខកចិត្តជាខ្លាំងនិងបានប្រាប់នាងថា នាងត្រូវតែធ្វើតេស្តឈាមរកមេរោគអេដស៍ ដើម្បីជាប្រយោជន៍ ក្នុងការការពារកូនដែលនៅក្នុងផ្ទៃរបស់នាង។
- តើនឹងមានបញ្ហាអ្វីខ្លះទាក់ទងទៅនឹងក្រមសីលធម៌?

## ករណីសិក្សាទី៣

- អ្នកបានផ្តល់ប្រឹក្សាអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍ដល់ប្តីប្រពន្ធវ័យក្មេងពីរនាក់
- បុរសជាប្តីបានទទូចសុំទទួលលទ្ធផលតេស្តឈាមដាច់ដោយឡែកពីគ្នា
- លទ្ធផលតេស្តឈាមរបស់ប្តី វិជ្ជមាន។ រីឯលទ្ធផលតេស្តឈាមរបស់ប្រពន្ធ អវិជ្ជមាន
- អ្នកបានពិភាក្សាជាមួយប្តីរបស់អតិថិជន ឱ្យប្រាប់អំពីស្ថានភាពរបស់គាត់ដល់ប្រពន្ធ តែបុរសនោះបានបដិសេធ
- បុរសជាប្តីនោះបាននិយាយទៀតថា គាត់នឹងមិនប្រើស្រោមអនាម័យទេ ពីព្រោះគាត់មិនចេះប្រើវា។
- តើនឹងមានបញ្ហាអ្វីខ្លះទាក់ទងទៅនឹងក្រមសីលធម៌?

## ករណីសិក្សាទី៤

- ថ្មីៗនេះ អ្នកត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅមណ្ឌលសុខភាពមួយនៅខេត្តកំពង់ស្ពឺ
- អ្នកបានធ្វើការជាអ្នកផ្តល់ប្រឹក្សាការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅសេវាពិនិត្យផ្ទៃពោះជាមួយនិងអ្នកផ្តល់ប្រឹក្សា/ឆ្មបម្នាក់ទៀត
- នៅចុងសប្តាហ៍មួយអ្នកបានប្រទះឃើញ សហសេវិករបស់អ្នកចូលរួមក្នុងទិវាសង្គមជាមួយមនុស្សម្នាក់ ដែលអ្នកបានស្គាល់ថាជាអតិថិជនម្នាក់ក្នុងចំណោមអតិថិជនជាច្រើនរបស់គាត់។
- តើនឹងមានបញ្ហាអ្វីខ្លះទាក់ទងទៅនឹងក្រមសីលធម៌?

## ករណីសិក្សាទី៥

- អ្នកផ្តល់ប្រឹក្សាម្នាក់បានផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាមដល់ស្ត្រីក្មេងមានផ្ទៃពោះម្នាក់ដែលជាស្រីរកស៊ីផ្លូវភេទ
- អ្នកផ្តល់ប្រឹក្សាបានប្រាប់ទៅនាងថា សង្គមមិនអាចទទួលយកបានទេនៅពេលដែលនាងរកស៊ីផ្លូវភេទបែបនេះ ហើយព្រមទាំងនិយាយថា ការប្រព្រឹត្តិរបស់នាងគួរឱ្យខ្មាស់អៀនណាស់
- អ្នកផ្តល់ប្រឹក្សាបានឱ្យនាងចេញនិងប្រាប់ស្ត្រីក្មេងនោះថា គាត់មិនអាចជួយនាងបានទេ

តើនឹងមានបញ្ហាអ្វីខ្លះទាក់ទងទៅនឹងក្រមសីលធម៌?

## សកម្មភាពទី៤: ការបំផុសគំនិត: ឧទាហរណ៍ទ្វេគ្រោះនៃក្រមសីលធម៌

**ចំណាំ:** ទ្វេគ្រោះគឺជាស្ថានភាពមួយដែលគ្រប់ជម្រើសទាំងអស់មិនគួរជាទីស្វាគមន៍

- គ្រូនឹងស្នើឱ្យអ្នកគិតអំពីស្ថានភាពនៃការផ្តល់ប្រឹក្សាដែលនៅក្នុងនោះមានទ្វេគ្រោះនៃក្រមសីលធម៌ ឬជម្លោះនៃផលប្រយោជន៍រវាងអតិថិជន និងបុគ្គលម្នាក់ទៀតឬនិងមនុស្សដទៃទៀត
- សូមអ្នកយកបទពិសោធន៍ដែលអ្នកធ្លាប់ធ្វើជាអ្នកផ្តល់ប្រឹក្សាមកពិចារណាចំពោះឧទាហរណ៍ទាំងនេះ

## ទ្វេគ្រោះនៃក្រមសីលធម៌

- ការទទួលខុសត្រូវរបស់អ្នកផ្តល់ប្រឹក្សាចំពោះក្រមសីលធម៌ គឺត្រូវផ្តល់ការថែទាំដល់អតិថិជន។ ក៏ប៉ុន្តែ គាត់ក៏ត្រូវតែមានភារកិច្ចផ្តល់ការថែទាំដល់អ្នកដទៃដែរ
- ទ្វេគ្រោះនៃក្រមសីលធម៌អាចកើតមានឡើងនៅពេលណាដែលមានជំលោះរវាងផលប្រយោជន៍របស់អតិថិជន និងផលប្រយោជន៍របស់សហគមន៍

26

## ឧទាហរណ៍នៃទ្វេគ្រោះនៃក្រមសីលធម៌

- អ្នកផ្ទុកមេរោគអេដស៍ម្នាក់បដិសេធពីការប្រាប់ពីស្ថានភាពរបស់គាត់ទៅដៃគូរបស់ខ្លួនគាត់
- បុគ្គលផ្ទុកមេរោគអេដស៍ម្នាក់បដិសេធកាត់បន្ថយឥរិយាបថដែលប្រឈមខ្ពស់នឹងការឆ្លង
- អ្នកផ្ទុកមេរោគអេដស៍ម្នាក់មិនត្រឡប់មកទទួលលទ្ធផលតេស្ត ឬបដិសេធទទួលលទ្ធផលតេស្ត
- បុគ្គលិកម្នាក់ធ្វើការជាមួយអ្នកមានទំនាក់ទំនងក្រោវិជ្ជាជីវៈជាមួយអតិថិជនម្នាក់

27

## សកម្មភាពទី៥: ធ្វើការជាក្រុម: ដំណោះស្រាយទ្វេគ្រោះនៃក្រមសីលធម៌

» ឥឡូវនេះ គ្រូនឹងចែកអ្នកជាក្រុមដែលមានគ្នាពី៤-៥នាក់ និងចែកឱ្យក្រុមនីមួយៗស្វែងរកដំណោះស្រាយពីការលំបាកនៃទ្វេគ្រោះនៃក្រមសីលធម៌ដែលបានរកឃើញនៅក្នុងសកម្មភាពទី៤

» ចូរពិចារណាលើសេណារីយ៉ូរបស់អ្នក និងសរសេរពីគោលការណ៍នៃក្រមសីលធម៌ទាក់ទងទៅនឹងរឿងរបស់អ្នក និងព្យាយាមរកវិធីដំណោះស្រាយនៅពេលដែលជួបស្ថានការណ៍ទាំងនោះ

» សូមចងចាំថា ករណីសិក្សានីមួយៗមានបញ្ហាពិបាកៗនិងជានិច្ចកាលមិនមានភាពច្បាស់លាស់ទេ ថាតើដំណោះស្រាយមួយណាដែលត្រូវឬមួយណាដែលខុស

» សិក្ខាកាមម្នាក់ៗក្នុងក្រុមនីមួយៗ ត្រូវឡើងមកបង្ហាញពីគំនិតយោបល់របស់ក្រុម

» គ្រូដឹកនាំការពិភាក្សាលើសំណួរដូចតទៅនេះ:

១. តើមានដំណោះស្រាយផ្សេងៗគ្នាអ្វីខ្លះ សម្រាប់ស្ថានភាពនីមួយៗ?

២. តើដំណោះស្រាយនីមួយៗមានគុណសម្បត្តិនិងគុណវិបត្តិអ្វីខ្លះ?

៣. តើអាចមានវិធីដោះស្រាយណាដែលប្រសើរជាងនេះដែរឬទេ?

### ដំណោះស្រាយចំពោះទ្វេគ្រោះនៃក្រមសីលធម៌

អ្នកផ្តល់ប្រឹក្សា:

- ត្រូវទទួលព័ត៌មានឱ្យប្រាប់ច្បាស់លាស់ មានជំនឿលើខ្លួនឯង និងមានជំនាញក្នុងការដោះស្រាយទ្វេគ្រោះនៃក្រមសីលធម៌ដោយមានប្រសិទ្ធិភាព
- ត្រូវបានមើលឃើញថាជាអ្នកប្រកបវិជ្ជាជីវៈមានសមត្ថភាព ដែលចេះពិភាក្សាបញ្ហាដោយចំហ និងមានឥរិយាបថត្រឹមត្រូវ និងមានមេត្តាករុណា ក្នុងការរក្សាការសម្ងាត់ដល់អតិថិជន
- ជូនកាលដឹងខ្លួនថាកំពុងស្ថិតនៅកណ្តាលជំលោះនៃគោលការណ៍ក្រមសីលធម៌
- ត្រូវពិភាក្សាពីស្ថានភាពលំបាកជាមួយប្រធានគ្រប់គ្រងផ្តល់ប្រឹក្សា ឬជាមួយអ្នកផ្តល់ប្រឹក្សា ដែលមានបទពិសោធន៍ណាម្នាក់
- ត្រូវដឹងថា ទោះបីជាក្រោយការពិចារណាបញ្ហាសំខាន់ដោយប្រុងប្រយ័ត្នហើយ ក៏ដោយ ក៏ទ្វេគ្រោះនៃក្រមសីលធម៌ខ្លះ មិនអាចដោះស្រាយដោយងាយស្រួលដែរ ឬដោះស្រាយបានក្នុងបែបផែនមួយដែលមិនជាទីពេញចិត្តទាំងស្រុងទេ ។ 29

**ម៉ូឌុលទី៩: ចំណុចគន្លឹះ**

- ត្រូវណែនាំអ្នកផ្តល់ប្រឹក្សាឱ្យអនុវត្តតាមគោលការណ៍ណែនាំនៃក្រមសីលធម៌
- គោលការណ៍ណែនាំមាន:

  ១. សមត្ថភាព

  ២. ការព្រមព្រៀងក្រោយពីបានទទួលព័ត៌មានត្រឹមត្រូវ

  ៣. ការរក្សាការសម្ងាត់

  ៤. ការប្រព្រឹត្តនិងភាពស្មោះត្រង់របស់បុគ្គល

  ៥. គោរពសិទ្ធិមនុស្ស
- អ្នកផ្តល់ប្រឹក្សាអាចជួបប្រទះនូវស្ថានភាពមួយដែលកើតចេញពីជម្លោះផលប្រយោជន៍រវាងអតិថិជននិងអ្នកដទៃ
- អ្នកផ្តល់ប្រឹក្សាគួរពិគ្រោះជាមួយអ្នកគ្រប់គ្រងរបស់ខ្លួន នៅពេលមានបញ្ហាលំបាក។

# ម៉ូឌុលទី១០
# ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ  សិក្ខាកាមទាំងអស់អាចនឹង:

១. ពន្យល់បានអំពីគោលបំណងនៃការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមរកមេរោគអេដស៍

២. ពិភាក្សាអំពីកត្តាដែលមានឥទ្ធិពលលើអតិថិជនក្នុងការសម្រេចចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍

៣. អធិប្បាយអំពីដំណើរការនៃការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមដល់ស្ត្រីមានផ្ទៃពោះ នៅសេវាថែទាំផ្ទៃពោះ

៤. រាយប្រធានបទសំខាន់ៗដែលត្រូវលើកយកមកនិយាយនៅពេលផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម

៥. ពន្យល់បញ្ហានានាទាក់ទងទៅនឹងការផ្តល់ប្រឹក្សាជាក្រុម ជាបុគ្គល ឬ ដល់ប្តីប្រពន្ធ។



*រយៈពេល:* ***៤ម៉ោង២០នាទី***

# សកម្មភាពទី១: រំលឹកឡើងវិញអំពីការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍

## តើអ្វីទៅជា VCCT សំរាប់ HIV ?

| | |
|---|---|
| **Voluntary** | ការស្ម័គ្រចិត្ត |
| **Confidential** | ការរក្សាការសម្ងាត់ |
| **Counselling** | ការផ្តល់ប្រឹក្សា |
| **Testing** | ការធ្វើតេស្ត |

5

## តើអ្វីជាការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម?

**ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម**

គឺជាការសន្ទនារវាងអតិថិជននិងអ្នកផ្តល់ប្រឹក្សា:

- អនុញ្ញាតឱ្យអតិថិជនធ្វើការសំរេចចិត្តក្រោយពីបានទទួលព័ត៌មានគ្រប់គ្រាន់ថាតើគាត់គួរធ្វើតេស្តឈាមឬក៏មិនគួរ
- ជួយឱ្យអតិថិជនបានត្រៀមខ្លួន ដើម្បីទទួលលទ្ធផលតេស្ត

6

## ហេតុអ្វីបានជា VCCTមានសារៈសំខាន់?

មានអ្នកផ្ទុកមេរោគអេដស៍ជាច្រើនពុំបានដឹងជាមុនថា ខ្លួនគេបានឆ្លងមេរោគអេដស៍ទេ

ការធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្តអាចៈ

- បង្កើនចំណេះនិងការយល់ដឹងស្តីពីមេរោគអេដស៍-ជម្ងឺអេដស៍
- ឱ្យអតិថិជនធ្វើផែនការនិងធ្វើការសំរេចចិត្តដ៏សំខាន់លើជីវិតរបស់គាត់ រួមមានការសំរេចចិត្តក្នុងការធ្វើតេស្តឈាមរកមេរោគអេដស៍
- ផ្តល់ឱកាសសំរាប់ការផ្តល់ប្រឹក្សាដើម្បីបង្ការការឆ្លងមេរោគអេដស៍
- ជួយអតិថិជនឱ្យផ្លាស់ប្តូរឥរិយាបថ ដូចនេះពួកគេអាចការពារនិងថែទាំខ្លួនឯងព្រមទាំងគ្រួសាររបស់ពួកគាត់បាន
- មានតួនាទីជាចំណុចផ្តើមក្នុងការទទួលសេវាថែទាំព្យាបាលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដល់អ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍។

7

## ការផ្តល់ប្រឹក្សាសំរាប់ធ្វើតេស្តឈាមរកមេរោគអេដស៍

អ្នកផ្តល់ប្រឹក្សាត្រូវតែៈ

- មានចំណេះដឹងខ្ពស់ស្តីពីមេរោគអេដស៍-ជម្ងឺអេដស៍ និងជម្ងឺកាមរោគផ្សេងទៀត សុខភាពបន្តពូជ ការអនុវត្តន៏ការរួមភេទប្រកបដោយសុវត្ថិភាព
- អាចជជែកអំពីឥរិយាបថរួមភេទរបស់អតិថិជននិងគ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៏ដែលបណ្តាលមកពីឥរិយាបថនៃការប្រព្រឹត្តិអំពើទាំងនោះ
- មានភាពជឿជាក់និងច្បាស់លាស់នៅពេលនិយាយពីឥរិយាបថនៃការរួមភេទនិងគ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៏ដែលបណ្តាលមកពីឥរិយាបថប្រព្រឹត្តទាំងនោះ
- ចេះធ្វើការប៉ាន់ប្រមាណពីគ្រោះប្រឈម និងពិភាក្សាពីគំនិតកាត់បន្ថយគ្រោះប្រឈម
- អាចជួយអតិថិជនឱ្យចេះរៀបចំផែនការកាត់បន្ថយគ្រោះប្រឈម សំរាប់ខ្លួនគេនិងដៃគូរបស់គេ
- អាចកំណត់បាននូវឧបសគ្គឬការរារាំង និងការជំរុញលើកទឹកចិត្តដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបថ។

8

## សកម្មភាពទី២:  លំហាត់ : ការសម្រេចចិត្តធ្វើតេស្តឈាម

គោលបំណងនៃលំហាត់នេះ គឺដើម្បីពិចារណាលើហេតុផលដែលអ្នកខ្លះជ្រើសរើសការធ្វើតេស្តឈាម និងខ្លះមិនព្រមធ្វើតេស្តឈាម

» ម្ខាងនៃបន្ទប់នឹងត្រូវបានកំណត់ថា: សម្រេចចិត្ត**ធ្វើតេស្តឈាម**រកមេរោគអេដស៍ និងម្ខាងទៀតនៃបន្ទប់ត្រូវបានកំណត់ថា: សម្រេចចិត្ត**មិនធ្វើតេស្តឈាម**

» គ្រូនឹងសុំឱ្យសិក្ខាកាមណាម្នាក់ ឡើងមកពន្យល់អំពីហេតុផលនៃការស្ម័គ្រចិត្តធ្វើតេស្តឈាម និងការមិនព្រមធ្វើតេស្តឈាម

» ប្រសិនជា សិក្ខាកាមណាគាំទ្រការធ្វើតេស្តឈាម ត្រូវឱ្យគាត់មកឈរនៅខាង " **ធ្វើតេស្តឈាម**" ។ ប្រសិនជា មានអ្នកមិនគាំទ្រការធ្វើតេស្តឈាមទេ ត្រូវឱ្យគាត់ទៅឈរនៅខាង " **មិនធ្វើតេស្តឈាម**"

» អ្នកដទៃដែលមានគំនិតស្របជាមួយអ្នក អាចទៅឈរតាមអ្នក។ ប្រសិនជាគេយល់ស្របតាមគំនិតរបស់អ្នកទេ ឬមិនច្បាស់លាស់ទេ គេអាចទៅឈរនៅខាងដែលគេចង់ឈរ

» នៅពេលធ្វើលំហាត់ សិក្ខាកាមអាចទៅពីកន្លែងមួយទៅកន្លែងមួយទៀតបានច្រើនដងទៅតាមការយល់ឃើញរបស់សិក្ខាកាមម្នាក់ៗ

### ការសំរេចចិត្តធ្វើតេស្តឈាម

- មនុស្សម្នាក់ៗតែងតែ មានហេតុផល មានវិធីគិតគូរ មានអារម្មណ៍ និងមានរបៀបដោះស្រាយបញ្ហារបស់គេខុសៗគ្នា
- អ្នកផ្តល់ប្រឹក្សាត្រូវអនុញ្ញាតឱ្យអតិថិជនជាអ្នកសំរេចចិត្តក្នុងការធ្វើតេស្តឈាម:
  - មនុស្សខ្លះ  ក្រោយពីបានសិក្សាពីមេរោគអេដស៍ជាច្រើន ប្រហែលជាសំរេចចិត្តមិនធ្វើតេស្តឈាមទេ ដោយសារតែពួកគេមានអារម្មណ៍ថាមិនបានប្រឈមនឹងការឆ្លង
  - មនុស្សខ្លះដែលមានឥរិយាបថប្រឈមនឹងការឆ្លងខ្ពស់ ក៏ប្រហែលជាសំរេចចិត្តមិនធ្វើតេស្តឈាមដែរ
  - អ្នកខ្លះទៀតប្រហែលជាត្រឡប់មកវិញ នៅក្រោយពេលដែលគេសំរេចចិត្តជាចុងក្រោយចង់ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គេ

10

### ហេតុផលចំពោះការសំរេចចិត្តធ្វើតេស្តឈាម

- ចង់ដឹងពីស្ថានភាពរបស់ខ្លួន ដើម្បីធ្វើគំរោងផែនការសំរាប់ការពារពេលអនាគត
- គិតថាពួកគេកំពុង ឬប្រហែលជាប្រឈមមុខនឹងការឆ្លង
- ចង់រៀបអាពាហ៍ពិពាហ៍
- មានសមាជិកគ្រួសារមានផ្ទុកមេរោគអេដស៍
- ប៉ាន់ទទួលការពិត
- មិនចង់បន្តការព្រួយបារម្ភ
- ជឿថាអ្នកផ្តល់ប្រឹក្សានិងបុគ្គលិកមន្ទីរពិសោធន៍អាចរក្សាការសម្ងាត់បាន
- ចង់ដឹងដើម្បីរៀបផែនការសំរាប់ពេលអនាគតនិងអាចការពារដៃគូនិងកូនរបស់គេក្នុងពេលអនាគតបាន
- បើសិនជាវិជ្ជមាន  មិនចង់ចម្លងមេរោគទៅអ្នកដទៃ
- ចង់ធ្វើអ្វីដែលល្អបំផុតសំរាប់កូនរបស់ពួកគេដែលមិនទាន់កើត

11

### ហេតុផលមិនចង់ធ្វើតេស្តឈាម

មនុស្សម្នាក់អាចសំរេចចិត្តមិនធ្វើតេស្តឈាមរកមេរោគអេដស៍ ពីព្រោះគេគិតថា:

- គ្មានហេតុផលនឹងត្រូវធ្វើតេស្ត  គ្មានឥរិយាបថប្រឈមមុខនឹងការឆ្លង
- ជឿជាក់ថាបើសិនជាលទ្ធផលតេស្តវិជ្ជមាន គេមិនអាចទទួលយកបាននូវលទ្ធផលតេស្តទេ  ប្រហែលជាអាចវង្វេង ឬចង់សំលាប់ខ្លួន
- បើសិនជាលទ្ធផលតេស្តវិជ្ជមាន នឹងមានការពិបាកចិត្ត ដូច្នេះមិនដឹងពីស្ថានភាពវាប្រសើរជាង
- ភ័យខ្លាចថា ការសម្ងាត់នឹងត្រូវបានបង្ហាញ
- មិនអាចទទួលយកវាបាន  សង្គមមិនទទួលស្គាល់
- ភ័យខ្លាចថាដៃគូ និងសាច់ញាតិដឹងរឿងរបស់ខ្លួន
- ខ្លាចមានអំពើហឹង្សាក្នុងគ្រួសារ

12

## សកម្មភាពទី៣: ល្បែងបំផុសគំនិត: ការផ្ដល់ព័តិមានមុនពេលធ្វើតេស្តឈាម

» គោលបំណងនៃលំហាត់នេះ គឺដើម្បីរំលឹកឡើងវិញអំពីចំណេះដឹងរបស់សិក្ខាកាម ស្ដីអំពីមេរោគអេដស៍-ជំងឺអេដស៍ និងការធ្វើតេស្តឈាមក្នុងការត្រៀមផ្ដល់សេវាប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍

» គ្រូនឹងឱ្យសិក្ខាកាមឈរនៅម្ខាងនៃបន្ទប់ និងសួរសំណួរស្ដីអំពីព័តិមានមុនពេលធ្វើតេស្តឈាម ដែលត្រូវនិយាយនៅពេលផ្ដល់ប្រឹក្សាមុនធ្វើតេស្តឈាម

» ប្រសិនជាអ្នកឆ្លើយត្រូវនឹងសំណួរ អ្នកនឹងត្រូវទៅឈរនៅម្ខាងទៀតនៃបន្ទប់

» នៅពេលសិក្ខាកាមឆ្លើយសំណួរទីមួយត្រឹមត្រូវហើយ ចូរឆ្លើយនឹងសំណួរភាគ២

» នៅពេលនេះ នៅពេលដែលឆ្លើយសំណួរត្រូវហើយ អ្នកត្រូវត្រឡប់មកឈរនៅកន្លែងដើមវិញ។

### គោលបំណងនៃការផ្ដល់ព័ត៌មានមុនពេលធ្វើតេស្តឈាម

ការផ្ដល់ព័តិមានមុនពេលធ្វើតេស្តឈាម :

- ជាព័តិមានមូលដ្ឋានស្ដីពីមេរោគអេដស៍-ជម្ងឺអេដស៍
- ជួយឱ្យស្ត្រីនិងដៃគូយល់ពីដំណើរការនៃការផ្ដល់ប្រឹក្សានិងធ្វើតេស្តឈាម

ព័តិមានមុនពេលធ្វើតេស្តឈាមអាចផ្ដល់ជូនដល់ស្ត្រីមានផ្ទៃពោះ ក្នុងលក្ខណៈជាក្រុម នៅក្នុងកំឡុងពេលផ្ដល់ការអប់រំសុខភាពដល់ស្ត្រីមានផ្ទៃពោះ ឬក្នុងលក្ខណៈជាបុគ្គលម្នាក់ៗឬរួមជាមួយដៃគូរបស់ស្ត្រី។

14

### ការផ្ដល់ព័ត៌មានមុនពេលធ្វើតេស្តឈាម (១)

រំលឹកឡើងវិញពីចំណេះដឹងស្ដីពីមេរោគអេដស៍-ជម្ងឺអេដស៍

១. តើ HIV និង AIDS ខុសគ្នាយ៉ាងដូចម្ដេចខ្លះ?
២. តើអ្នកអាចឆ្លងមេរោគអេដស៍តាមរបៀបណា?
៣. តើឥរិយាបថបែបណាខ្លះដែលប្រឈមខ្ពស់បំផុតទៅនឹងការឆ្លងមេរោគអេដស៍?
៤. តើអ្នកអាចបង្ការមិនឱ្យឆ្លងមេរោគអេដស៍បានយ៉ាងដូចម្ដេច?
៥. តើអ្នកអាចកាត់បន្ថយគ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៍របស់អ្នកបានយ៉ាងដូចម្ដេច?
៦. តើទារកឆ្លងមេរោគអេដស៍ពីម្ដាយរបស់គេតាមរបៀបណា?
៧. តើអ្វីទៅដែលហៅថា PMTCT ?
៨. តើមានសេវាថែទាំនិងគាំទ្រអ្វីខ្លះសំរាប់អ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍?

15

### ការផ្ដល់ព័ត៌មានមុនពេលធ្វើតេស្តឈាម (២)

ការធ្វើតេស្តឈាម:

១. តើគេធ្វើតេស្តឈាមយ៉ាងដូចម្ដេច?

២. តើការធ្វើតេស្តឈាមមានគុណសម្បត្តិអ្វីខ្លះ?

៣. តើការធ្វើតេស្តឈាមមានគុណវិបត្តិអ្វីខ្លះ?

៤. តើលទ្ធផលតេស្តមានន័យយ៉ាងដូចម្ដេច?

៥. តើអ្នកណាខ្លះអាចដឹងព័តិមានពីលទ្ធផលតេស្តរបស់អ្នកបាន?

៦. តើការផ្ដល់ប្រឹក្សាទាំងប្ដីប្រពន្ធមានផលប្រយោជន៍អ្វីខ្លះ?

16

## សកម្មភាពទី៤: ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម ដោយប្រើសៀវភៅរូបភាពមុនពេលធ្វើតេស្តឈាមនៅសេវាថែទាំផ្ទៃពោះ

» សៀវភៅរូបភាពត្រូវបានរៀបរៀងឡើង ដើម្បីជួយសម្រួលដល់ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម

» អ្នកនឹងមានឱកាសអនុវត្តការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមនៅក្នុងសកម្មភាពបន្ទាប់

### សៀវភៅរូបភាពមុនពេលធ្វើតេស្តឈាមនៅសេវាថែទាំផ្ទៃពោះ

សៀវភៅរូបភាពមុនពេលធ្វើតេស្តឈាមនៅសេវាថែទាំផ្ទៃពោះ អាចប្រើសំរាប់:

- ការផ្តល់ប្រឹក្សាជាក្រុម:
  មានក្រុមស្ត្រីមានផ្ទៃពោះនិងដៃគូរបស់គាត់នៅបន្ទប់អប់រំម្តាយ
- ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ ឬជាលក្ខណៈបុគ្គល:
  មានស្ត្រីមានផ្ទៃពោះតែម្នាក់ឯង ឬស្ត្រីមានផ្ទៃពោះជាមួយដៃគូរបស់គាត់

18

### បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម (១)

**រាល់វគ្គផ្តល់ប្រឹក្សាទាំងអស់ (ជាក្រុមឬបុគ្គល)**

សៀវភៅរូបភាពនេះគួរប្រើប្រាស់សំរាប់ជាជំនួយសំរាប់ប្រធានបទ ដូចតទៅនេះ:

១. ព័ត៌មានជាមូលដ្ឋានស្តីពីមេរោគអេដស៍- ជម្ងឺអេដស៍
២. វាយតម្លៃពីការយល់ដឹងស្តីពីមេរោគអេដស៍-ជម្ងឺអេដស៍
៣. គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើតេស្តឈាម
៤. ដំណើរការនៃការធ្វើតេស្តឈាមរកមេរោគអេដស៍
៥. ការរក្សាការសម្ងាត់
៦. អត្ថន័យ និង ការពាក់ព័ន្ធនៃលទ្ធផលតេស្ត វិជ្ជមាន និង អវិជ្ជមាន
៧ ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដល់ដៃគូ
៨. វិធីបង្ការការចម្លងមេរោគអេដស៍រវាងដៃគូ
៩. វិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
១០. កំណត់រកសេវាថែទាំនិងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍

19

### បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម (២)

**ការផ្តល់ប្រឹក្សាជាក្រុម:**

បើសិនជានៅបន្ទប់អប់រំម្តាយ ត្រូវផ្តល់ព័ត៌មានថា :

- ការធ្វើតេស្តឈាមនឹងផ្តល់ជូនគាត់ ព្រោះវាជាផ្នែកមួយនៃការផ្តល់សេវាជាប្រចាំនៅសេវាថែទាំផ្ទៃពោះ
- បើសិនជាស្ត្រីចង់បានព័ត៌មានបន្ថែមទៀត ឬក៏ចង់ឱ្យដៃគូមកចូលរួមទទួលការផ្តល់ប្រឹក្សា គាត់អាចនិយាយប្រាប់បុគ្គលិកសុខាភិបាល
- បើសិនជាស្ត្រីមិនចង់ធ្វើតេស្តឈាមរកមេរោគអេដស៍ទេ គាត់ត្រូវនិយាយប្រាប់បុគ្គលិកសុខាភិបាល

20

## បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម (៣)

**ការផ្តល់ប្រឹក្សាជាបុគ្គលៈ**

បើសិនជាការផ្តល់ប្រឹក្សាជាបុគ្គល ព័តិមានដែលត្រូវលើកមកនិយាយមាន :

- ការប៉ាន់ប្រមាណពីការប្រឈមនឹងការឆ្លងមេរោគអេដស៍និងជម្ងឺកាមរោគដទៃទៀត
- ផែនការកាត់បន្ថយគ្រោះប្រឈមនៃការឆ្លង
- រាវរកជំរើសផ្សេងៗដើម្បីបង្ហាញពីស្ថានភាពឱ្យគេដឹង

- ■ ទទួលការព្រមព្រៀងពីអតិថិជន និងធ្វើតេស្តឈាម
- ■ ពិចារណាពីតំរូវការសំរាប់ធ្វើការផ្តល់ប្រឹក្សាបន្ថែមទៀត

21

## បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម (៤)

**ការផ្តល់ប្រឹក្សាជាក្រុមៈ**

បើសិនជា ផ្តល់ការប្រឹក្សាជាក្រុម ព័តិមានដែលត្រូវលើកមកនិយាយមាន :

- ■ ការប៉ាន់ប្រមាណពីការប្រឈមនឹងការឆ្លងមេរោគអេដស៍និងជម្ងឺកាមរោគដទៃទៀត
- ■ ផែនការកាត់បន្ថយគ្រោះប្រឈមនៃការឆ្លងសំរាប់ដៃគូទាំងពីរ
- ■ ពន្យល់ពី **លទ្ធផលតេស្តមិនស្របគ្នា** និងប្រាប់ឱ្យដៃគូទាំងពីរត្រៀមខ្លួនជាស្រេច ចំពោះបញ្ហាដែលនឹងអាចកើតមានឡើងនេះ
- ■ សួរអតិថិជន ថាតើគាត់ចង់ទទួលលទ្ធផលតេស្ត**ដោយឡែកពីគ្នា ឬជាមួយគ្នា**
- ■ ទទួលការព្រមព្រៀងពីដៃគូម្នាក់ៗ (ដាក់លេខកូដដោយឡែកពីគ្នា) និងធ្វើតេស្តឈាម
- ■ ពិចារណាពីតំរូវការសំរាប់ធ្វើការផ្តល់ប្រឹក្សាបន្ថែមទៀត

22

## លទ្ធផលតេស្តមិនស្របគ្នា

ប្តីប្រពន្ធដែលមានលទ្ធផលតេស្តមិនស្របគ្នា គឺជាប្តីប្រពន្ធដែលៈ

- ■ ដៃគូម្ខាងមានលទ្ធផលតេស្ត HIV វិជ្ជមាន
- ■ ដៃគូម្ខាងមានលទ្ធផលតេស្ត HIV អវិជ្ជមាន

នេះប្រហែលជាបណ្តាលមកពីៈ

១. ដៃគូដែលមានលទ្ធផលតេស្តអវិជ្ជមាន ទើបនឹងឆ្លងមេរោគអេដស៍នៅពេលថ្មីៗបំផុត ហើយកំពុងស្ថិតនៅក្នុងរយៈពេលចំហ ដូចនេះហើយបានជាលទ្ធផលតេស្តអវិជ្ជមាន

២. ដៃគូដែលមានលទ្ធផលតេស្តអវិជ្ជមាន មិនទាន់ឆ្លងមេរោគអេដស៍ពីដៃគូរបស់គាត់ដែលមានផ្ទុកមេរោគអេដស៍នៅឡើយ

23

## ការសំរេចចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍

ត្រូវផ្តល់សិទ្ធិឱ្យអតិថិជនជាអ្នកសំរេចចិត្តធ្វើតេស្តឈាមដោយគ្មានការបង្ខិតបង្ខំ

- ■ បើសិនជាអតិថិជនសំរេចចិត្តធ្វើតេស្តឈាម ត្រូវប្រាប់អតិថិជនពីពេលវេលាដែលត្រូវមកទទួលលទ្ធផល និងត្រូវរៀបចំសម្រាប់ធ្វើការបូមឈាម
- ■ បើសិនជាអតិថិជនសំរេចចិត្តមិនព្រមធ្វើតេស្តឈាមទេ ហើយគាត់ទំនងជាកំពុងស្ថិតនៅក្នុងស្ថានភាពមួយដែលប្រឈមនឹងការឆ្លងមេរោគអេដស៍ អ្នកផ្តល់ប្រឹក្សាត្រូវពិភាក្សាជាមួយអតិថិជន ពីគំរោងកាត់បន្ថយគ្រោះប្រឈមឱ្យបានល្អិតល្អន់។

ការដែលស្ត្រីសំរេចចិត្តមិនធ្វើតេស្តឈាមរកមេរោគអេដស៍
មិនត្រូវឱ្យមានផលប៉ះពាល់ដល់ការទទួលសេវាថៃទាំផ្ទៃពោះរបស់គាត់ទេ។

24

## សកម្មភាពទី៥: ល្បែងដើរតួ: ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម ដោយប្រើសៀវភៅរូបភាពមុនពេលធ្វើតេស្តឈាមនៅសេវាថែទាំផ្ទៃពោះ

### ការត្រៀមរៀបចំ

ចូរអានជំនាញជាមូលដ្ឋានក្នុងការបង្ហាញសៀវភៅរូបភាព និងជំនាញក្នុងការសម្របសម្រួលជាក្រុម ដើម្បីឱ្យខ្លួនអ្នកថ្នឹកក្នុងការប្រើប្រាស់វាជាមុន

រំលឹកឡើងវិញអំពីតួនាទីរបស់អតិថិជន សម្រាប់មុនពេលធ្វើតេស្តឈាមជាក្រុម

### សង្ខេបសកម្មភាព

» គោលបំណងនៃសកម្មភាពនេះ គឺដើម្បីអនុវត្តជំនាញផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម និងដឹងអំពីរបៀបប្រើសៀវភៅរូបភាព

» សៀវភៅរូបភាពអាចប្រើសម្រាប់ផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមជាក្រុម ផ្តល់ប្រឹក្សាដល់បុគ្គលនិងប្តីប្រពន្ធ ។ ក្នុងសកម្មភាពនេះអ្នកនឹងអនុវត្តវិធីទាំងអស់នេះ

» សិក្ខាកាមទាំងអស់នឹងដើរតួសំដែងគ្រប់ៗគ្នា ហើយម្នាក់ៗត្រូវសំដែងជា "អ្នកផ្តល់ប្រឹក្សា " និង "អតិថិជន" យ៉ាងហោចក៏ឱ្យបានម្តងដែរ ។

| **ជំនាញជាមូលដ្ឋានក្នុងការបង្ហាញសៀវភៅរូបភាពជាមូលដ្ឋាន**<br>សម្រាប់ឱ្យអ្នកសម្របសម្រួលប្រើប្រាស់នៅពេលបណ្តុះបណ្តាល និងសម្រាប់ឱ្យអ្នកផ្តល់ប្រឹក្សាប្រើនៅកន្លែងធ្វើការ |
| --- |
| **ការត្រៀមរៀបចំ** |
| ■ រំលឹកឡើងវិញពីសៀវភៅរូបភាពជាមុន ។ ត្រូវដឹងឱ្យច្បាស់អំពីសម្ភារៈ និងមានអារម្មណ៍មិនភ័យព្រួយនឹងនិយាយអំពីវានៅចំពោះមុខក្រុមមនុស្សទាំងអស់<br>■ ចូរគិតអំពីនរណាម្នាក់ដែលអ្នកនឹងត្រូវនិយាយទៅរក ធ្វើដូច្នេះអ្នកនឹងអាចធ្វើការបង្ហាញបានល្អ<br>■ រៀបចំនិងពិនិត្យសម្ភារៈសម្រាប់បង្ហាញរបស់អ្នកមុនពេលបង្រៀន ដោយប្រាកដថាមានឯកសារគ្រប់គ្រាន់សម្រាប់ចែកឱ្យសិស្ស<br>■ រៀបចំបន្ទប់ឱ្យមានកន្លែងអង្គុយគ្រប់គ្រាន់ ហើយសិក្ខាកាមអាចមើលឃើញអ្នកនិងសៀវភៅរូបភាពបានច្បាស់ |
| **ការធ្វើចលនា** |
| ■ ចាប់ផ្តើមដោយឈរនៅចំពីមុខនិងបែរមុខទៅរកសិក្ខាកាម<br>■ ត្រូវធ្វើចលនានៅពេលបង្ហាញ ។ ខិតទៅជិតអតិថិជនដើម្បីឱ្យគាត់យកចិត្តទុកដាក់ស្តាប់អ្នកនិយាយ និងលើកទឹកចិត្តពួកគាត់ឱ្យឆ្លើយនឹងសំណួរ<br>■ សម្លឹងយ៉ាងយកចិត្តទុកដាក់ទៅរកអតិថិជន<br>■ ប្រើកាយវិការពីធម្មជាតិនិងបង្ហាញទឹកមុខឱ្យបានសមស្របនៅពេលបង្រៀន ។ ព្យាយាមសរមួលឥរិយាបថនិងត្រូវមានទំនុកចិត្តលើខ្លួនឯង |

| ការនិយាយ |
| --- |
| ■ និយាយមួយៗតែពួច្បាស់ ដាស់អារម្មណ៏អ្នកស្ដាប់ឱ្យបានឮគ្រប់ៗគ្នា<br>■ ប្រើពាក្យសាមញ្ញនិងសមស្រប |
| **មាតិកា** |
| ■ ធ្វើការផ្ដល់ប្រឹក្សាតាមសៀវភៅរូបភាពដោយប្រាកដថា អ្នកបាននិយាយអស់នូវចំណុចសំខាន់ៗ<br>■ និយាយរឿងនិងធ្វើការប្រៀបធៀប ដើម្បីពន្យល់អំពីគំនិតខ្លះៗដែលស្មុគស្មាញ<br>■ លើកទឹកចិត្តសិក្ខាកាមឱ្យសួរសំណួរនិងមានយោបល់<br>■ កំណត់ពេលវេលាឱ្យបាន។ មិនត្រូវបង្ខំឱ្យចប់ឆាប់ពេក ឬបន្ទាយពេលវេលាយូរពេកចំពោះគំនិតណាមួយទេ<br>■ ត្រូវនិយាយសង្ខេបនូវសារៈសំខាន់ៗនៅពេលបញ្ចប់វគ្គនីមួយៗ<br>■ ត្រូវឆ្លើយនឹងសំណួរឱ្យបានត្រឹមត្រូវ។ ប្រសិនជាអ្នកមិនដឹងចម្លើយ ត្រូវនិយាយប្រាប់គេថាអ្នកមិនដឹងទេ ឬបង្វិលសំណួរទៅឱ្យអ្នករួមការងារជាមួយ |

| |
|---|
| **ជំនាញសម្របសម្រួលក្រុមៈ** ជ្រើសរើសអ្នកធ្វើរបាយការណ៍ម្នាក់ក្នុងចំណោមសមាជិកទាំងអស់ ។ លើកទឹកចិត្តឱ្យមានការពិភាក្សាផុលផុសក្នុងចំណោមក្រុម និងលើកទឹកចិត្តសិក្ខាកាម ឬអតិថិជនឱ្យផ្លាស់ប្តូរបទពិសោធន៍ពីគ្នាទៅវិញទៅមក |
| **អ្នកសម្របសម្រួលត្រូវ**<br>■ ប្រើសំណួរបើក<br>■ រៀបចំបទបញ្ជានៅពេលដំបូងនៃវគ្គ ។ ឧទាហរណ៍<br>  ■ យើងនឹងលើកដៃឡើងដើម្បីសួរសំណួរឬមានយោបល់<br>  ■ យើងនឹងប្រើពាក្យសំដីដែលគោរពដល់អ្នកដទៃ<br>  ■ យើងនឹងនិយាយក្នុង១ពេលឱ្យបានម្តង និងជៀសវាងខ្សិបខ្សៀវគ្នាឬការសន្ទនាដោយឡែក<br>  ■ យើងនឹងការពារការសម្ងាត់គ្នាទៅវិញទៅមក<br>■ យកចិត្តទុកដាក់ដល់អ្វីដែលអតិថិជនបាននិយាយ និងអំពីរបៀបនិយាយរបស់គាត់<br>■ យកអាក្បកិរិយាមិនវិនិច្ឆ័យអ្នកដទៃ មកអនុវត្តចំពោះសមាជិកក្រុម<br>■ ធានាថា គ្រប់អតិថិជនបានចូលរួមមានមតិទាំងអស់គ្នា ទោះជាគាត់អៀនខ្មាស់ក៏ដោយ<br>■ ត្រូវចេះដោះស្រាយជាមួយអតិថិជនដែលមាននិន្នាការបំពានលើអ្នកដទៃ |
| **បច្ចេកទេសគ្រប់គ្រងអតិថិជនដែលនិយាយច្រើន** |
| ប្រសិនជាមាននរណាម្នាក់និយាយយកឈ្នះតែម្នាក់ឯងនៅក្នុងការពិភាក្សាៈ<br>■ ត្រូវកោតសរសើរដល់គាត់និងអរគុណដល់គាត់ ដែលបានចូលរួមចំណែកក្នុងការពិភាក្សានិងចែកចាយបទពិសោធន៍របស់គាត់ដល់ក្រុម ក៏ប៉ុន្តែត្រូវនិយាយថា "តើខ្ញុំអាចឱ្យអ្នកដទៃទៀតនិយាយផងដែរបានឬទេ?"<br>■ ប្រសិនជាអ្នកនិយាយច្រើននោះទំនងជាអ្នកផ្តល់ប្រឹក្សាធម្មតាទេ  សូមស្នើគាត់ឱ្យជួយចែកខិត្តប័ណ្ណដោយចែកចាយបទពិសោធន៍របស់គាត់ឬឱ្យគាត់ឆ្លើយនូវសំណួរខ្លះដែលលំបាក ។<br><br>ប្រសិនជាមនុស្សនៅក្នុងក្រុមជជែកគ្នាៈ<br>■ ត្រូវនិយាយតិចៗ ធ្វើដូច្នេះពួកគាត់នឹងឈប់ជជែកគ្នាដើម្បីងាកមកស្តាប់អ្នកវិញ<br>■ ត្រូវដើរទៅឱ្យជិតអ្នកនិយាយគ្នា<br>■ ស្នើឱ្យអ្នកជជែកគ្នាចែករំលែកនូវបទពិសោធន៍របស់គាត់ជាមួយក្រុមទាំងមូល |

**បច្ចេកទេសដើម្បីបង្កើនការចូលរួម**

- ប្រើប្រាស់សំណួរនិងចម្លើយនិងពិភាក្សាជាក្រុម
- ទុកពេលឱ្យបានគ្រប់គ្រាន់ដល់ក្រុមដើម្បីឆ្លើយនឹងសំណួរ ។ ត្រូវនៅឱ្យស្ងៀមដើម្បីអតិថិជនមានសេចក្តីក្លាហាននឹងឆ្លើយតប
- ផ្តល់ការឆ្លើយតបប្រកបដោយការលើកទឹកចិត្តទៅដល់អតិថិជនដែលបានឆ្លើយតបនឹងសំណួរ ។ ត្រូវប្រុងប្រយ័ត្នក្នុងការកែចម្លើយដែលខុស ។ ឧ៖ ត្រូវចាប់ផ្តើមការឆ្លើយតបវិញដោយ " មានមនុស្សជាច្រើនគិតថាដូច្នោះ ក៏ប៉ុន្តែ ..."
- ទាញការសន្ទនារបស់អតិថិជនមករកប្រធានបទវិញ នៅពេលដែលគាត់ចេញផុតពីចំណុចដែលត្រូវនិយាយ
- ព្យាយាមធ្វើយ៉ាងណាឱ្យអតិថិជនទាំងអស់ចូលរួមពិភាក្សា ។ នៅពេលមានមនុស្ស២-៣នាក់ហាក់ដូចជានិយាយច្រើនជាងគេក្នុងពេលពិភាក្សា ត្រូវសួរទៅក្រុមថា តើមាននរណាផ្សេងទៀតចង់មានយោបល់អ្វីដែរ

**បច្ចេកទេសបន្ថែមសម្រាប់គ្រប់គ្រងអតិថិជនដែលពិបាក**

- ធ្វើមិនដឹងមិនឮពីឥរិយាបថលំបាករបស់អតថិជន ចាប់តាំងពីនៅពេលចាប់ផ្តើមវគ្គ ។ ប្រសិនជាគាត់នៅតែមានឥរិយាបថបែបនោះទៀត អ្នកត្រូវប្រឈមជាមួយនឹងអតិថិជននោះវិញ
- និយាយដោយស្ងាត់ស្ងៀមជាមួយអតិថិជនដែលលំបាកនោះ ដើម្បីពន្យល់ហេតុផលដល់គាត់ថា ឥរិយាបថរបស់គាត់អាចមានផលប៉ះពាល់ដល់ក្រុមទាំងអស់ ។ ត្រូវរាវរកមើលពីហេតុផលនៃការរំខាននោះ និងស្នើឱ្យគាត់បញ្ឈប់សកម្មភាពទាំងនោះ
- ប្រសិនជាឥរិយាបថនោះល្មើសនឹងបទបញ្ជាមូលដ្ឋាន ត្រូវរំលឹកដល់ក្រុមពីបទបញ្ជានោះ ដើម្បីបង្ហាញថាឥរិយាបថនោះមិនសមស្របទេ

| | |
|---|---|
| **សកម្មភាព ភាគទី១**<br><br>ការផ្តល់ប្រឹក្សាជាក្រុម<br>៣០នាទី | ■ គ្រូត្រូវបង្ហាញអំពីរបៀបធ្វើការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមជាក្រុម ដោយប្រើសៀវភៅរូបភាព<br>■ សិក្ខាកាមត្រូវធ្វើហាក់ដូចជាអតិថិជននៅក្នុងសេវាថែទាំផ្ទៃពោះដែលកំពុងតែមមាញឹក<br>■ គ្រូចែកក្រដាសថតចម្លងនិយាយអំពីតួនាទីរបស់អតិថិជន ដល់សិក្ខាកាមសម្រាប់ធ្វើការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម និងស្នើសុំឱ្យមានអ្នកស្ម័គ្រចិត្តដើរតួនីមួយៗ (សូមមើលនៅខាងក្រោមនេះ រំលឹកឡើងវិញអំពីតួនាទីមុនពេលសំដែង ធ្វើដូច្នេះអ្នកអាចត្រៀមខ្លួនដើម្បីឆ្លើយតបបានសមស្រប)<br>■ សូមដើរតួជាអតិថិជន ដោយសំដែងហាក់ដូចជាខ្លួនកំពុងតែស្ថិតនៅក្នុងសេវាថែទាំផ្ទៃពោះតែម្តង។ មិនត្រូវបញ្ឈប់សកម្មភាពនៅពាក់កណ្តាលទីទេ។<br>■ នៅពេលដែលធ្វើការបង្ហាញរួចហើយ ត្រូវសង្ខេបខ្លីៗដូចខាងក្រោមនេះ |
| **សកម្មភាព ភាគទី២**<br><br>ការផ្តល់ប្រឹក្សាជាបុគ្គល និងដល់ប្តីប្រពន្ធ<br>៩០នាទី | ■ គ្រូចែកសិក្ខាកាមជាក្រុមមានគ្នាពី៤-៥នាក់<br>■ ត្រូវប្រាកដថាក្រុមអ្នកមានសៀវភៅរូបភាពមួយក្បាលនិងក្រដាសល្បែងដើរតួ<br>■ ក្រុមនីមួយៗត្រូវមាន អ្នកផ្តល់ប្រឹក្សាម្នាក់និងអតិថិជនម្នាក់ឬពីរនាក់ (មានករណីសិក្សាមួយត្រូវការឱ្យដើរតួជាប្តីប្រពន្ធ) រីឯអ្នកផ្សេងទៀតត្រូវដើរតួជាអ្នកសង្កេតការណ៍ (ត្រូវមានក្រដាសវាយតម្លៃពីការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម)<br>■ អ្នកផ្តល់ប្រឹក្សា ត្រូវធ្វើការប្រឹក្សាមុនតេស្តដោយប្រើសៀវភៅរូបភាពនិងធ្វើតាមតួដែលខ្លួនត្រូវសំដែង<br>■ អ្នកដែលជាអតិថិជន ត្រូវគួរសមនិងត្រូវស្តាប់អ្នកផ្តល់ប្រឹក្សា ក៏ប៉ុន្តែត្រូវដើរតួឱ្យដូចពិតៗ ដើម្បីឱ្យអ្នកផ្តល់ប្រឹក្សារៀនធ្វើការដោះស្រាយជាមួយអតិថិជន<br>■ ក្រុមនីមួយៗត្រូវដើរតួគ្រប់ទាំងអស់ ដោយប្តូរតួម្តងម្នាក់ជាអ្នកផ្តល់ប្រឹក្សានិងជាអតិថិជន |

| | |
|---|---|
| **សង្ខេបខ្លីៗ** | ក្រោយពីវគ្គផ្តល់ប្រឹក្សានីមួយៗបានបញ្ចប់ ត្រូវធ្វើការសង្ខេបដូចតទៅ:<br>■ សួរទៅអ្នកផ្តល់ប្រឹក្សាឱ្យគាត់និយាយពីវគ្គផ្តល់ប្រឹក្សាដែលគាត់បានធ្វើ ថាតើមានដំណើរការយ៉ាងដូចម្តេចដែរ តើគាត់ធ្វើបានល្អត្រង់ចំណុចណាខ្លះ តើគាត់ចង់ប្តូរអ្វីខ្លះនៅពេលផ្តល់ប្រឹក្សាលើកក្រោយទៀត<br>ដោយប្រើបញ្ជីផ្ទៀងផ្ទាត់វាយតម្លៃ អ្នកសង្កេតការណ៍ត្រូវផ្តល់ព័ត៌មានត្រឡប់ដល់អ្នកផ្តល់ប្រឹក្សាអំពី:<br>- តើចំណុចខ្លាំងរបស់អ្នកផ្តល់ប្រឹក្សាមានអ្វីខ្លះ?<br>- តើកាយវិការនិងពាក្យសំដីរបស់អ្នកផ្តល់ប្រឹក្សា ជួយដល់ការបង្ហាញរបស់គាត់ដែរឬទេ?<br>- តើអ្នកផ្តល់ប្រឹក្សាមានផ្តល់ឱកាសដល់អតិថិជននៅក្នុងការពិភាក្សាដែរឬទេ និងឆ្លើយតបនឹងសំណួរបានច្បាស់លាស់ដែរឬទេ?<br>- តើអ្នកផ្តល់ប្រឹក្សាពន្យល់អំពីប្រធានបទនីមួយៗបានច្បាស់លាស់ដែរឬទេ និងមានបញ្ចូលគ្រប់ព័ត៌មានសំខាន់ៗដែរឬទេ?<br>- តើអ្នកផ្តល់ប្រឹក្សាដោះស្រាយបញ្ហាលំបាករបស់អតិថិជនបានសមស្របដែរឬទេ?<br>នៅពេលដែលសិក្ខាកាមគ្រប់គ្នាបានដើរតួជាអ្នកផ្តល់ប្រឹក្សារួចហើយ ឱ្យគាត់ត្រឡប់មកក្រុមធំវិញ។ ឱ្យសិក្ខាកាមធ្វើការពិភាក្សា:<br>■ តើលំហាត់នេះដំណើរការយ៉ាងដូចម្តេចដែរ? តើសិក្ខាកាមមានអារម្មណ៍យ៉ាងដូចម្តេចដែរក្នុងការដើរតួជាអ្នកផ្តល់ប្រឹក្សា?<br>■ តើគាត់មានអារម្មណ៍យ៉ាងណាដែរចំពោះអតិថិជន?<br>■ តើការសំដែងជាតួដូច្នេះ ខុសគ្នាយ៉ាងណាដែរជាមួយនឹងការងារពិត?<br>■ តើសៀវភៅរូបភាពជួយអ្នកបានអ្វីខ្លះ? តើសៀវភៅនេះមានចំណុចខ្លាំងត្រង់ណាខ្លះ? តើអ្នកផ្តល់ប្រឹក្សាត្រូវបង្កើនជំនាញអ្វីខ្លះទៀត ដើម្បីប្រើប្រាស់សៀវភៅរូបភាពឱ្យបានប្រសើរជាងមុន?<br>■ តើចំណុចសិក្សាដំបូងអំពីលំហាត់នេះមានអ្វីខ្លះ?<br>■ គ្រូត្រូវកត់ត្រាចំណុចសំខាន់ៗនៅលើសៀវភៅរូបភាពឬនៅលើក្តារខៀន។ |

## សកម្មភាពទី៥ ភាគទី១: វគ្គផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម: ការសំដែងតួជាអតិថិជននិងការសម្គាល់របស់គ្រូ

| ការសំដែងតួជាអតិថិជន |
| --- |

**អតិថិជនទី១:**

នាងវិទ្យាមានផ្ទៃពោះ៣២សប្តាហ៍ហើយ ។ នាងមានការបារម្ភចង់ដឹងខ្លាំងណាស់អំពីមេរោគអេដស៍ ។ នាងមិនបានគិតថា ខ្លួននាងបានឆ្លងមេរោគអេដស៍ទេ ក៏ប៉ុន្តែនាងចង់ដឹងឱ្យបានច្រើនអំពីរឿងនេះ ។ ឧបសគ្គក្នុងការស្តាប់អំពីបញ្ហានេះ គឺកូនរបស់នាងដែលមានអាយុ១៨ខែចេះតែរត់លេងចុះឡើងនៅលើជណ្តើរ ។

**អតិថិជនទី២:**

នាងសីលាមានផ្ទៃពោះ៣៦សប្តាហ៍ហើយ ។ នាងមិនសូវដឹងអំពីមេរោគអេដស៍ច្រើនទេ ។ នេះជាផ្ទៃពោះលើកទី១របស់នាងហើយ ។ នាងចង់ដឹងឱ្យបានច្រើនអំពីមេរោគអេដស៍នេះ ។ នាងមានសំណួរជាច្រើនចង់សួរ តែនាងមិនហ៊ានសួរ ។

**អតិថិជនទី៣:**

នាងសំណាងមានផ្ទៃពោះ៣០សប្តាហ៍ហើយ ។ នាងចង់ដឹងអំពីមេរោគអេដស៍ខ្លាំងណាស់ ។ នាងមានសំណួរជាច្រើនដែលនាងមិនខ្លាចនឹងសួរទេ ។

**អតិថិជនទី៤:**

នាងគីនីនមានផ្ទៃពោះ៣៩អាទិត្យនិងគ្មានជាសុកភាពសោះ ។ នាងគ្មានការអំណត់ជាមួយនឹងការបង្ហាញអំពីមេរោគអេដស៍សោះ ។ នាងគិតថាជាការខាតពេលអត់ប្រយោជន៍ ។ នាងគិតថា នាងមិនអាចឆ្លងមេរោគអេដស៍បានទេ ពីព្រោះនាងជាស្ត្រីកាន់ព្រះពុទ្ធសាសនា ហើយគិតថាអ្នកដែលមានផ្ទុកមេរោគអេដស៍សមតែទទួលបាបកម្មនេះហើយ ។

**អតិថិជនទី៥:**

នាងម៉ាយ៉ាមានផ្ទៃពោះ៣២សប្តាហ៍ហើយ ។ នាងមានដៃគូជាច្រើនកាលពីមួយឆ្នាំកន្លងទៅនេះ ។ ដៃគូម្នាក់ក្នុងចំណោមដៃគូទាំងអស់មានសុខភាពមិនសូវល្អទេ ។ ម៉ាយ៉ាមានសំណួរចង់សួរជាច្រើន ដែលសំណួរទាំងនោះទាក់ទងទៅនឹងការប្រឈមមុខខ្ពស់របស់នាង (តើជំងឺអេដស៍មានរោគសញ្ញាអ្វីខ្លះ? តើធ្វើយ៉ាងដូចម្តេចដើម្បីឱ្យខ្ញុំដឹងថា ដៃគូរបស់ខ្ញុំមានជំងឺអេដស៍? តើខ្ញុំអាចឆ្លងមេរោគអេដស៍ដែរឬទេ ប្រសិនជាខ្ញុំរួមភេទតែពីរដងគត់?)

## សកម្មភាពទី៥ ភាគទី២: ល្បែងដើរតួ: ការផ្តល់ប្រឹក្សាជាបុគ្គលនិងដល់ប្តីប្រពន្ធ

| ល្បែងដើរតួទី១: (ការផ្តល់ប្រឹក្សាជាបុគ្គល) |
| --- |
| "គឹមលី " ជាស្ត្រីម្នាក់អាយុ៣៥ឆ្នាំ។ នាងបានបាត់បង់ស្វាមីរយៈពេល៥ឆ្នាំកន្លងទៅហើយ។ ប្តីរបស់គាត់ធ្លាប់ធ្វើជាមន្ត្រីគយច្រកព្រំដែនវៀតណាម ហើយធ្លាប់ឈឺជាច្រើនខែមុននឹងគាត់ស្លាប់។ ឆ្នាំមុន " គឹមលី " បានរៀបការម្តងទៀត ឥឡូវនេះនាងមានផ្ទៃពោះកូនទី៤។ នាងបានទៅពិនិត្យផ្ទៃពោះ ហើយបានទទួលព័ត៌មានអប់រំអំពីមេរោគអេដស៍នៅថ្នាក់អប់រំសុខភាព។ នាងបានសម្រេចចិត្តមកទទួលការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម ពីព្រោះនាងចង់ធ្វើតេស្តឈាមរកមេរោគអេដស៍ ។ |

| ល្បែងដើរតួទី២: (ការផ្តល់ប្រឹក្សាជាបុគ្គល) |
| --- |
| " បុប្ផា" បានធ្វើជាស្ត្រីរកស៊ីផ្លូវភេទនៅប៉ោយប៉ែតរយៈពេល៤ឆ្នាំហើយ។ នាងមិនបានរៀបការទេ ប៉ុន្តែកូនក្នុងផ្ទៃនាងជាកូនទី២។ កូនទី១រស់នៅជាមួយជីដូនរបស់នាងនៅឯភ្នំពេញ។ ឆ្នាំមុននាងធ្លាប់បានព្យាបាលជំងឺកាមរោគ ហើយតាំងពីពេលនោះមក នាងព្យាយាមឱ្យភ្ញៀវរបស់នាងប្រើស្រោមអនាម័យ។ មានពេលខ្លះភ្ញៀវបដិសេធមិនព្រមប្រើស្រោម។ នៅពេលដែលនាងត្រូវការលុយខ្លាំង នាងត្រូវតែយល់ព្រមរួមភេទដោយមិនប្រើស្រោមអនាម័យ។ ឥឡូវនេះនាងកំពុងមានផ្ទៃពោះ។ នាងមិនទាន់ដឹងច្បាស់ថាត្រូវធ្វើអ្វីនោះទេ។ នាងបានឮអំពីមេរោគអេដស៍-ជំងឺអេដស៍ និងបានដឹងថាស្រីរកស៊ីផ្លូវភេទមួយចំនួនបានឆ្លងមេរោគអេដស៍។ នាងមិនបានដឹងថាឪពុករបស់កូននាងជាអ្នកណាទេ។ ប៉ុន្តែនាងគិតថានាងចង់បានកូនម្នាក់ទៀត និងមានបំណងត្រឡប់ទៅភ្នំពេញវិញដើម្បីរកការងារផ្សេងទៀតធ្វើ។ ដូច្នេះនាងអាចចិញ្ចឹមកូនដោយខ្លួនឯងបាន។ នាងសម្រេចចិត្តមកពិនិត្យផ្ទៃពោះ។ ឥឡូវនេះ នាងបានដឹងថាមានសេវាធ្វើតេស្តឈាមរកមេរោគអេដស៍។ នាងស្នើសុំធ្វើការប្រឹក្សាមុនពេលធ្វើតេស្តឈាម។ |

| ល្បែងដើរតួទី៣: (ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ) |
| --- |
| " សុផល "និងមិត្តស្រីរបស់គាត់ឈ្មោះ " ណារី " កំពុងសិក្សាផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៅភ្នំពេញ។ គេទាំងពីរនាក់បានរៀបការ១ឆ្នាំមកហើយ។ ឥឡូវនេះ " ណារី "មានផ្ទៃពោះ៤ខែហើយ។<br>" ណារី " មានប្អូនថ្លៃស្រីម្នាក់មានផ្ទុកមេរោគអេដស៍ដែលកូនស្រីតូចរបស់នាងបានស្លាប់កាលពីឆ្នាំមុន។ "ណារី" ធ្លាប់មានមិត្តប្រុសម្នាក់មុនពេលជួបនឹង " សុផល " នាងមានអារម្មណ៏មិនទុកចិត្ត "សុផល" និងគិតថា "សុផល"អាចធ្លាប់គេងជាមួយស្រីបំរើស្រាបៀរមុនពេលជួបនឹងនាង។ " សុផល " ធ្លាប់និយាយអំពីការស្រវឹងជួបជុំមិត្តភ័ក្តិនៅពេលល្ងាចនៅរង្គសាលនិងខារ៉ាអូខេ។<br>នាងបានពន្យល់ " សុផល " ថា នាងមានការបារម្ភខ្លាចឆ្លងមេរោគអេដស៍ ដោយសារតែប្អូនថ្លៃស្រីរបស់នាងធ្លាប់មានប្តីធ្វើជាយោធា។ នាងបានដឹងអំពីការធ្វើតេស្តឈាមនៅពេលដែលនាងមកពិនិត្យផ្ទៃពោះនៅគ្លីនិកកាលពីអាទិត្យមុន។ អ្នកផ្តល់ប្រឹក្សាបានប្រាប់នាងថា ប្រសិនជានាងបានមកទទួលការប្រឹក្សាជាមួយប្តីរបស់នាង វាជាការប្រសើរណាស់។ នាងបានអូសទាញប្តីនាងឱ្យមកជាមួយ។ ក៏ប៉ុន្តែ " សុផល " ប្រាប់នាងថា គេនឹងមិនធ្វើតេស្តឈាមរកមេរោគអេដស៍ទេ។ |

## ម៉ូឌុលទី១០: ចំណុចគន្លឹះ

- ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម មានគោលបំណងឱ្យស្ត្រីនិងដៃគូបានត្រៀមខ្លួនមុននឹងធ្វើតេស្តរកមេរោគអេដស៍ ដោយផ្តល់នូវព័ត៌មាននិងការអប់រំស្តីអំពីមេរោគអេដស៍-ជំងឺអេដស៍ និងការធ្វើតេស្តឈាម
- គុណសម្បត្តិនិងគុណវិបត្តិនៃការធ្វើតេស្តឈាមត្រូវលើកយកមកពិភាក្សា
- ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត ជាការត្រៀមរួចស្រេចសម្រាប់អតិថិជនក្នុងការមកទទួលលទ្ធផលតេស្តនៅពេលផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម។
- ការវាយតម្លៃអំពីការប្រឈមនឹងការឆ្លងមេរោគអេដស៍របស់បុគ្គល និងផែនការកាត់បន្ថយការប្រឈម (មានការបង្ហាញអំពីការប្រើប្រាស់ស្រោមអនាម័យ ប្រសិនជាមានពេលវេលាសមស្រប) ត្រូវលើកយកមកពិភាក្សា ប្រសិនជាការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធឬជាបុគ្គល
- នៅចុងបញ្ចប់នៃការផ្តល់ប្រឹក្សា ស្ត្រីមានផ្ទៃពោះ និងឬ ដៃគូរបស់នាងគួរតែស្ថិតនៅក្នុងស្ថានភាពមួយដែលអាចឱ្យគាត់ធ្វើការសម្រេចចិត្តក្នុងការធ្វើតេស្តឈាមបាន។

## ឧបសម្ព័ន្ធទី១០

បញ្ជីផ្ទៀងផ្ទាត់នេះអាចប្រើប្រាស់ដោយអ្នកផ្តល់ប្រឹក្សា ដើម្បីជួយរំលឹកដល់គាត់អំពីដំណាក់កាលដែលគាត់ត្រូវធ្វើ នៅពេលផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាមម្តាយ ជាក្រុម ជាបុគ្គល ឬជាប្តីប្រពន្ធ

**បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម**

ប្រើសៀវភៅរូបភាពមុនពេលធ្វើតេស្តឈាមនៅផ្នែកថែទាំផ្ទៃពោះ ដើម្បីជាជំនួយក្នុងការផ្តល់សារ

១. ព័ត៌មានជាមូលដ្ឋាន ស្តីអំពីមេរោគអេដស៍-ជំងឺអេដស៍
២. ការវាយតម្លៃពីការយល់ដឹងអំពីមេរោគអេដស៍
៣.គុណសម្បត្តិនិងការប្រឈមនឹងការធ្វើតេស្តឈាម
៤.ដំណើរការធ្វើតេស្តឈាមរកមេរោគអេដស៍
៥.ការរក្សាការសម្ងាត់
៦.អត្ថន័យនិងការពាក់ព័ន្ធទៅនឹងលទ្ធផលតេស្តវិជ្ជមាននិងអវិជ្ជមាន
៧.ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដល់ដៃគូ
៨.វិធីបង្ការការចម្លងមេរោគអេដស៍រវាងដៃគូ
៩.វិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
១០.ការកំណត់រកសេវាថែទាំនិងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍

**ប្រសិនជាអ្នកផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមនៅបន្ទប់អប់រំម្តាយ នៅចុងបញ្ចប់ត្រូវនិយាយថា:**

- ការធ្វើតេស្តឈាមរកមេរោគអេដស៍ គឺជាផ្នែកមួយនៃការផ្តល់សេវាជាប្រចាំដល់អ្នក
- ប្រសិនជាអ្នកចង់បានព័ត៌មានថែមទៀត ឬក៏ចង់នាំប្តីមកជាមួយដើម្បីទទួលប្រឹក្សាទាំងពីរនាក់ សូមប្រាប់មកពួកយើងដែលកំពុងតែធ្វើការក្នុងថ្ងៃនេះ

**ប្រសិនជាអ្នកផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល ឬ ជាលក្ខណៈប្តីប្រពន្ធ សូមផ្តល់សារដូចតទៅនេះ:**

- ការប៉ាន់ប្រមាណអំពីគ្រោះប្រឈមនឹងមេរោគអេដស៍និងជំងឺកាមរោគ
  - ពន្យល់ថា ជំងឺកាមរោគបង្កើនគ្រោះប្រឈមនឹងការចម្លងមេរោគអេដស៍ និងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
  - ប្រាប់អតិថិជនអំពីការទទួលសេវាព្យាបាលជំងឺកាមរោគផ្សេងៗទៀត
- ផែនការកាត់បន្ថយការប្រឈម
- រាវរកជម្រើសនៃការបើកចំហស្ថានភាពរបស់អតិថិជន

| **ក្រដាសវាយតម្លៃការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម — ក្នុងវគ្គនេះ តើអ្នកផ្តល់ការប្រឹក្សាមានធ្វើដូចសំណួរនៅខាងក្រោមដែរឬទេ?** | **មាន** | **គ្មាន** |
|---|---|---|
| ១. ស្វាគមន៍និងធ្វើការវកិច្ច | | |
| ២. អ្នកផ្តល់ប្រឹក្សាធ្វើការណែនាំខ្លួន | | |
| ៣. ពន្យល់ហេតុផលនៃការពិភាក្សា | | |
| ៤. សង្ខេបត្រួសៗអំពីដំណើរការនៃការផ្តល់ប្រឹក្សា " ថ្ងៃនេះ យើងនឹង...." | | |
| **១០ បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមមាន១០ចំណុចដែលត្រូវនិយាយ:** (ត្រូវមើលសៀវភៅរូបភាពផងដែរ) | | |
| ១. ព័ត៌មានជាមូលដ្ឋានស្តីអំពីមេរោគអេដស៍-ជំងឺអេដស៍ | | |
| ២. ការវាយតម្លៃអំពីការយល់ដឹងអំពីមេរោគអេដស៍ | | |
| ៣. គុណសម្បត្តិនិងការប្រឈមនៃការធ្វើតេស្តឈាម | | |
| ៤. ដំណើរការធ្វើតេស្តឈាម | | |
| ៥. ការរក្សាការសម្ងាត់ | | |
| ៦. អត្ថន័យនិងការពាក់ព័ន្ធរវាងលទ្ធផលតេស្តវិជ្ជមាននិងលទ្ធផលតេស្តអវិជ្ជមាន | | |
| ៧. ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដល់ដៃគូ | | |
| ៨. វិធីបង្ការការចម្លងមេរោគអេដស៍រវាងដៃគូ | | |
| ៩. វិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន | | |
| ១០. ការកំណត់រកសេវាថែទាំ-ព្យាបាលនិងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ | | |
| **ការផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល ឬ ជាលក្ខណៈប្តីប្រពន្ធ** | | |
| ១. ការវាយតម្លៃអំពីការប្រឈមនឹងមេរោគអេដស៍ | | |
| ២. ពិភាក្សាផែនការកាត់បន្ថយការប្រឈមរបស់បុគ្គល | | |
| ៣. បង្ហាញអំពីរបៀបពាក់ស្រោមអនាម័យ (បើសិនជាសមស្រប) | | |
| ៤. រាវរកជម្រើសនៃការបើកចំហលទ្ធផលតេស្ត | | |
| ៥. ឥរិយាបថរបស់អ្នកផ្តល់ប្រឹក្សា: តើអ្នកផ្តល់ប្រឹក្សាមានបានធ្វើ...? | | |

| ឥរិយាបថរបស់អ្នកផ្តល់ប្រឹក្សាៈ តើអ្នកផ្តល់ប្រឹក្សាមានបានធ្វើ...? | | |
|---|---|---|
| ១. ផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អតិថិជននៅពេលផ្តល់ប្រឹក្សាដែរឬទេ? | | |
| ២. យកចិត្តទុកដាក់និងស្តាប់អតិថិជននៅពេលផ្តល់ការប្រឹក្សាដែរឬទេ? | | |
| ៣. បង្អាក់ការសន្ទនារបស់អតិថិជន? | | |
| ៤. ទុកពេលឱ្យអតិថិជនគិតក្នុងអារម្មណ៍ឬគិតបញ្ហាបានគ្រប់គ្រាន់ ? | | |
| ៥. បង្ហាញការយល់ចិត្តអតិថិជន? | | |
| ៦. លើកទឹកចិត្តនិងទុកពេលឱ្យអតិថិជនមានពេលគ្រប់គ្រាន់ក្នុងការសួរសំណួរ? | | |
| ៧. ឥរិយាបថរបស់អ្នកផ្តល់ប្រឹក្សាចំពោះអតិថិជន (សូមដាក់ពិន្ទុពី ១ទៅ៥: ១គឺអន់ណាស់ និង ៥គឺល្អបំផុត) | | |
| ៨. តើវគ្គផ្តល់ប្រឹក្សានេះបានបញ្ចប់ដោយបរិយាកាសវិជ្ជមានដែរឬទេ? | | |

# ម៉ូឌុលទី១១
# ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. កំណត់បានអំពីគោលបំណងនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

២. អធិប្បាយអំពីដំណើរការនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម សម្រាប់ស្ត្រីមានផ្ទៃពោះនៅសេវាថែទាំផ្ទៃពោះ

៣. រាយបញ្ជីនៃប្រធានបទដែលត្រូវលើកមកពិភាក្សា ក្នុងអំឡុងពេលផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមដល់:

ក-អតិថិជនទាំងអស់

ខ-អ្នកដែលមានលទ្ធផលតេស្តឈាមអវិជ្ជមាន

គ-អ្នកដែលមានលទ្ធផលតេស្តឈាមវិជ្ជមាន

៤. ពិភាក្សាអំពីសមាសភាគនៃការផ្តល់ប្រឹក្សាក្រោយតេស្តឱ្យបានលំអិត អំពីការកាត់បន្ថយគ្រោះប្រឈម ការប្រាប់លទ្ធផលតេស្តឱ្យគេដឹង ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ ការរស់នៅដោយវិជ្ជមាន

៥. ពិភាក្សាអំពីប្រតិកម្មផ្លូវចិត្តនៅពេលដឹងពីលទ្ធផលតេស្ត

៦. ពិភាក្សាអំពីយុទ្ធវិធីនៃការផ្តល់ប្រឹក្សាដល់ឪពុកម្តាយ អំពីលទ្ធផលតេស្តឈាមរកមេរោគអេដស៍កូនរបស់គាត់ ។



*រយៈពេល:* ***៥ម៉ោង៣០នាទី***

# សកម្មភាពទី១: សេចក្តីផ្តើមស្តីអំពីការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

## ការផ្តល់ប្រឹក្សាក្រោយតេស្តឈាម_គោលបំណង

ការផ្តល់ប្រឹក្សាក្រោយតេស្តមានគោលបំណង:

- ផ្តល់លទ្ធផលតេស្តឈាមរកមេរោគអេដស៍ដល់អតិថិជន និងជួយឱ្យគាត់យល់ពីលទ្ធផលតេស្តនោះ
- ជួយអតិថិជននៅពេលដែលគាត់មានការរន្ធត់ចិត្ត ឬអារម្មណ៍ចំពោះលទ្ធផលរបស់គាត់
- ផ្តល់ព័ត៌មានសំខាន់ៗស្តីពីកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- បញ្ជូនអតិថិជនទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- ដោះស្រាយ និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរឥរិយាបថកាត់បន្ថយគ្រោះប្រឈម
- ពិភាក្សាពីការប្រាប់លទ្ធផលតេស្តដល់អ្នកដទៃ និងការធ្វើតេស្តឈាមរកមេរោគអេដស៍ដល់ដៃគូ
- ផ្តល់ការគាំទ្រ ផ្តល់ព័ត៌មាន និង ការបញ្ជូនដទៃទៀតដល់អតិថិជននៅពេលដែលចាំបាច់។

5

## ដំណើរការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

ដំណើរការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម អាចចែកចេញជា២ផ្នែក:

- ផ្នែកទី១ អនុវត្តលើគ្រប់អតិថិជនទាំងអស់ដែលមកទទួលលទ្ធផលតេស្ត
- ផ្នែកទី២ ការផ្តល់ប្រឹក្សាមានភាពខុសគ្នា អាស្រ័យទៅនឹងលទ្ធផលតេស្តវិជ្ជមាន ឬ អវិជ្ជមាន

ការផ្តល់ប្រឹក្សាក្រោយតេស្តឈាមក៏មានភាពខុសគ្នាដែរ។ វាអាស្រ័យទៅនឹងការផ្តល់ប្រឹក្សាជាលក្ខណៈបុគ្គល ឬ ជាប្តីប្រពន្ធ។

6

## ការផ្តល់លទ្ធផលតេស្ត

- ចំពោះការអនុវត្តន៍នៅកម្ពុជា រាល់លទ្ធផលតេស្តឈាមត្រូវបានដាក់ចូលទៅក្នុងស្រោមសំបុត្រសំរាប់អ្នកផ្តល់ប្រឹក្សាយកទៅជូនអតិថិជនក្នុងអំឡុងពេលផ្តល់ប្រឹក្សាក្រោយតេស្ត
- អ្នកផ្តល់ប្រឹក្សាមិនបានដឹងពីលទ្ធផលតេស្តឈាមមុនពេលជួបនឹងអតិថិជនទេ
- ក្រោយពីបានការអនុញ្ញាតពីអតិថិជន អ្នកផ្តល់ប្រឹក្សាត្រូវបើកស្រោមសំបុត្រ ដើម្បីអាននិងពន្យល់ប្រាប់ពីអត្ថន័យនៃលទ្ធផលតេស្ត
- អ្នកផ្តល់ប្រឹក្សាត្រូវតែត្រៀមលក្ខណៈដឹងឮចំពោះលទ្ធផលតេស្តដែលត្រៀមនឹងបើក មិនថាលទ្ធផលវិជ្ជមានឬអវិជ្ជមាននោះទេ និងអាចធ្វើការងារជាមួយអតិថិជនបន្តទៀតបាន។

7

## សកម្មភាពទី២: បំផុសគំនិត : តើប្រធានបទអ្វីខ្លះដែលត្រូវលើកមកពិភាក្សាក្នុងពេលផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

» គោលបំណងនៃលំហាត់នេះ គឺដើម្បីប្រមូលផ្តុំចំណុចនានាដែលត្រូវនិយាយក្នុងពេលផ្តល់ប្រឹក្សាក្រោយតេស្ត

» គ្រូស្នើឱ្យសិក្ខាកាមមានយោបល់អំពីចំណុចដែលត្រូវនិយាយនៅពេលផ្តល់ប្រឹក្សាក្រោយតេស្ត

### ដំណើរការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមៈ គ្រប់អតិថិជនទាំងអស់

- ពិនិត្យមើលថាតើលេខកូដ PMTCT របស់អតិថិជន និងលេខនៅលើស្រោមសំបុត្រដូចគ្នាឬទេ
- រំលឹកឡើងវិញពីអ្វីដែលបានប្រឹក្សារួចនៅមុនពេលធ្វើតេស្តឈាម
- រំលឹកឡើងវិញពីអារម្មណ៍របស់អតិថិជនអំពីការទទួលយកលទ្ធផលតេស្ត និងការសំរបខ្លួន ជាមួយលទ្ធផលតេស្ត
- សួរទៅអតិថិជន តើពួកគេបានត្រៀមខ្លួននឹងទទួលលទ្ធផលតេស្តពីអ្នកផ្តល់ប្រឹក្សាហើយឬនៅ
- បើសិនជាអតិថិជនយល់ព្រម សូមបើកស្រោមសំបុត្រអានលទ្ធផល និងពន្យល់លទ្ធផលតេស្តដល់អតិថិជន
- ទុកពេលវេលាឱ្យអតិថិជនបានសំដែងចេញនូវប្រតិកម្មនិងអារម្មណ៍ និងសួរសំណួរនានា។

9

### ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមៈ លទ្ធផលតេស្តអវិជ្ជមាន (១)

**លទ្ធផលតេស្តអវិជ្ជមាន** មានន័យថា បុគ្គលមិនបានឆ្លងមេរោគអេដស៍ទេ ឬស្ថិតនៅក្នុងរយៈពេលសំងំនៃមេរោគ

- រំលឹកឡើងវិញពីអត្ថន័យនៃលទ្ធផលតេស្ត
- ភាពរករយៈពេលសំងំនៃមេរោគ និងលើកទឹកចិត្តដល់អ្នកដែលប្រឈមនឹងការឆ្លងថ្មីៗឱ្យត្រឡប់មកធ្វើតេស្តឈាមម្តងទៀតក្នុងរវាង៣ខែក្រោយ
- បើសិនជាស្ត្រីមកតែម្នាក់ឯង សូមពិភាក្សាពីការប្រាប់លទ្ធផលតេស្តឱ្យគេដឹង និងការធ្វើតេស្តឈាមរបស់ដៃគូ
- និយាយពីលទ្ធផលតេស្តមិនស្របគ្នារបស់ដៃគូ
- ពិភាក្សាផែនការកាត់បន្ថយគ្រោះប្រឈមនឹងការឆ្លង ដើម្បីឱ្យលទ្ធផលតេស្តនៅតែអវិជ្ជមានជានិច្ច
  - ពង្រឹងសារ អេ ប៊ី ស៊ី (A B C)
  - អប់រំពីការប្រើប្រាស់ស្រោមអនាម័យ និងធ្វើការបង្ហាញពីរបៀបប្រើប្រាស់វា
  - ផ្តល់ស្រោមអនាម័យដល់អ្នកដែលមានបំណងនឹងប្រើប្រាស់វា

10

### ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមៈ លទ្ធផលតេស្តអវិជ្ជមាន (២)

- សង្កត់ធ្ងន់ពីសារៈសំខាន់នៃការរក្សាស្ថានភាពឱ្យនៅតែអវិជ្ជមានក្នុងកំឡុងពេលមានផ្ទៃពោះ និងនៅពេលបំបៅដោះកូន
- លើកទឹកចិត្តស្ត្រីឱ្យចិញ្ចឹមកូនដោយដោះ
- ផ្តល់ព័ត៌មាន ឬបញ្ជូនស្ត្រីទៅសេវាទាក់ទងដទៃទៀត ដូចជា សេវាផែនការគ្រួសារ គ្លីនិកជម្ងឺកាមរោគ បើសិនជាអាច
- ផ្តល់ឯកសារអប់រំដល់ស្ត្រី
- សួរថាតើគាត់មានសំណួរ ឬការបារម្ភអ្វីដែរឬទេ
- លើកទឹកចិត្តស្ត្រីឱ្យមកជួបទៀត បើសិនជាចាំបាច់

បន្ថែមពីលើនេះសូមៈ

- និយាយលើកទឹកចិត្តស្ត្រីឱ្យនាំដៃគូមកទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍
- និយាយពីជំនាញចរចាពីសុវត្ថិភាពនៃការរួមភេទ

11

## ការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមៈ លទ្ធផលតេស្តវិជ្ជមាន (១)

**លទ្ធផលតេស្តវិជ្ជមាន** មានន័យថា បុគ្គលបានឆ្លងមេរោគអេដស៍ ប៉ុន្តែមិនមែនមានន័យថាគាត់ត្រូវតែមានជម្ងឺអេដស៍នោះទេ

- រំលឹកអំពីអត្ថន័យនិងការជាប់ទាក់ទងទៅនឹងលទ្ធផលតេស្ត
- លើកទឹកចិត្តឱ្យអតិថិជនបញ្ចេញអារម្មណ៏របស់គាត់ រាវរកបញ្ហារបស់គាត់ និងគាំទ្រដល់គាត់

នៅពេលណាដែលអតិថិជនបានត្រៀមខ្លួនរួចរាល់ហើយ សូមពន្យល់ទៅអតិថិជនថាមានបញ្ហាសំខាន់ទាក់ទងនឹងជីវិតប្រចាំថ្ងៃ ជាច្រើនដែលត្រូវពិភាក្សា

វាជាការសំខាន់ណាស់ដែលត្រូវលើកយកបញ្ហាទាំងនោះមកពិភាក្សាក្នុងពេលផ្ដល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមដើម្បីឱ្យអតិថិជនស៊ាំជាមួយបញ្ហាទាំងនោះជាមុន ។

12

## ការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមៈ លទ្ធផលតេស្តវិជ្ជមាន (២)

- រំលឹកប្រាប់ដល់ស្រ្តីពីអន្តរាគមន៏បង្ការការចម្លងមេរោគអេដស៏ពីម្តាយទៅកូនដែលមាន និងពីសារៈសំខាន់នៃសេវា PMTCT:
  - ការបង្ការ និងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៏ បង្ការដោយឱសថប្រឆាំងមេរោគអេដស៏
  - ជំរើសនៃការចិញ្ចឹមកូន
  - ការសំរាលកូននៅកន្លែងដែលមានសេវា PMTCT
  - អាហាររូបត្ថម្ភគ្រប់គ្រាន់
  - ការរស់នៅប្រកបដោយភាពវិជ្ជមាន
- ពិភាក្សាពីសេវាថែទាំព្យាបាល និងគាំទ្រដទៃទៀត
- បញ្ជូនស្រ្តីទៅទទួលសេវាព្យាបាលជម្ងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៏ ដែលនៅជិតបំផុត ដើម្បីឱ្យគាត់បានទទួលការព្យាបាលនិងបង្ការ ដោយមានការយល់ព្រមពីសាមីខ្លួន
- បើសិនជាស្រ្តីមកតែម្នាក់ឯង ពិភាក្សាពីការចំហលទ្ធផលតេស្ត ការធ្វើតេស្តឈាមដល់ដៃគូ និងជំរើសនៃការបង្ការ
- ជជែកពីលទ្ធផលតេស្តមិនស្របគ្នាចំពោះប្ដីប្រពន្ធ

13

## ការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមៈ លទ្ធផលតេស្តវិជ្ជមាន (៣)

- កំណត់រកប្រភពនៃក្ដីសង្ឃឹមសំរាប់អតិថិជន ដូចជាៈ គ្រួសារ មិត្តភ័ក្ត្រ សេវានៅតាមសហគមន៏ ការគាំទ្រខាងផ្លូវចិត្តនិងជំរើសនៃការព្យាបាល ការបញ្ជូនសមស្រប
- ផ្ដល់ព័ត៌មាន ឬបញ្ជូនអតិថិជនទៅសេវាដែលពាក់ព័ន្ធ ដូចជា សេវាផែនការគ្រួសារ គ្លីនិកជម្ងឺកាមរោគឱ្យបានសមស្រប
- បើសិនជាអតិថិជនមានកូន សូមពិភាក្សាពីការធ្វើតេស្តឈាមរកមេរោគអេដស៏ដល់កូនទាំងនោះ
- សួរអតិថិជនថាតើ គាត់មានសំណួរ ឬការបារម្ភដែរឬទេ។ ផ្ដល់ព័ត៌មានដល់អតិថិជនសំរាប់ទាក់ទងជាមួយគ្លីនិកទាំងនោះ
- ផ្ដល់ឯកសារអប់រំដល់ស្រ្តី

14

## ការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមៈ លទ្ធផលតេស្តវិជ្ជមាន (៤)

- រំលឹកដល់ ស្រ្តីនិងគ្រួសារថា គាត់អាចមកទទួលសេវាផ្ដល់ប្រឹក្សាបានគ្រប់ពេលវេលាក្នុងពេលដែលគាត់មានផ្ទៃពោះដើម្បីជួយគាត់ក្នុងការរៀបផែនការសំរាប់អនាគត និងទទួលបាននូវសេវាផ្សេង១

បន្ថែមពីលើនេះ:

- លើកទឹកចិត្តស្រ្តីឱ្យនាំដៃគូមកទទួលសេវាផ្ដល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់
- រៀបផែនការកាត់បន្ថយគ្រោះប្រឈម មានការបង្ការការចម្លងមេរោគអេដស៏ទៅអ្នកដែលមិនទាន់ឆ្លង ឬទៅដៃគូដែលមិនទាន់បានធ្វើតេស្តឈាមរកមេរោគអេដស៏ និងបង្ការការឆ្លងមេរោគអេដស៏បន្ថែមទៀត
- ពិភាក្សាពីជំនាញក្នុងការចរចាសុវត្ថិភាពនៃការរួមភេទ

15

## សកម្មភាពទី៣: ធ្វើការជាក្រុម: សមាសភាគនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

» គ្រូចែកសិក្ខាកាមជា៤ក្រុមនិងចែកប្រធានបទនីមួយៗទៅឱ្យសិក្ខាកាម:

ក្រុមទី១: ការកាត់បន្ថយគ្រោះប្រឈមនិងការប្តូរឥរិយាបថ

ក្រុមទី២: ការប្រាប់លទ្ធផលតេស្តដល់អ្នកដទៃ

ក្រុមទី៣: ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធនិងលទ្ធផលតេស្តប្តីប្រពន្ធមិនស្របគ្នា

ក្រុមទី៤: ការរស់នៅប្រកបដោយភាពវិជ្ជមាន

» ក្រុមនីមួយៗត្រូវគិតអំពីចំណុចដែលទាក់ទងទៅនឹងប្រធានបទរបស់គេ និងដែលត្រូវនិយាយនៅពេលប្រឹក្សាក្រោយតេស្ត

» គ្រូទុកពេល១៥នាទី ដើម្បីឱ្យសិក្ខាកាមធ្វើការ។

» ក្រុមនីមួយៗឡើងមកបង្ហាញលទ្ធផលរបស់ក្រុមខ្លួន

» គ្រូដឹកនាំការពិភាក្សាដើម្បីឱ្យប្រាកដថាគ្រប់គ្នាបានយល់ច្បាស់

### ១. គំរោងកាត់បន្ថយគ្រោះប្រឈម: លទ្ធផលតេស្តអវិជ្ជមាន

- អតិថិជនដែលត្រូវបានប្រាប់ថា មានលទ្ធផលតេស្តអវិជ្ជមាន អាចសន្យាថានឹងទទួលរាល់ការណែនាំទាំងឡាយ ដើម្បីរក្សាលទ្ធផលតេស្តឈាមរបស់គាត់ឱ្យនៅតែវិជ្ជមានមេរោគអេដស៍ជានិច្ច
- ពេលខ្លះពួកគាត់ថែមទាំងប្រាប់អ្នកផ្តល់ប្រឹក្សាថានឹងមិនរួមភេទទៀតទេ
- អ្នកផ្តល់ប្រឹក្សាមិនត្រូវឱ្យឱកាសនេះកន្លងផុតទៅទេ។ ត្រូវពង្រឹងសារស្តីពីសកម្មភាពកាត់បន្ថយគ្រោះប្រឈមនឹងការឆ្លងរបស់អតិថិជន
- បើសិនជាអតិថិជនមានឥរិយាបថប្រឈមជាក់លាក់ណាមួយ អ្នកផ្តល់ប្រឹក្សាត្រូវប្រាប់ដល់អតិថិជនពីសកម្មភាពប្រឈមទាំងនោះ និងពិភាក្សាដើម្បីជួយអតិថិជនឱ្យផ្លាស់ប្តូរឥរិយាបថទាំងនោះចេញ។

17

### គំរោងកាត់បន្ថយគ្រោះប្រឈម: ការផ្លាស់ប្តូរឥរិយាបថ

- ការផ្លាស់ប្តូរអាកប្បកិរិយានិងឥរិយាបថ
  - -ជាមូលដ្ឋានសំរាប់ការបង្ការនិងការព្យាបាលថែទាំដល់អ្នកផ្ទុកមេរោគអេដស៍-ជម្ងឺអេដស៍
  - -មិនមែនជារឿងងាយស្រួលក្នុងការអនុវត្តន៍នោះទេ
  - -ជាដំណើរការមួយដែលទាមទារពេលវេលា និងការព្យាយាមយូរអង្វែង
- ឥរិយាបថរបស់មនុស្សម្នាក់ៗប្រែប្រួលទៅតាមអាយុ បទដ្ឋានសង្គម តម្លៃរបស់បុគ្គលម្នាក់ៗ និងសង្គម
- ដើម្បីសំរបទៅនឹងឥរិយាបថថ្មី មនុស្ស:
  - -ត្រូវយល់ដឹងពីផលប្រយោជន៍
  - -មានចំណេះដឹង
  - -មានជំនាញនិងសម្ភារៈ
  - -ឬអាចទទួលបាននូវសេវានានានិងការគាំទ្រពីមជ្ឈដ្ឋានជុំវិញ

18

## ២. ការប្រាប់លទ្ធផលតេស្តដល់អ្នកដទៃ (១)

សំដីផ្ទាល់របស់អ្នកផ្តល់ប្រឹក្សាម្នាក់ បាននិយាយថា:

"ការដែលអ្នកលាក់ទុកការសម្ងាត់នៃស្ថានភាពផ្ទុកមេរោគអេដស៍របស់អ្នក គឺដូចជាអ្នកកំពុងតែរែកពន់នូវរបស់មួយដ៏ធ្ងន់នៅលើស្មាតែម្ខាងរបស់អ្នក (លី) ។ ការចែករំលែកព័ត៌មានជាមួយមនុស្សដែលអ្នកស្រឡាញ់ គឺដូចជាអ្នករំលែកបន្ទុកដ៏ធ្ងន់នៅលើស្មាពីរដែរ (សែង) ។ ទោះបីជាពីដំបូងគេខឹងនឹងអ្នកក្តី បន្តិចម្តងៗ គេនឹងឈប់ខឹងនឹងអ្នក ហើយនៅថ្ងៃណាមួយពួកគេនឹងដឹងពីរឿងនេះ" ។

19

## ការប្រាប់លទ្ធផលតេស្តដល់អ្នកដទៃ (២)

- ការប្រាប់លទ្ធផលតេស្តដល់អ្នកដទៃ គឺធ្វើឡើងនៅពេលដែលមនុស្សម្នាក់សំរេចចិត្តប្រាប់ពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់ទៅអ្នកដទៃ
- បើសិនជាស្ត្រីម្នាក់ប្រាប់ស្ថានភាពផ្ទុកមេរោគអេដស៍របស់នាងទៅដៃគូ និងគ្រួសាររបស់នាង នាងប្រហែលជានឹងអាច:
  - -លើកទឹកចិត្តដៃគូរបស់នាងឱ្យស្ម័គ្រចិត្តធ្វើតេស្តឈាម
  - -បង្ការការចម្លងមេរោគអេដស៍ទៅដៃគូរបស់នាងបាន
  - -ទទួលបាននូវអន្តរាគមន៍នានាដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
  - -ទទួលបាននូវការគាំទ្រពីដៃគូនិងក្រុមគ្រួសាររបស់នាង ក្នុងអំឡុងពេលមានផ្ទៃពោះ និងក្រោយពេលមានផ្ទៃពោះ ដើម្បីអាចទទួលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងទទួលសេវាថែទាំព្យាបាល និងគាំទ្របន្ត ។

20

## ការប្រាប់ពីលទ្ធផលតេស្តដល់អ្នកដទៃ (៣)

- ហេតុផលដែលធ្វើឱ្យអ្នកជម្ងឺមិនចង់ប្រាប់ពីស្ថានភាពផ្ទុកមេរោគអេដស៍ដល់អ្នកដទៃ ដូចជា:
  - -ភ័យខ្លាចត្រូវគេបដិសេធ និងភ័យខ្លាចនឹងកំហឹងរបស់ដៃគូ ឬប្តី/ប្រពន្ធ ឬឳពុកម្តាយ ឬឳពុកម្តាយក្មេក( ដោយសារតែការខូចកិត្តិយសរបស់គ្រួសារ)
  - -ការភ័យខ្លាចបាត់បង់ការងារ
- ស្ត្រីអាចមានបំណងនឹងប្រាប់ស្ថានភាពរបស់គាត់ដល់អ្នកដទៃ ក៏ប៉ុន្តែមិនដឹងធ្វើដូចម្តេចដើម្បីឱ្យគេអាចទទួលយកបាន
- ការលាក់ស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន អាចជួយឱ្យអ្នកផ្ទុកមេរោគអេដស៍ការពារខ្លួនគាត់ពីផលប៉ះពាល់អវិជ្ជមានទាំងឡាយដែលអាចកើតមានឡើង ។ ក៏ប៉ុន្តែ ការលាក់ទុកនូវអ្វីដែលខ្លួនបានដឹង អាចជាបន្ទុកដ៏ធ្ងន់មួយ
- ការសិក្សាជាច្រើនបានបង្ហាញថា មនុស្សភាគច្រើននឹងប្រាប់ពីលទ្ធផលរបស់ខ្លួនទៅកាន់អ្នកដទៃទៀត អាស្រ័យលើពេលវេលាសមស្រប
- អ្នកផ្តល់ប្រឹក្សាអាចជួយអតិថិជនរៀបចំផែនការ និងជួយបង្ហាញពីរបៀបប្រាប់លទ្ធផលតេស្តដល់អ្នកដទៃ។

21

## ៣. ការផ្តល់ប្រឹក្សាដល់ប្តីប្រពន្ធ

- អ្នកផ្តល់ប្រឹក្សាត្រូវជួយប្តីឬប្រពន្ធម្នាក់ៗ ឱ្យចេះសំរបខ្លួនជាមួយនឹងប្រតិកម្មដែលបណ្តាលមកពី លទ្ធផលតេស្ត និង ប្រតិកម្មដៃគូរបស់គាត់
- នៅពេលដែលលទ្ធផលរបស់ប្តីប្រពន្ធទាំងពីរ វិជ្ជមាន ឬក៏ម្នាក់វិជ្ជមាន ហើយម្នាក់ទៀតអវិជ្ជមាន ភាគីម្ខាងអាចនឹងបន្ទោសភាគីម្ខាងទៀតពីឥរិយាបថប្រព្រឹត្តដែលនាំឱ្យទទួលបានលទ្ធផលបែបនេះ
- បើសិនជាប្តីប្រពន្ធបញ្ចេញអារម្មណ៍ ឬមានប្រតិកម្មខ្លាំងលើគ្នាទៅវិញទៅមក អ្នកផ្តល់ប្រឹក្សាចាំបាច់ត្រូវ:
  - -កំណត់ព្រំដែន ដើម្បីបញ្ឈប់ការបំពានខាងពាក្យសំដី ឬការបំពានលើរាងកាយគ្នាទៅវិញទៅមក
  - -ណែនាំពួកគាត់កុំឱ្យស្តីបន្ទោសដាក់គ្នា ហើយត្រូវនាំពួកគាត់ឱ្យផ្តោតលើការរៀបចំគំរោងរស់នៅជាមួយមេរោគអេដស៍ប្រកបដោយគំនិតវិជ្ជមានវិញ ។

22

## ៤. ការរស់នៅដោយភាពវិជ្ជមាន

"ប្រសិនបើខ្ញុំចុះខ្សោយឬស្លាប់ក្នុងពេលឆាប់ៗ តើមានអ្នកណាជាអ្នកថែរក្សាកូនទាំង៣នាក់របស់ខ្ញុំ រហូតដល់ពួកគេធំពេញវ័យ ។
ខ្ញុំត្រូវតែថែទាំសុខភាពរបស់ខ្ញុំនិងធ្វើការដូចធម្មតា ។ ខ្ញុំប្រាប់ខ្លួនឯង មិនឱ្យខឹង មិនឱ្យក្រៀមក្រំចិត្ត អញ្ចឹងខ្ញុំអាចរស់នៅបានយូរអង្វែង ។"

(បុរសផ្ទុកមេរោគអេដស៍ជាជនជាតិខ្មែរ អាយុ៣៩ឆ្នាំ)

"ប្តីរបស់ខ្ញុំបានស្លាប់ហើយ ។ នៅសល់តែខ្ញុំទេដែលជាអ្នកថែរក្សាកូនរបស់ខ្ញុំ ។ ខ្ញុំត្រូវតែរឹងប៉ឹងទើបខ្ញុំ អាចថែរក្សាកូនតូចៗរបស់ខ្ញុំបាន ។ ខ្ញុំចង់ឱ្យកូនរបស់ខ្ញុំទៅសាលារៀនដូចអ្នកដទៃដែរ ។ ស្ត្រីផ្សេងទៀតក្នុងសហគមន៍ក៏ជួបប្រទះការលំបាកដូចខ្ញុំដែរ ដូចនេះពួកយើងត្រូវតែរួមគ្នាតស៊ូតទៅទៀត ។ ស្ត្រីទាំងនោះក៏បានជួយខ្ញុំ នៅពេលដែលខ្ញុំធ្លាក់ខ្លួនឈឺផងដែរ ។"

(ស្ត្រីផ្ទុកមេរោគអេដស៍ជាជនជាតិខ្មែរ អាយុ៤៧ឆ្នាំ)

23

## ការរស់នៅដោយភាពវិជ្ជមាន (ត)

មនុស្សដែលឆ្លងមេរោគអេដស៍:
- នៅតែមានតម្លៃដូចមនុស្សដទៃនៅក្នុងសង្គមដែរ
- អាចរស់នៅប្រកបដោយសុខភាពល្អជាច្រើនឆ្នាំ
- អាចបន្តធ្វើការបាន និងជួយរួមចំណែកកសាងសង្គមជាតិ
- មិនត្រូវចុះចាញ់ដោយសារតែការឆ្លងជម្ងឺរបស់ពួកគេទេ
- អាចផ្លាស់ប្តូរស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេឱ្យទៅជាកម្លាំងថ្មីមួយ

អ្នកឆ្លងមេរោគអេដស៍ជាច្រើននាក់ បានផ្លាស់ប្តូរការលំបាករបស់ពួកគាត់ឱ្យទៅជាកម្លាំងថ្មី និងបានទទួលជោគជ័យនៅក្នុងជីវិតរបស់គេ ដែលពួកគេមិនធ្លាប់គិតថានឹងអាចកើតមានពីមុនមក ។

24

## សកម្មភាពទី៤: ប្រតិកម្មខាងផ្លូវចិត្តនិងស្ថានភាពលំបាក

## ប្រតិកម្មខាងផ្លូវចិត្ត

ប្រតិកម្មចំពោះការដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ទាក់ទងទៅនឹង:
- **ភាពមិនប្រាកដប្រជា** អំពី: អនាគតអ្វីដែលនឹងកើតឡើងអ្វីដែលត្រូវធ្វើ អ្នកណាដែលត្រូវប្រាប់
- **ការភ័យខ្លាច** ចំពោះ: ជម្ងឺនិងសេចក្តីស្លាប់ការបដិសេធពីដៃគូគ្រួសារ ឬពីសហគមន៍របស់ពួកគាត់
- តំរូវការសំរាប់**កែច្នៃ** ស្ថានភាពជីវិតថ្មី

ប្រតិកម្មដំបូង
អាចមាន:
-ការរន្ធត់ចិត្ត
-ការបដិសេធ
-កំហឹង

ប្រតិកម្មបន្ទាប់
អាចមាន:
-ភាពសោកសៅ
-ក្តីបារម្ភ
-ការក្រៀមក្រំចិត្ត

26

## ប្រតិកម្មចំពោះរោគវិនិច្ឆ័យនៃមេរោគអេដស៍

មនុស្សដែលឆ្លងមេរោគអេដស៍អាចមាន:
- **ខឹង** នឹងអ្នកដែលចម្លងមេរោគទៅឱ្យគាត់ ឬខឹង សូម្បីតែអ្នកផ្តល់ប្រឹក្សាក៏ដោយ
- **អារម្មណ៍សោកសៅ** ឬ **ពិបាកចិត្ត** ចំពោះ
  - -ការបាត់បង់សុខភាព និងឋានៈ ការផ្លាស់ប្តូរនៃរូបរាងកាយ និង លទ្ធភាពផ្លូវភេទរបស់គាត់
  - -ការមិនអាចមានលទ្ធភាពបន្តពូជ
  - -សេចក្តីស្លាប់នៅពេលខាងមុខ និងការបន្សល់ទុកឱ្យកូននៅកំព្រា
- **កំហុស** ដែលគិតថាខ្លួនឯងជាអ្នកបង្កជម្ងឺនៅក្នុងគ្រួសារ ជាពិសេសចំពោះកូនៗរបស់គាត់ ។

ស្ត្រីអាចរំជួលចិត្តខ្លាំងដោយអារម្មណ៍ខ្វះទីពឹង ឬអស់សង្ឃឹមដែលធ្វើឱ្យគាត់ក្រៀមក្រំទុក្ខព្រួយធ្ងន់ធ្ងរ និងប្រឈមទៅនឹងការធ្វើអត្តឃាត ។

27

## ការដោះស្រាយជាមួយនឹងស្ថានភាពដ៏លំបាក

អ្នកផ្តល់ប្រឹក្សាត្រូវត្រៀមខ្លួនទទួលនូវប្រតិកម្មផ្លូវចិត្ត ជាពិសេសនៅពេលដែលផ្តល់លទ្ធផលតេស្តវិជ្ជមាន៖

- ផ្តល់ពេលវេលាដល់អតិថិជនដើម្បីឱ្យគាត់បានបញ្ចេញនូវអារម្មណ៍របស់គាត់
- ផ្តល់ការគាំទ្រដល់អតិថិជនដើម្បីអោយគាត់បានបញ្ចេញអារម្មណ៍
- បើសិនជាស្ត្រីបង្ហាញពីកំហឹង ឬស្តីបន្ទោសដល់អ្នកផ្តល់ប្រឹក្សា  អ្នកផ្តល់ប្រឹក្សាមិនត្រូវឈ្លោះតបទៅវិញទេ
- បើសិនជាប្រតិកម្មនោះមានសភាពខ្លាំងក្លា  ត្រូវធ្វើការណាត់ជួបជាមួយគាត់ម្តងទៀតនៅពេលក្រោយ ឬបញ្ជូនគាត់ឱ្យទៅជួបជាមួយគ្រូពេទ្យផ្នែកចិត្តសាស្ត្រ ។

28

## ការធ្វើអត្តឃាត  និង  ការក្រៀមក្រំចិត្ត

មនុស្សដែលមានផ្ទុកមេរោគអេដស៍ ងាយប្រឈមនឹងការសម្លាប់ខ្លួនណាស់អ្នកផ្តល់ប្រឹក្សាត្រូវតែ៖

- អាចស្ទង់មើលពីកំរិតនៃការក្រៀមក្រំចិត្ត ឬការបារម្ភហួសហេតុរបស់អតិថិជនដែលអាចឱ្យគាត់ងាយប្រថុយប្រថានក្នុងការសម្លាប់ខ្លួន
- ស្ទង់មើលកំរិតគាំទ្ររបស់គ្រួសារគាត់ ឬការគាំទ្រផ្សេងទៀតដែលមានចំពោះគាត់
- អាចដឹងមានសេវាគាំទ្រផ្លូវចិត្តដល់អតិថិជននៅកន្លែងណាខ្លះ និងដឹងពីរបៀបបញ្ជូនអតិថិជនទៅកាន់កន្លែងនោះ ។

29

## ការប៉ាន់ប្រមាណពីគ្រោះប្រឈមនឹងការធ្វើអត្តឃាត

អ្នកផ្តល់ប្រឹក្សាត្រូវ៖

- ប្រុងប្រយ័ត្នចំពោះអាកប្បកិរិយារបស់ខ្លួនឯង ចំពោះការចង់ធ្វើអត្តឃាតនេះ និងមិនត្រូវមានអាកប្បកិរិយារាំងអតិថិជនមិនឱ្យនិយាយពីរឿងនេះទេ
- ស្ទង់មើលថាតើអតិថិជន មានលេចចេញឡើងនូវការក្រៀមក្រំចិត្ត ឬមានការបារម្ភខ្លាំងដែរឬទេ
- ត្រៀមខ្លួនចំពោះការជជែកគ្នាពីការស្លាប់ដែលចេះតែកើនឡើង
- លើកទឹកចិត្តអតិថិជនឱ្យសំដែងចេញនូវអារម្មណ៍របស់គាត់
- មិនត្រូវខ្លាចនឹងលើកយកនូវប្រធានបទនៃការធ្វើអត្តឃាតមកពិភាក្សានោះទេ
  -សួរអតិថិជនថាតើគាត់ធ្លាប់មានគំនិតចង់ធ្វើអត្តឃាតដែរឬទេ?
  -សួរអតិថិជនថាតើគាត់ធ្លាប់ប៉ុនប៉ងបំផ្លាញជីវិតគាត់ដែរឬទេ?

30

## សកម្មភាពទី៥: ការផ្តល់ប្រឹក្សាដល់ឪពុកម្តាយអំពីលទ្ធផលតេស្តឈាមរបស់កូនគាត់

### ការផ្តល់ប្រឹក្សាដល់ឪពុកម្តាយ អំពីលទ្ធផលតេស្តវិជ្ជមានរបស់កូនគាត់ (១)

- ពិនិត្យឱ្យបានច្បាស់ថា លទ្ធផលតេស្តឈាមរបស់អ្នកប្រាកដជាត្រឹមត្រូវ
- សួរទៅឪពុកម្តាយថា តើពួកគាត់មានសំណួរអ្វីដែរឬទេចំពោះលទ្ធផលតេស្តឈាមរបស់កូនគាត់
- សួរគាត់ តើបានត្រៀមនឹងទទួលលទ្ធផលហើយឬនៅ
- ប្រាប់គាត់ថា លទ្ធផលតេស្តរបស់កូនគាត់គឺ វិជ្ជមាន  មានន័យថាកូនគាត់មានផ្ទុកមេរោគអេដស៍
- ត្រូវរង់ចាំនិងផ្តល់ពេលវេលាដល់ឪពុកម្តាយ ដើម្បីឱ្យគាត់បានបញ្ចេញអារម្មណ៍របស់គាត់
- បង្ហាញលទ្ធផលតេស្តដល់ពួកគាត់
- ពិនិត្យមើលការយល់ដឹងរបស់ឪពុកម្តាយអំពីលទ្ធផលតេស្ត  កែតំរូវការភ័ន្តច្រឡំទាំងឡាយនិងឆ្លើយតបទៅនឹងសំណួរទាំងឡាយណាដែលពួកគាត់បានសួរ។ 32

### ការផ្តល់ប្រឹក្សាដល់ឪពុកម្តាយ អំពីលទ្ធផលតេស្តវិជ្ជមានរបស់កូនគាត់(២)

- ឪពុកម្តាយអាចមានប្រតិកម្មដោយក្តីទុក្ខសោក រន្ធត់ កំហឹង គ្មានជំនឿ បដិសេធ។ ត្រូវរំពឹងទុកជាមុននូវប្រតិកម្មទាំងនេះដែលអាចកើតមាន និងផ្តល់ការគាំទ្រដល់គាត់
- ពន្យល់គាត់ថា ទោះបីជាគ្មានថ្នាំព្យាបាលជម្ងឺអេដស៍ឱ្យជាដាច់ក៏ដោយ ក៏នៅមានវិធីព្យាបាល ជម្ងឺឱកាសនិយមដល់កូនរបស់គាត់ដែរ និងត្រូវនិយាយប្រាប់គាត់អំពីការព្យាបាលដោយ ឱសថប្រឆាំងមេរោគអេដស៍
- ត្រូវបញ្ជាក់ថា កូនគាត់អាចរស់នៅបានច្រើនឆ្នាំ មុននឹងវាធ្លាក់ខ្លួនមានជម្ងឺអេដស៍
- ពិភាក្សារកវិធីដើម្បីឱ្យកូនមានសុខភាពល្អ:
  - ចាក់ថ្នាំបង្ការឱ្យបានគ្រប់ចំនួន
  - ចំណីអាហារមានគុណភាព
  - ព្យាបាលបង្ការជម្ងឺឱកាសនិយម និងប្រញាប់យកទៅមន្ទីរពេទ្យនៅពេលដែលកូននោះឈឺ
- បញ្ជូនកូនទៅគ្លីនិកព្យាបាលជម្ងឺកុមារផ្ទុកមេរោគអេដស៍ដែលនៅជិតបំផុត និងពន្យល់ឪពុកម្តាយអំពីអត្ថប្រយោជន៏ទាំងនេះ។ 33

### ការផ្តល់ប្រឹក្សាដល់ឪពុកម្តាយ អំពីលទ្ធផលតេស្តវិជ្ជមានរបស់កូនគាត់(៣)

- រំលឹកឡើងវិញពីការបង្ការជាសកល
  - ប្រាប់ឪពុកម្តាយឱ្យបានច្បាស់ថា ការប៉ះពាល់ជិតស្និទ្ធរាល់ថ្ងៃជាមួយនឹងកូនមិនមានឆ្លងមេរោគអេដស៏ទេ
  - ពន្យល់ថាការផ្លាស់ប្តូរកន្ទបមិនចាំបាច់ប្រើស្រោមដៃទេ  ប៉ុន្តែចំពោះមុខរបួសចំហ ឬដំបៅគួរតែបិទឱ្យជិតហើយត្រូវពាក់ស្រោមដៃដើម្បីសំអាតឈាមដែលខ្ទាត
- ពិនិត្យរកមើល តើមានសមាជិកគ្រួសារណាខ្លះទៀតដែលអាចឆ្លង ហើយរៀបចំឱ្យគេបានទទួលការប្រឹក្សាយោបល់ផង
- កំណត់រកបណ្តាញគាំទ្រសំរាប់គ្រួសារដែលមានផ្ទុកមេរោគអេដស៏ និង បញ្ជូនទៅក្រុមថែទាំតាមផ្ទះ ឬក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៏ ដោយមានការអនុញ្ញាតពីឪពុកម្តាយ
- ធ្វើការបញ្ជាក់ពីការប្រាប់ពីស្ថានភាពផ្ទុកមេរោគអេដស៏ដល់អ្នកដទៃ
- និយាយអំពីការរក្សាការសម្ងាត់នៅក្នុងប្រព័ន្ធថែទាំសុខភាព
- បន្តផ្តល់ព័តិមាននិងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៏ នៅរាល់ពេលមកជួបពិនិត្យសុខភាព។ 34

# សកម្មភាពទី៦: ករណីសិក្សា: ការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាមដោយប្រើសៀវភៅរូបភាព

## សង្ខេបសកម្មភាព

» គោលបំណងនៃសកម្មភាពនេះ គឺដើម្បីអនុវត្តជំនាញផ្តល់ប្រឹក្សាក្រោយតេស្តឈាមដោយប្រើសៀវភៅរូបភាព

### ការរៀបចំ

រំលឹកអំពីជំនាញបង្ហាញសៀវភៅរូបភាពជាមូលដ្ឋាន និងជំនាញសម្របសម្រួលជាក្រុម ដែលអ្នកបានរៀននៅម៉ូឌុលទី១០

### សកម្មភាព (៩០នាទី)

សូមបើកតារាងដែលស្ថិតនៅទល់មុខ

### ធ្វើការសង្ខេប (៦០នាទី)

គ្រូនឹងដឹកនាំការពិភាក្សាអំពីការសំដែងតួម្តងមួយៗ។ ចំពោះការសំដែងៗតួនីមួយៗ គ្រូនឹងសួរសំណួរដូចតទៅ:

- តើអ្នកមានអារម្មណ៍យ៉ាដូចម្តេចដែរ នៅពេលដើរតួនេះ?
- តើអ្នកសំដែងបានល្អដែរឬទេ? (សម្រាប់អ្នកផ្តល់ប្រឹក្សា) ឬ តើអ្នកផ្តល់ប្រឹក្សាសំដែងបានល្អដែរឬទេ? (សម្រាប់អតិថិជន)
- តើអ្នកឃើញមានការលំបាកជាពិសេសត្រង់កន្លែងណាខ្លះ?
- តើវគ្គផ្តល់ប្រឹក្សាត្រង់ណាដែលប្រសើរជាងគេ?

| សកម្មភាព: ៩០នាទី |
|---|
| ■ គ្រូចែកសិក្ខាកាមជាក្រុមដែលមានគ្នាពី៤-៥នាក់។ សមាជិកម្នាក់ក្នុងក្រុមនឹងដើរតួជាអ្នកផ្តល់ប្រឹក្សា និងម្នាក់ឬពីរនាក់ទៀតនឹងដើរតួជាអតិថិជន (ករណីខ្លះមានប្តីប្រពន្ធចូលរួម)។ អ្នកផ្សេងទៀតត្រូវដើរតួជាអ្នកសង្កេតការណ៍ |
| ■ ត្រូវប្រាកដថា ក្រុមនីមួយៗមានសេណារីយ៉ូសម្រាប់សំដែង មានបញ្ជីផ្ទៀងផ្ទាត់សម្រាប់ផ្តល់ប្រឹក្សាក្រោយតេស្ត មានក្រដាស់វាយតម្លៃ និងមានសៀវភៅរូបភាពសម្រាប់ផ្តល់ប្រឹក្សាក្រោយតេស្តឈាម |
| ■ សូមរំលឹកឡើងវិញនូវជំនាញបង្ហាញ ដែលអ្នកបានរៀនរួចហើយនៅម៉ូឌុលទី១០ |
| ■ ត្រូវចាប់ផ្តើមសំដែងអំពីលទ្ធផលតេស្តអវិជ្ជមានជាមុនសិន បន្ទាប់មកទើបសំដែងអំពីលទ្ធផលតេស្តដទៃទៀត |
| ■ អ្នកដែលត្រូវសំដែងតួជា" អតិថិជន" ត្រូវធ្វើឱ្យដូចពិតៗតាមដែលអាចធ្វើបានដើម្បីឱ្យ "អ្នកផ្តល់ប្រឹក្សា " មានឱកាសអនុវត្តជំនាញរបស់គាត់បាន |
| ■ អ្នកសង្កេតការណ៍អាចជួយបាន ប្រសិនជាមាននរណាម្នាក់ភ្លេចសកម្មភាព |
| ■ អ្នកផ្តល់ប្រឹក្សាត្រូវប្រើសៀវភៅរូបភាព ដើម្បីជាជំនួយក្នុងការផ្តល់ប្រឹក្សាក្រោយតេស្ត។ "អតិថិជន" ត្រូវឆ្លើយតបឱ្យបានសមស្របទៅតាមស្ថានភាព |
| ■ បន្ទាប់ពីវគ្គប្រឹក្សានីមួយៗ សិក្ខាកាមត្រូវពិភាក្សានៅក្នុងក្រុមតូចដដែលចំពោះសំណួរ:<br>❖ តើវគ្គផ្តល់ប្រឹក្សានោះដំណើរការយ៉ាងដូចម្តេចខ្លះ?<br>❖ តើមានចំណុចណាមួយដែលពិបាកសំដែងដែរឬទេ? តើអ្នកដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច?<br>❖ តើសៀវភៅរូបភាពបានជួយការផ្តល់ប្រឹក្សាយ៉ាងណាខ្លះ? តើវាមានចំណុចខ្លាំងអ្វីខ្លះ? តើបុគ្គលិកសុខាភិបាលត្រូវការជំនាញអ្វីខ្លះ ដើម្បីឱ្យការប្រើប្រាស់សៀវភៅរូបភាពកាន់តែល្អប្រសើរជាងមុន? |
| ■ នៅពេលដែលក្រុមនីមួយៗបានសម្តែងគ្រប់តួអង្គអស់ហើយ ចូលមកពិភាក្សាក្នុងក្រុមធំវិញ ដើម្បីសង្ខេបសកម្មភាព។ |

## សកម្មភាពទី៦: ល្បែងដើរតួ: ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

| ល្បែងដើរតួទី១: លទ្ធផលតេស្តអវិជ្ជមាន |
| --- |
| "ស៊ីណា"មានអាយុ២៥ឆ្នាំ។ ថ្មីៗនេះនាងបានដឹងថាប្តីរបស់នាងមានផ្ទុកមេរោគអេដស៍។ សុខភាពប្តីរបស់នាងនៅល្អនៅឡើយ ហើយគាត់ចង់គេងជាមួយនាង។ "ស៊ីណា"កំពុងមានផ្ទៃពោះកូនទី២។ កូនស្រីរបស់នាងដែលមានអាយុ៥ឆ្នាំ ជាក្មេងដែលរីករាយនិងមានសុខភាពល្អ។ ក្រោយពីបានទៅពិនិត្យផ្ទៃពោះលើកដំបូង នាងបានឮអំពីសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ហើយនាងក៏បានសម្រេចចិត្តធ្វើតេស្ត។ មុនដំបូងនាងបានទៅផ្ទះដើម្បីឱ្យប្តីនាងមកជាមួយនាង។ ប៉ុន្តែគាត់បានបដិសេធហើយនិយាយថាគាត់បានឆ្លងមេរោគអេដស៍រួចទៅហើយ។ "ស៊ីណា"មិនដឹងថាតើត្រូវធ្វើយ៉ាងដូចម្តេចជាមួយនឹងប្តីរបស់នាង។ នាងមានការស្ទាក់ស្ទើរក្នុងការរួមភេទជាមួយប្តីនាងដោយភ័យខ្លាចថានាងនឹងអាចឆ្លងមេរោគអេដស៍ដែរ។ តែប្រសិនជានាងបដិសេធទាំងស្រុងនោះ ប្តីរបស់នាងប្រហែលអាចខឹងនឹងនាង។ នាងបានមកធ្វើតេស្តឈាមរកមេរោគអេដស៍នៅព្រឹកនេះ។ ហើយឥឡូវនេះនាងបានត្រឡប់មកវិញដើម្បីទទួលយកលទ្ធផលរបស់នាង។ |

| ល្បែងដើរតួទី២: លទ្ធផលតេស្តអវិជ្ជមាន |
| --- |
| "វិសិទ្ធ" និង "ចាន់ដា" បានរៀបការអស់រយៈពេល២ឆ្នាំហើយ។ "វិសិទ្ធ" ធ្វើការនៅក្នុងភោជនីយដ្ឋានមួយនៅភ្នំពេញ។ ចំណែកឯប្រពន្ធរបស់គាត់ធ្វើការនៅរោងចក្រកាត់ដេរ។ មុនពេលបានជួបគ្នា "វិសិទ្ធ" ជួបបញ្ហាលំបាកយ៉ាងខ្លាំងអស់រយៈពេលជាច្រើនឆ្នាំ។ ពេលខ្លះគាត់ប្រើប្រាស់ថ្នាំញៀន ប៉ុន្តែគាត់មិនដែលឈឺទេ។ "ចាន់ដា" ដឹងអំពីដំណើរជីវិតរបស់ប្តីនាង ប៉ុន្តែមិនដែលមានការព្រួយបារម្ភអ្វីទេពីមុនមក។ ឥឡូវនេះ "ចាន់ដា" មានផ្ទៃពោះកូនដំបូង ហើយគូស្វាមីភរិយានេះបានទៅកាន់សេវាថែទាំផ្ទៃពោះជាមួយគ្នា ហើយពួកគេសម្រេចចិត្តទទួលការផ្តល់ប្រឹក្សាយោបល់និងធ្វើតេស្តឈាមជាមួយគ្នា។ |

| ល្បែងដើរតួទី៣: លទ្ធផលតេស្តវិជ្ជមានដូចគ្នា |
| --- |
| "សម្ផស្ស" និង "ឆាយា"បានរៀបការអស់រយៈពេល១០ឆ្នាំហើយនិងមានកូន៣នាក់។ ឥឡូវនេះ នាងមានផ្ទៃពោះកូនទី៤និងស្ថិតក្នុងត្រីមាសទី២នៃគភ៌។ កាលពីឆ្នាំទៅ ប្តីរបស់នាងដែលជាមន្ត្រីរដ្ឋាភិបាលត្រូវបានចាត់ឱ្យទៅធ្វើការនៅខេត្តបាត់ដំបងអស់រយៈពេល៦ខែ។ ក្នុងអំឡុងពេលនោះ គាត់មានទំនាក់ទំនងផ្លូវភេទយ៉ាងយូរជាមួយស្ត្រីម្នាក់ដែលក្រោយមកគាត់ដឹងថានាងមានផ្ទុកមេរោគអេដស៍។ ប្រពន្ធ "ឆាយា" បានដឹងពីរឿងនេះនិងមានការព្រួយបារម្ភពីជីវិតរបស់នាងនិងជីវិតរបស់កូននាង។ "ឆាយា" បានយល់ព្រមមកកាន់គ្លីនិកជាមួយនាង ហើយពួកគេបានទទួលការប្រឹក្សាយោបល់មុនពេលធ្វើតេស្តឈាមជាមួយគ្នា។ |

## សកម្មភាពទី៦: ល្បែងដើរតួ: ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

| ល្បែងដើរតួទី៤: លទ្ធផលតេស្តមិនស្របគ្នា ( "ចាន់ សុក" មានលទ្ធផលតេស្តវិជ្ជមាន "មីង" មានលទ្ធផលតេស្តអវិជ្ជមាន) |
| --- |
| "ចាន់ សុក" ធ្វើជាទាហានអស់រយៈពេល៥ឆ្នាំ។ គាត់បានរៀបការជាមួយ "មីង" និងមានកូន២នាក់។ កូនបងមានអាយុ៥ឆ្នាំនិងកូនប្អូនមានអាយុ២ឆ្នាំ។ ឥឡូវនេះ "មីង" មានផ្ទៃពោះម្តងទៀត។ "ចាន់ សុក" បានយល់ដឹងអំពីមេរោគអេដស៍-ជំងឺអេដស៍ច្រើន តាមរយៈមិត្តភ័ក្តិរបស់គាត់នៅក្នុងជួរកងទ័ព។ គាត់ដឹងថា មនុស្សច្រើនតែឆ្លងមេរោគអេដស៍តាមការរួមភេទ។ គាត់ក៏បានឮថា មិត្តភ័ក្តិរបស់គាត់មួយចំនួនឆ្លងមេរោគអេដស៍ពីស្រីពេស្យា។ ពីមុនគាត់ធ្លាប់បានទៅផ្ទះបនជាមួយមិត្តភ័ក្តិរបស់គាត់។ ទោះបីជាយ៉ាងណាក៏ដោយ ថ្មីៗនេះគាត់ចូលចិត្តទៅរកស្រីៗនៅក្នុងភូមិជិតៗឬស្រីដែលគាត់បានជួបក្នុងពេលបុណ្យទាន។ កាលពីអាទិត្យមុន "មីង" បានមកផ្ទះប្រាប់ប្តីថា នាងបានទៅពិនិត្យផ្ទៃពោះនៅថ្ងៃនោះ ហើយបានដឹងថាមានការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍។ នាងត្រូវបានណែនាំឱ្យនាំប្តីរបស់នាងមកជាមួយ។ គាត់យល់ព្រមមកកាន់គ្លីនិកជាមួយនាងដោយស្ទាក់ស្ទើរ។ ប្តីប្រពន្ធទាំងពីរក៏បានទទួលការផ្តល់ប្រឹក្សាយោបល់និងធ្វើតេស្តឈាមនៅពេលព្រឹកនេះ និងបានមកទទួលលទ្ធផលតេស្ត។ |

| ល្បែងដើរតួទី៥: លទ្ធផលតេស្តវិជ្ជមាន |
| --- |
| "បុប្ផា"ធ្វើការជាស្ត្រីបំរើស្រាបៀរអស់រយៈពេលប្រហែល៥ឆ្នាំហើយ។ នាងបានទទួលប្រាក់ខែប្រហែល៤០ដុល្លារក្នុង១ខែ។ នាងមានការលំបាកក្នុងការរស់នៅដោយពឹងផ្អែកលើប្រាក់ខែនេះណាស់។ ជារៀងរាល់ថ្ងៃ នាងបានឃើញមិត្តភ័ក្តិរបស់នាងរកចំណូលក្រៅដោយសារការទៅដេកជាមួយភ្ញៀវ។ មិត្តភ័ក្តិរបស់នាងមួយចំនួនទទូចឱ្យនាងធ្វើដូចនេះដែរដើម្បីបានចំណូលគ្រាន់បើជាងនេះ ហើយនាងក៏បានសម្រេចចិត្តធ្វើតាមពួកគេ។ នាងឃើញថា វាជាការល្អក្នុងការរកលុយតាមវិធីនេះ។<br>នាងមិនសូវបានប្រើស្រោមអនាម័យជាមួយអតិថិជនរបស់នាងទេនៅពេលដែលនាងរួមភេទ ពីព្រោះអតិថិជនរបស់នាងមិនចង់ប្រើវា ហើយនាងគិតផងដែរថាពួកគេជាអ្នកមានគេមិនមានផ្ទុកមេរោគអេដស៍ទេ។ នាងក៏គ្មានអំណាចចរចាជាមួយអតិថិជនទេ ក្នុងពេលដែលនាងនៅតែពីរនាក់ជាមួយនឹងភ្ញៀវ។ នៅថ្ងៃមួយ នាងបានឃើញមានអ្វីចំឡែកម្យ៉ាងនៅនឹងប្រដាប់ភេទរបស់នាង ហើយវាធ្វើឱ្យមានការហូរឈាមនៅពេលរួមភេទ។ នាងមានការភ័យខ្លាចយ៉ាងខ្លាំង ហើយបានទៅជួបជាមួយគ្រូពេទ្យ។ ក្នុងពេលពិនិត្យជំងឺគ្រូពេទ្យបានផ្តល់ការព្យាបាលនិងអប់រំដល់នាង។ ទោះបីជាយ៉ាងណាក៏ដោយ នាងមិនអាចធ្វើតាមដំបូន្មានរបស់គ្រូពេទ្យទេ ពីព្រោះនាងត្រូវការរកចំណូលក្រៅ។<br>ថ្មីៗនេះ នាងបានដឹងថានាងមានផ្ទៃពោះ។ នាងមិនដែលមានកូនទេ ប៉ុន្តែនាងបានសម្រេចចិត្តទៅកាន់មណ្ឌលសុខភាពមួយក្នុងតំបន់ ដោយសារតែនាងឮថាមានសេវាធ្វើតេស្តឈាមរកមេរោគអេដស៍។ នាងមានផ្ទៃពោះទើបតែ២ខែប៉ុណ្ណោះ ប៉ុន្តែនាង មានការច្របូកច្របល់និងព្រួយបារម្ភណាស់។ ព្រឹកនេះនាងបានធ្វើតេស្តឈាមរកមេរោគអេដស៍។ |

| សកម្មភាពទី៦: លទ្ធផលតេស្តវិជ្ជមាន |
| --- |
| "រដ្ឋា" អាយុ២៨ឆ្នាំមានផ្ទៃពោះកូនទី៣។ នាងជាអ្នកលក់ផ្លែឈើនៅក្នុងផ្សារមួយនៅភ្នំពេញ។ ប្តីរបស់នាងជាមន្ត្រីរាជការធ្វើការនៅក្រសួងពាណិជ្ជកម្ម។ ប្តីគាត់តែងធ្វើដំណើរទៅធ្វើការងារនៅខេត្តជាញឹកញាប់។ នៅទីនោះ មិត្តភ័ក្តិនិងមិត្តរួមការងាររបស់គាត់តែងតែអញ្ជើញគាត់ទៅញុំាអាហារពេលល្ងាច។ ការហូបចុកនិងផឹកស៊ីគឺជាសកម្មភាពកំសាន្តដែលជាចំណូលចិត្តបំផុតរបស់គាត់។ លើសពីនេះ មិត្តរបស់គាត់តែងតែចេញលុយឱ្យគាត់ ជាហេតុធ្វើឱ្យគាត់មានឱកាសរកសេវាផ្លូវភេទដោយមិនបាច់អស់ប្រាក់។ "រដ្ឋា" មានការមន្ទិលសង្ស័យនិងព្រួយបារម្ភពីឥរិយាបថរបស់ប្តីនាង នៅពេលដែលគាត់នៅធ្វើការឯខេត្ត។ ទោះបីជាយ៉ាងណាក៏ដោយ នាងមិនអាចធ្វើអ្វីឱ្យបានច្រើនជាងនេះទេ។ នៅផ្ទះពួកគេមិនដែលប្រើស្រោមអនាម័យទេ។ "រដ្ឋា" ដឹងថាការប្រើប្រាស់ស្រោមអនាម័យអាចបង្ការការឆ្លងមេរោគអេដស៍បាន។ ប៉ុន្តែនាងមិនអាចផ្តើមប្រើប្រាស់វាជាមួយប្តីរបស់នាងទេ ព្រោះនាងគិតថា ស្រោមអនាម័យគេប្រើតែជាមួយស្រីរកស៊ីផ្លូវភេទ។ បើនាងនិយាយរឿងនេះជាមួយប្តី ខ្លាចប្តីយល់ថាជាសញ្ញាមួយនៃការមិនទុកចិត្តនិងមិនសប្បាយចិត្ត។ នាងបានមកកាន់សេវាថែទាំផ្ទៃពោះដើម្បីពិនិត្យសុខភាព។ ក្រោយពីបានទទួលព័ត៌មានអំពីមេរោគអេដស៍/ជំងឺអេដស៍ នាងក៏សម្រេចចិត្តធ្វើតេស្តឈាមរកមេរោគអេដស៍ពីព្រោះនាងមានការព្រួយបារម្ភពីកូនរបស់នាង។ |

| ល្បែងដើរតួទី៧: កុមារមានលទ្ធផលតេស្តវិជ្ជមាន (មុន្នីមានផ្ទុកមេរោគអេដស៍) |
| --- |
| "ប៊ុនថា" និង "វណ្ណី" ដឹងថាពួកគេទាំង២នាក់មានផ្ទុកមេរោគអេដស៍។ ឆ្នាំមុន "ប៊ុនថា" បានធ្វើរោគវិនិច្ឆ័យដឹងថាមានជំងឺរបេង និងក្រោយមកបានធ្វើតេស្តឈាមឃើញថាមានផ្ទុកមេរោគអេដស៍។ ឥឡូវនេះ "វណ្ណី" ជាប្រពន្ធមានផ្ទៃពោះកូនទី៣ដែលមានអាយុ៣ត្រីមាសហើយ។ នាងកំពុងតែទទួលការព្យាបាលបង្ការដោយឱសថប្រឆាំងមេរោគអេដស៍។ កាលពី៦សប្តាហ៍មុន នៅពេលដែលនាងមកពិនិត្យផ្ទៃពោះលើកដំបូង នាងបានធ្វើតេស្តឈាម។ លទ្ធផលតេស្តរបស់នាងគឺ វិជ្ជមាន ហើយនាងត្រូវបានបញ្ជូនទៅកាន់សេវាព្យាបាលនិងថែទាំបន្តក្នុងតំបន់ដែលនាងរស់នៅដែលនៅទីនោះគេបានរាប់កោសិកាCD4 ឃើញមាន៤០០/មម៣។<br>"មុន្នី"ជាកូនតូចរបស់ពួកគេមានអាយុ៤ឆ្នាំ។ ថ្មីៗនេះវាមិនសូវស្រួលខ្លួនដោយសារមានជំងឺរាកនិងក្អកជាប្រចាំ។ ឆ្មបម្នាក់នៅកន្លែងពិនិត្យផ្ទៃពោះបានណែនាំ "វណ្ណី" ឱ្យនាំ "មុន្នី" ទៅទទួលការប្រឹក្សាយោបល់និងធ្វើតេស្តឈាម។ នាងបាននាំកូនមកធ្វើតេស្តឈាមកាលពីព្រឹក។ ឥឡូវនេះ "ប៊ុនថា" និង "វណ្ណី" បានត្រឡប់មកទទួលយកលទ្ធផលតេស្តឈាមរបស់កូនគាត់។ |

## សកម្មភាពទី៧: លំហាត់: រយៈពេលចំហនៃមេរោគ

- គ្រូនឹងស្នើឱ្យអ្នកស្រមៃថា ខ្លួនអ្នកកំពុងតែផ្ដល់ប្រឹក្សាក្រោយតេស្តដល់ស្ត្រីមានផ្ទៃពោះម្នាក់ ដែលទើបតែប្រឈមនឹងមេរោគអេដស៍ក្នុងពេលថ្មីៗនេះ
- លទ្ធផលតេស្តឈាមរបស់អតិថិជនគឺអវិជ្ជមាន ក៏ប៉ុន្តែអ្នកត្រូវតែដឹងនិងត្រូវពន្យល់ទៅនាងថា នាងអាចកំពុងតែស្ថិតនៅក្នុងរយៈពេលចំហនៃមេរោគអេដស៍
- អ្នកត្រូវប្រាប់នាងឱ្យត្រឡប់មកធ្វើតេស្តឈាមម្តងទៀតនៅ៣ខែក្រោយ ដើម្បីធ្វើតេស្តឈាមជាថ្មីម្តងទៀត
- ចូរអ្នកពិនិត្យទៅតារាងនិងសូមសរសេរកាលបរិច្ឆេទ សម្រាប់ការណាត់ជួបជាមួយស្ត្រីម្តងទៀត ដើម្បីធ្វើតេស្តឈាមជាថ្មីម្តងទៀតសម្រាប់ឧទាហរណ៍នីមួយៗ
- សូមពិនិត្យថ្ងៃណាត់ម្តងទៀតដើម្បីឱ្យប្រាកដថា អ្នកមិនបានណាត់ចំថ្ងៃសម្រាកឬថ្ងៃបុណ្យទេ

| | ថ្ងៃខែឆ្នាំធ្វើតេស្តលើកទី១ | ថ្ងៃខែឆ្នាំធ្វើតេស្តលើកទី២ |
|---|---|---|
| ១ | ៧ មិថុនា ២០០៧ | |
| ២ | ២ វិច្ឆិកា ២០០៧ | |
| ៣ | ២៨ មីនា ២០០៧ | |
| ៤ | ១៤-០៩-២០០៧ | |
| ៥ | ១០-០៧-២០០៧ | |
| ៦ | ៣០-០៥-២០០៧ | |

## ចំណុចគន្លឹះ

**ម៉ូឌុលទី១១: ចំណុចគន្លឹះ**

- ការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមមានសារៈសំខាន់ណាស់សម្រាប់ស្ត្រីគ្រប់រូប ទោះបីជាលទ្ធផលតេស្តវិជ្ជមានក្តី ឬអវិជ្ជមានក្តី
- សម្រាប់ស្ត្រីដែលអវិជ្ជមានមេរោគអេដស៍ ត្រូវផ្តោតលើសារៈសំខាន់នៃការបង្ការការឆ្លងមេរោគអេដស៍សម្រាប់ពេលអនាគត
- សម្រាប់ស្ត្រីដែលបានឆ្លងមេរោគអេដស៍ សូមផ្ដល់ការគាំទ្រផ្នែកផ្លូវចិត្ត ផ្ដល់ព័ត៌មានពីសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងការបញ្ជូនស្ត្រីទៅកាន់សេវាព្យាបាលជំងឺឱកាសនិយមនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងផ្ដល់សេវាគាំទ្រដល់គាត់
- នៅពេលផ្ដល់ប្រឹក្សាក្រោយតេស្ត អ្នកផ្ដល់ប្រឹក្សាគួរលើកទឹកចិត្តនិងគាំទ្រឱ្យស្ត្រីគ្រប់រូបមានចិត្តក្លាហាននឹងប្រាប់ពីស្ថានភាពផ្ទុកមេរោគអេដស៍ឱ្យប្តីរបស់ខ្លួន ឬសាច់ញាតិដែលជិតស្និទ្ធបំផុតបានដឹង ។

## ឧបសម្ព័ន្ធទី១១

| បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមៈ លទ្ធផលតេស្តអវិជ្ជមាន |
|---|
| ១-កិច្ចស្វាគមន៍និងការសំដែងគារវកិច្ចចំពោះអតិថិជន<br>២-ផ្ទៀងលេខកូដ PMTCT របស់អតិថិជន និងលេខកូដនៃលទ្ធផលតេស្តឈាមក្នុងស្រោមសំបុត្រ ឱ្យឃើញថាដូចគ្នាដែរឬទេ<br>៣-រំលឹកឡើងវិញត្រួសៗ ពីអ្វីដែលបានពិភាក្សាក្នុងអំឡុងពេលមុនធ្វើតេស្តឈាម<br>៤-ស្ទាបស្ទង់ឡើងអំពីអារម្មណ៍របស់អតិថិជនចំពោះការទទួលលទ្ធផលតេស្ត និងអំពីលទ្ធភាពអាចសម្របខ្លួនជាមួយលទ្ធផលតេស្ត<br>៥-សួរអតិថិជនអំពីការត្រៀមខ្លួនរបស់គាត់ក្នុងការអនុញ្ញាតឱ្យអ្នកផ្ដល់ប្រឹក្សាបើកលទ្ធផលតេស្ត<br>៦-ប្រសិនជាអតិថិជនយល់ព្រម អ្នកផ្ដល់ប្រឹក្សាបើកស្រោមសំបុត្រ  អានលទ្ធផលតេស្តនិងពន្យល់លទ្ធផលដល់អតិថិជន<br>៧-ទុកពេលឱ្យអតិថិជនបញ្ចេញប្រតិកម្មនិងអារម្មណ៍ និងសួរសំណួរ |
| ការប្រើសៀវភៅរូបភាពសម្រាប់ការផ្ដល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមដល់ស្ត្រី គ្មានផ្ទុកមេរោគអេដស៍ ដើម្បីផ្ដល់សារដូចតទៅនេះ |
| ៨-រំលឹកពីអត្ថន័យនៃលទ្ធផលតេស្ត<br>៩-រាវរករយៈពេលចំហនៃមេរោគនិងលើកទឹកចិត្តដល់អ្នកដែលមានឥរិយាបថប្រឈមមុខនឹងការឆ្លងថ្មីៗ ឱ្យត្រឡប់មកធ្វើតេស្តបញ្ជាក់សារឡើងវិញនៅ៣ខែក្រោយ<br>១០-ប្រសិនបើស្ត្រីមកតែម្នាក់ឯង ពិភាក្សាអំពីការប្រាប់លទ្ធផលតេស្តឱ្យអ្នកដទៃដឹងនិងការធ្វើតេស្តឈាមដល់ប្ដី<br>១១-ជជែកពិភាក្សាអំពីលទ្ធផលតេស្តដៃគូដែលមិនស្របគ្នា<br>១២-ពិភាក្សាអំពីផែនការកាត់បន្ថយគ្រោះប្រឈមមុខ ដើម្បីរក្សានូវភាពមិនឆ្លងមេរោគអេដស៍<br>ក. ពង្រឹងសារ A, B, C<br>ខ. ផ្ដល់នូវការអប់រំអំពីការប្រើប្រាស់ស្រោមអនាម័និងបង្ហាញពីរបៀបប្រើវា<br>គ. ផ្ដល់ស្រោមអនាម័យដល់អតិថិជនដែលមានបំណងប្រើវា<br>១៣.បញ្ជាក់អំពីសារៈសំខាន់នៃការរក្សាខ្លួនមិនឱ្យឆ្លងមេរោគអេដស៍ ក្នុងពេលមានផ្ទៃពោះនិងពេលបំបៅដោះកូន<br>១៤.លើកទឹកចិត្តស្ត្រីឱ្យបំបៅកូនដោយទឹកដោះ<br>១៥. ផ្ដល់ព័តិមានឬបញ្ជូនអតិថិជនទៅរកសេវាសមស្រប ដែលទាក់ទង ដូចជាសេវាពន្យារកំណើត គ្លីនិកជំងឺកាមរោគ<br>១៦.ផ្ដល់ឯកសារព័តិមានសម្រាប់អប់រំដល់ស្ត្រី<br>១៧.ស្នើឱ្យនាងមានសំណួរឬសួរអំពីការបារម្ភរបស់នាង<br>១៨. ជំរុញឱ្យស្ត្រីមានសេចក្តីក្លាហាននឹងត្រឡប់មកទៀតនៅពេលណាដែលនាងត្រូវការ |

| |
|---|
| បន្ថែមពីលើនេះ ពិភាក្សាចំណុចដូចតទៅនេះឱ្យបានសមស្រប |
| ១៩. លើកទឹកចិត្តស្ត្រីឱ្យនាំដៃគូមកទទួលសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់<br>២០. ជំនាញចរចាអំពីសុវត្ថិភាពនៃការរួមភេទ |
| **បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម: លទ្ធផលតេស្ត វិជ្ជមាន** |
| ១. កិច្ចស្វាគមន៍និងការសំដែងគារវកិច្ចចំពោះអតិថិជន<br>២. ផ្ទៀងលេខកូដ **PMTCT** របស់អតិថិជន និងលេខកូដនៃលទ្ធផលតេស្តឈាមក្នុងស្រោមសំបុត្រឱ្យឃើញថាដូចគ្នា<br>៣. រំលឹកឡើងវិញពីអ្វីដែលបានពិភាក្សាក្នុងអំឡុងពេលមុនធ្វើតេស្តឈាម<br>៤. ស្ទាបស្ទង់ឡើងវិញពីអារម្មណ៍របស់អតិថិជនចំពោះការទទួលលទ្ធផលតេស្ត និងពីលទ្ធភាពអាចសម្របខ្លួនជាមួយលទ្ធផលតេស្ត<br>៥. សួរអតិថិជនពីការត្រៀមខ្លួនរបស់គាត់ក្នុងការអនុញ្ញាតឱ្យអ្នកផ្តល់ប្រឹក្សាបើកលទ្ធផលតេស្ត<br>៦. ប្រសិនជាអតិថិជនយល់ព្រម អ្នកផ្តល់ប្រឹក្សាបើកស្រោមសំបុត្រអានលទ្ធផលតេស្តនិងពន្យល់លទ្ធផលដល់អតិថិជន<br>៧. ទុកពេលឱ្យអតិថិជនបញ្ចេញប្រតិកម្មនិងអារម្មណ៍ និងសួរសំណួរ |
| ការប្រើសៀវភៅរូបភាពសម្រាប់ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមដល់ស្ត្រីគ្មានផ្ទុកមេរោគអេដស៍ ដើម្បីផ្តល់សារដូចតទៅនេះ: |
| ៨. រំលឹកអំពីអត្ថន័យនៃលទ្ធផលតេស្តនិងការពាក់ព័ន្ធរបស់វា<br>៩. លើកទឹកចិត្តឱ្យអតិថិជនបញ្ចេញនូវអារម្មណ៍របស់គាត់  រាវរកបញ្ហានិងគាំទ្រដល់គាត់<br>១០. ពិភាក្សាអំពីអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន **PMTCT** និងអំពីសារៈសំខាន់របស់វា<br>ក-ការបង្ការនិងការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ **OI-ART**<br>ខ-ជម្រើសនៃការចិញ្ចឹមកូន<br>គ-ការសម្រាលកូននៅក្នុងមន្ទីរពេទ្យដែលមានសេវា **PMTCT**<br>ឃ-អាហារូបត្ថម្ភគ្រប់គ្រាន់ |

| |
|---|
| ង-បញ្ជាក់អំពីការរស់នៅប្រកបដោយភាពវិជ្ជមាន<br>ច-ពិភាក្សាអំពីសេវាថែទាំព្យាបាលបែបវេជ្ជសាស្ត្រនិងសេវាគាំទ្រ ។ ប្រសិនជាមានការយល់ព្រមពីអតិថិជន បញ្ជូនស្ត្រីទៅទទួលសេវា**OI-ART**ដែលនៅជិតបំផុត ដើម្បីវាយតម្លៃពីលទ្ធភាពទទួលការព្យាបាលដោយ**OI-ART**<br>១១.ប្រសិនជាស្ត្រីមកតែម្នាក់ឯងទេ  អ្នកផ្តល់ប្រឹក្សានិយាយអំពីការប្រាប់លទ្ធផលតេស្តដល់អ្នកដទៃ  ការធ្វើតេស្តឈាមដល់ដៃគូនិងវិធីបង្ការមេរោគអេដស៍<br>១២.និយាយអំពីលទ្ធផលតេស្តមិនស្របគ្នារបស់ប្តីប្រពន្ធ<br>១៣.កំណត់រកប្រភពនៃក្តីសង្ឃឹមសម្រាប់អតិថិជន  ដូចជាគ្រួសារ  មិត្តភ័ក្តិ  សេវានៅតាមសហគមន៍ ការគាំទ្រផ្លូវចិត្ត និងផ្តល់ការព្យាបាល ។ ធ្វើការបញ្ជូននៅពេលសមស្រប<br>១៤.ផ្តល់ព័តិមានអំពីសេវាដែលជាប់ទាក់ទងគ្នាឬធ្វើការបញ្ជូនអតិថិជនទៅសេវាទាំងនោះដូចជា សេវាពន្យារកំណើត  គ្លីនិកជំងឺកាមរោគជាដើម<br>១៥. ប្រសិនជានាងមានកូនហើយ និយាយឱ្យនាងយកកូនមកពិនិត្យឈាម<br>១៦. សួរអតិថិជនមានសំណួរឬការព្រួយបារម្ភដែរឬទេ ។ ផ្តល់ព័តិមានសម្រាប់ឱ្យអតិថិជនទាក់ទងនៅពេលមានបញ្ហាកើតឡើង<br>១៧. ផ្តល់ឯកសារព័តិមានសម្រាប់អប់រំដល់ស្ត្រី<br>១៨. រំលឹកដល់ម្តាយព្រមទាំងស្វារថា គាត់អាចមកទទួលការប្រឹក្សាយោបល់បានគ្រប់ពេលក្នុងខណៈដែលគាត់នៅមានផ្ទៃពោះ ដើម្បីជួយគាត់ក្នុងការធ្វើផែនការសម្រាប់ពេលអនាគតនិងទទួលបានសេវាថែទាំគ្រប់ជ្រុងជ្រោយ |
| បន្ថែមពីលើនេះ ពិភាក្សាចំណុចដូតទៅនេះឱ្យបានសមស្រប |
| ១៩.  លើកទឹកចិត្តស្ត្រីឱ្យនាំដៃគូមកទទួលសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់<br>២០.  រៀបចំផែនការកាត់បន្ថយគ្រោះប្រឈម ដែលក្នុងនោះមានការបង្ការការចម្លងមេរោគអេដស៍ទៅដៃគូដែលមិនទាន់ឆ្លងមេរោគអេដស៍ ឬដៃគូដែលមិនទាន់ធ្វើតេស្តឈាម និងបង្ការការឆ្លងមេរោគអេដស៍សារចុះសារឡើង<br>២១. ពិភាក្សាអំពីជំនាញចរចាសុវត្ថិភាពនៃការរួមភេទ |

| ក្រដាសវាយតម្លៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម | មាន | គ្មាន |
|---|---|---|
| **សេចក្តីផ្តើម** | | |
| ១.ស្វាគមន៍និងសំដែងគារវកិច្ច | | |
| ២. ផ្តល់លទ្ធផលយ៉ាងសាមញ្ញហើយច្បាស់លាស់ | | |
| ៣. ទុកពេលឱ្យអតិថិជនដើម្បីឱ្យគាត់អាចទទួលយកនូវលទ្ធផលតេស្ត | | |
| **សារនៅក្នុងសៀវភៅរូបភាពដែលត្រូវនិយាយនៅពេលផ្តល់ប្រឹក្សា** | | |
| ៤. រំលឹកឡើងវិញអំពីអត្ថន័យនិងការជាប់ពាក់ព័ន្ធគ្នានៃលទ្ធផលតេស្ត ដល់អតិថិជន | | |
| ៥. ទុកឱកាសឱ្យអតិថិជនបញ្ចេញអារម្មណ៍របស់ខ្លួន | | |
| ៦. រំលឹកអំពីអន្តរាគមន៍បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដែលមានដល់អតិថិជន | | |
| ៧. ការបញ្ជូនអតិថិជនទៅសេវា **OI-ART** ដើម្បីជួយឱ្យស្ត្រីបានទទួលឱសថប្រឆាំងមេរោគអេដស៍ | | |
| ៨. ពិភាក្សាអំពីការជាប់ទាក់ទងរវាងបុគ្គល គ្រួសារនិងសង្គម និងអ្នកដែលត្រូវប្រាប់ពីអាថិកំបាំង | | |
| ៩. ឱ្យអតិថិជនសួរសំណួរនិងឆ្លើយតបទៅនឹងការបារម្ភរបស់គាត់ | | |
| ១០. ផ្តល់ការគាំទ្រភ្លាមៗដែលអាចធ្វើបានជាបន្ទាន់ជូនដល់អតិថិជន | | |
| ១១. ពិភាក្សាអំពីផែនការកាត់បន្ថយគ្រោះថ្នាក់បង្ការការចម្លងទៅដៃគូ និងបង្ការការឆ្លងសារចុះសារឡើង | | |
| ១២. កំណត់រកជម្រើសនិងប្រភពធនធាន | | |
| ១៣. រំលឹកអំពីផែនការបន្ទាន់  បំណងនឹងធ្វើអ្វីមួយ និង សកម្មភាព | | |
| ១៤. តាមដានផែនការដែលបានពិភាក្សា ធ្វើការបញ្ជូនទៅទីកន្លែងណាដែលចាំបាច់ | | |
| **ឥរិយាបថរបស់អ្នកផ្តល់ប្រឹក្សា: តើអ្នកផ្តល់ប្រឹក្សាមាន....?** | | |
| ១៥. ផ្តល់ពេលគ្រប់គ្រាន់ឱ្យអតិថិជននៅពេលផ្តល់ប្រឹក្សា? | | |
| ១៦. យកចិត្តទុកដាក់ស្តាប់អតិថិជនក្នុងពេលផ្តល់ប្រឹក្សា? | | |
| ១៧. បង្អាក់ឬកាត់សំដីអតិថិជន? | | |
| ១៨. ទុកពេលឱ្យអតិថិជនគិតក្នុងចិត្ត និង គិតពីបញ្ហារបស់គាត់? | | |
| ១៩. បង្ហាញការយល់ចិត្តចំពោះអតិថិជន? | | |
| ២០. លើកទឹកចិត្តអតិថិជនឱ្យមានសេចក្តីក្លាហានក្នុងការសួរសំណួរ? | | |
| ២១. ឥរិយាបថរបស់អ្នកផ្តល់ប្រឹក្សាទាំងស្រុងចំពោះអតិថិជន (សូមដាក់ពិន្ទុពី១-៥: ១គឺអន់បំផុត និង ៥គឺល្អបំផុត) | | |
| ២២. តើវគ្គផ្តល់ប្រឹក្សានេះបានបញ្ចប់ទៅដោយវិជ្ជមានដែរឬទេ? | | |

# ម៉ូឌុលទី១២

# ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូននិងការគាំទ្រ

**វត្ថុបំណង**

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមទាំងអស់អាចនឹង:

១. កំណត់បានអំពីគោលបំណងនិងសមាសភាគនៃការផ្តល់ប្រឹក្សា ស្តីអំពីការចិញ្ចឹមកូន

២. រៀបរាប់អំពីដំណាក់កាលនីមួយៗដែលទាក់ទងទៅនឹងការផ្តល់ប្រឹក្សា ស្តីអំពីការចិញ្ចឹមកូន

៣. ពន្យល់អំពីរបៀបចិញ្ចឹមកូនតាមដំណាក់កាលនីមួយៗ

៤. ផ្តល់ប្រឹក្សាដល់ស្ត្រី ស្តីអំពីការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងផ្តាច់ដោះកូនឱ្យបានឆាប់ រហ័ស

៥. ផ្តល់ប្រឹក្សាដល់ស្ត្រីស្តីអំពីការចិញ្ចឹមកូនដោយអាហារជំនួសទឹកដោះម្តាយ ក្នុងរយៈពេល៦ខែដំបូងនៃជីវិត កូន

៦. ពន្យល់ដល់ស្ត្រីអំពីពេលវេលានិងរបៀបផ្តល់អាហារបន្ថែមដល់កូន



*រយៈពេល:* ***៣ម៉ោង***

## សកម្មភាពទី១: សង្ខេប: គោលបំណងនៃការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន:

### គោលបំណងនៃការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន

ដើម្បីលើកកំពស់ការអនុវត្តន៍ចិញ្ចឹមកូនដោយសុវត្ថិភាពនិងកាត់បន្ថយ:

- គ្រោះប្រឈមទៅនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- គ្រោះប្រឈមទៅនឹងការមាក់ងាយចំពោះស្ត្រីជាម្តាយ និងគ្រួសាររបស់គាត់

ដើម្បីជាការនាំផ្លូវម្តាយក្នុងការសំរេចចិត្តជ្រើសរើសវិធីចិញ្ចឹមកូនដែលសមស្រប បំផុតទៅនឹងស្ថានភាពរបស់គាត់ ។

ម្តាយមានសិទ្ធិជ្រើសរើសវិធីចិញ្ចឹមកូន
តួនាទីរបស់អ្នកផ្តល់ប្រឹក្សាគឺគាំទ្រការជ្រើសរើសរបស់គាត់

5

## សកម្មភាពទី២: បំផុសគំនិត: សមាសភាគនៃការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន

» អ្នកត្រូវគិតអំពីចំណុចដែលត្រូវលើកមកនិយាយនៅក្នុងពេលផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន

» គ្រូនឹងឱ្យអ្នកឡើងមកសរសេរចម្លើយនៅលើក្តារខៀន

» នៅពេលដែលអស់ចំណុចហើយ គ្រូនឹងអនុញ្ញាតឱ្យសួរសំណួរ ព្រមទាំងធ្វើការស្រាយបំភ្លឺនូវរាល់ចំណុចណាដែលមិនច្បាស់លាស់

### សមាសភាគនៃការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន

ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន ត្រូវមាន:

- ព័ត៌មានស្តីពីការប្រឈមមុខទៅនឹងការចម្លងមេរោគអេដស៍តាមរយៈការបំបៅកូនដោយទឹកដោះម្តាយ
- ព័ត៌មានស្តីពីជំរើសនៃការចិញ្ចឹមកូនផ្សេងៗ ព្រមទាំងគុណសម្បត្តិនិងគុណវិបត្តិរបស់វា
- ការណែនាំជួយស្ត្រីក្នុងការសំរេចចិត្តឱ្យបានសមស្រប និងគាំទ្រគាត់ឱ្យអនុវត្តវិធីដែលគាត់ជ្រើសរើសនោះឱ្យបានត្រឹមត្រូវ
- ផ្តល់ជំនាញដល់ស្ត្រីក្នុងការចិញ្ចឹមកូនដោយសុវត្ថិភាព ដែលក្នុងនោះមានការបង្ហាញ និងបង្ហាត់ការអនុវត្តន៍ដល់ស្ត្រី ប្រសិនបើមានពេល ។

7

### សមាសភាគនៃការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន(២)

ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន ត្រូវ:

- គិតដល់ទំនៀមទំលាប់ ការអនុវត្តន៍ និងជំនឿតាមមូលដ្ឋានដែលអាចប៉ះពាល់ដល់ជំរើសនៃការចិញ្ចឹមកូន
- លើកទឹកចិត្តឱ្យមានការចូលរួមរបស់គ្រួសារក្នុងការសំរេចចិត្តជ្រើសរើស និងអនុវត្តវិធីចិញ្ចឹមកូន
- មានយុទ្ធវិធីសំរាប់ដោះស្រាយរាល់សំណួររបស់ញាតិមិត្ត ឬសហគមន៍ ទាក់ទងនឹងជម្រើសនៃការចិញ្ចឹមកូន
- គាំទ្រឱ្យគាត់ប្រាប់ពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់ឱ្យគេដឹង ។

8

## សកម្មភាពទី៣: គន្លឹះនៃពាក្យ: តើត្រូវផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូននៅពេលណា?

- » គ្រូស្នើឱ្យអ្នកគិតពីកាលៈទេសៈនៃការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន
- » អ្នកត្រូវឡើងមកសរសេរគំនិតទាំងនោះនៅលើក្តារខៀន
- » ត្រូវចងចាំថា ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន ត្រូវផ្តល់ជូនស្ត្រីមានផ្ទៃពោះឱ្យបានឆាប់របស់ទាន់ពេលវេលា តាមដែលអាចធ្វើបានតាំងតែពីមានផ្ទៃពោះ និងត្រូវបន្តរហូតដល់ពេលសម្រាលនិងក្រោយពេលសម្រាល
- » **ចំណាំ:** ជាធម្មតានៅពេលកើត គេមិនអាចប្រាប់ថាទារកដែលសម្រាលពីម្តាយផ្ទុកមេរោគអេដស៍បានឆ្លងមេរោគអេដស៍ពីម្តាយនៅពេលឈឺពោះសម្រាលឬសម្រាលដែរឬក៏អត់នោះទេ
- » ម្តាយទាំងអស់ត្រូវទទួលបាននូវការប្រឹក្សាស្តីអំពីការចិញ្ចឹមកូន ទោះបីជាស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់យ៉ាងណាក៏ដោយ ព្រោះវាមានផលប្រយោជន៍ច្រើន

### ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូននៅពេលមានផ្ទៃពោះ

ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន ត្រូវផ្តល់ជូនស្ត្រីមានផ្ទៃពោះ:

- ■ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន
- ■ នៅថ្នាក់អប់រំម្តាយ
- ■ ជាលក្ខណៈបុគ្គលនៅពេលដែលគាត់មកពិនិត្យផ្ទៃពោះ
- ■ ដែលជាប្រធានបទមួយសំរាប់ពិភាក្សា នៅពេលផ្តល់ប្រឹក្សាក្រោយតេស្តសំរាប់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍*

*ចំណាំ: អារម្មណ៍រំជើបរំជួលក្រោយពេលទទួលលទ្ធផលតេស្តឈាម អាចធ្វើឱ្យស្ត្រីពិបាកនឹងយល់បានទាំងស្រុងណាស់ ពីប្រធានបទដែលកំពុងតែពិភាក្សា។

10

### ការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូនក្រោយសំរាល

ការប្រឹក្សាស្តីពីការចិញ្ចឹមកូនចាំបាច់:

- ■ ត្រូវផ្តល់ជូនភ្លាមក្រោយពេលកូនសំរាលរួច
- ■ ត្រូវផ្តល់ជូនមុនពេលស្ត្រីចេញពីមន្ទីរពេទ្យ
- ■ ត្រូវផ្តល់ជូននៅរាល់ពេលដែលស្ត្រីមកពិនិត្យសុខភាពជាប្រចាំ
- ■ ត្រូវផ្តល់ជូនមុនពេលផ្តាច់ដោះកូនដែលធ្វើឡើងមុនពេលកំណត់។ព័ត៌មានបន្ថែមត្រូវផ្តល់ឱ្យចំពោះករណីប្រឈមខ្ពស់នឹងការឆ្លង បើសិនជា:
- ■ កុមារឈឺ
- ■ ម្តាយដល់ពេលចូលធ្វើការវិញ ឬត្រូវធ្វើដំណើរចេញទៅឆ្ងាយ
- ■ ម្តាយសំរេចចិត្តប្តូរវិធីចិញ្ចឹមកូន

11

### ទារកដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍

អត្រាទារកដែលឆ្លងមេរោគពីម្តាយរួចហើយមានតិចតួចណាស់ ហើយការធ្វើតេស្តឈាមធម្មតាមិនអាចដឹងបានឡើយ

- ■ បើសិនជា ទារកមិនឆ្លងមេរោគអេដស៍ទេ គ្រោះប្រឈមនឹងការឆ្លងមេរោគអេដស៍ និងរោគដទៃទៀតអាចកាត់បន្ថយបានតាមរយៈការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូនដែលសមស្រប
- ■ បើសិនជាទារកបានឆ្លងមេរោគអេដស៍រួចហើយ ម្តាយគួរតែបន្តបំបៅកូនដោយដោះ

**គ្រប់ម្តាយទាំងអស់គួរទទួលបាននូវការផ្តល់ប្រឹក្សាស្តីពីការចិញ្ចឹមកូន ទោះបីជាកូនមានផ្ទុកមេរោគអេដស៍ក្តី ឬក៏មិនមានក្តី។**

12

# សកម្មភាពទី៤: ល្បែងដើរតួ: ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន

## គោលបំណង

- ដើម្បីអនុវត្តការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន
- ដើម្បីកំណត់រកនិងបកស្រាយបញ្ហាដែលអាចកើតឡើងនៅពេលផ្តល់ប្រឹក្សា

## សម្ភារៈដែលត្រូវការ

១. ក្រដាសថតចម្លងល្បែងដើរតួ
២.ក្រដាសថតចម្លងបញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សា (ឧបសម្ព័ន្ធទី១២)

## សកម្មភាព

- គ្រូចែកសិក្ខាកាមជាគូៗ ដោយម្នាក់ត្រូវដើរតួជាម្តាយនិងម្នាក់ទៀតត្រូវដើរតួជាអ្នកផ្តល់ប្រឹក្សា
- បើអ្នកដើរតួជាម្តាយ ត្រូវអានតួនាទីម្តាយដែលគ្រូចែកឱ្យ

## សកម្មភាព (ត)

- សូមធ្វើការណែនាំខ្លួននិងនិយាយអំពីស្ថានភាពរបស់អ្នក (មុនពេលសម្រាលកូន ឬក្រោយពេលសម្រាលកូន) ទៅអ្នកផ្តល់ប្រឹក្សា
- អ្នកផ្តល់ប្រឹក្សាត្រូវធ្វើតាមដំណាក់កាលនីមួយៗ ដោយប្រើបញ្ជីផ្ទៀងផ្ទាត់ (ឧបសម្ព័ន្ធទី១២) និងផ្តល់ការប្រឹក្សាដល់ម្តាយ
- ប្រសិនជាអ្នកសំដែងជាតួម្តាយ សូមសំដែងឱ្យបានដូចជាការពិតតាមដែលអាចធ្វើបាន
- នៅពេលដែលអ្នកបញ្ចប់ការសំដែងតួរួចហើយ អ្នកត្រូវប្តូរជាតួសំដែងផ្សេងទៀត (ធ្វើដូច្នេះ ម្នាក់ៗនឹងមានឱកាសធ្វើជាអ្នកផ្តល់ប្រឹក្សា)
- សិក្ខាកាមម្នាក់ៗត្រូវសំដែងជាតួអង្គ “អ្នកផ្តល់ប្រឹក្សា” យ៉ាងហោចណាស់ក៏ម្តងដែរ។ បន្ទាប់មក អ្នកត្រូវវិលចូលមកក្នុងក្រុមធំវិញ ដើម្បីធ្វើការសង្ខេបសរុប។

## សង្ខេបខ្លីៗ:

សម្រាប់ម្តាយ:

- តើអ្នកមានអារម្មណ៍យ៉ាងណាដែរចំពោះការផ្តល់ប្រឹក្សាវគ្គនេះ?
- តើអ្នកផ្តល់ប្រឹក្សាធ្វើឱ្យអ្នកមានអារម្មណ៍បែបណាដែរ?: គាំទ្រឬក៏រើសអើង?
- តើអ្នកបានដឹងអំពីចំណុចសំខាន់អ្វីខ្លះ?
- តើវគ្គនេះ ធ្វើឱ្យអ្នកចង់ប្តូរចិត្តអំពីរបៀបចិញ្ចឹមកូនដែរឬទេ?
- តើមានចំណុចណាមួយដែលពិបាកពិភាក្សាដែរឬទេ?

ពិភាក្សារកវិធីដោះស្រាយបញ្ហាដែលបង្កប់នៅក្នុងសំណួរខាងលើ

សម្រាប់អ្នកផ្តល់ប្រឹក្សា:

- តើអ្នកមានអារម្មណ៍យ៉ាងណាដែរចំពោះវគ្គនេះ?
- តើអ្នកមានជួបការលំបាកក្នុងដំណាក់កាលណាមួយដែរឬទេ? ប្រសិនជាមានតើវាជាអ្វី?
- តើអ្នកត្រូវធ្វើខ្លះដើម្បីឱ្យកាន់តែមានទំនុកចិត្តក្នុងការផ្តល់ការគាំទ្រដល់ការចិញ្ចឹមកូន?

ពិភាក្សារកដំណោះស្រាយចំពោះបញ្ហាលំបាកដែលបង្កប់នៅក្នុងសំណួរខាងលើ

## ល្បែងដើរតួៈ ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន

| **ការមកពិនិត្យផ្ទៃពោះ** | |
|---|---|
| ល្បែងដើរតួទី១ | មុនពេលសម្រាល |
| អ្នកមានឈ្មោះ " សូភា" រស់នៅខេត្តតាកែវ ។ អ្នកមានផ្ទៃពោះកូនទីពីរចំនួន៨ខែហើយ ។ អ្នកបានចិញ្ចឹមកូនទីមួយដោយដោះរបស់អ្នកផ្ទាល់ ។ អ្នកមានផ្ទុកមេរោគអេដស៍ ។ អ្នកគិតថានឹងបំបៅកូនក្រោយដោយដោះរបស់អ្នកទៀត ដោយសារតែអ្នកមិនអាចលៃលករកទិញទឹកដោះគោម្សៅឱ្យកូនបាន ។ | |
| ល្បែងដើរតួទី២ | មុនពេលសម្រាល |
| អ្នកមានឈ្មោះ "ស្រីមុំ" រស់នៅទីក្រុងភ្នំពេញ ។ កូនដំបូងរបស់អ្នកនឹងកើតក្នុងរវាង២ខែទៀត ។ អ្នកដឹងថាខ្លួនមានផ្ទុកមេរោគអេដស៍ ។ អ្នកចង់ចិញ្ចឹមកូនដោយទឹកដោះគោម្សៅ ក៏ប៉ុន្តែអ្នកបានទទួលដំបូន្មានពីមិត្តភ័ក្តិដែលផ្ទុយពីគំនិតរបស់អ្នក ។ អ្នកមិនទាន់ច្បាស់ក្នុងចិត្តថាអ្វីដែលប្រសើរបំផុតនោះទេ ។ | |
| ល្បែងដើរតួទី៣ | មុនពេលសម្រាល |
| អ្នកមានឈ្មោះ "សុជាតា" រស់នៅខេត្តបាត់ដំបង ។ ថ្មីៗនេះ អ្នកដឹងថាខ្លួនមានផ្ទុកមេរោគអេដស៍ ក៏ប៉ុន្តែគ្មាននរណាម្នាក់នៅក្នុងគ្រួសារបានដឹងពីរឿងនេះទេ ។ កូនក្នុងផ្ទៃដែលជាកូនទីបីនឹងកើតក្នុងរវាង២ខែទៀត ។ | |

| **ការមកពិនិត្យក្រោយសម្រាល** | |
|---|---|
| ល្បែងដើរតួទី៤ | ក្រោយសម្រាល |
| អ្នកមានឈ្មោះ "ប៉ោជូ" ។ អ្នកបានចិញ្ចឹមកូនដោយដោះអស់រយៈពេល៣ខែមកហើយ ។ អ្នកដឹងខ្លួនថាមានផ្ទុកមេរោគអេដស៍ ហើយមានការភ័យខ្លាចមេរោគអេដស៍ឆ្លងទៅកូនរបស់អ្នក ។ អ្នកនៅមានចម្ងល់ពីរឿងបញ្ឈប់បំបៅដោះកូនតែបារម្ភថាកូនអ្នកនៅតូចពេក ។ | |

| ល្បែងដើរតួទី៥ | ក្រោយសម្រាល |
|---|---|
| អ្នកមានឈ្មោះ "នីន" ។ អ្នកកំពុងតែចិញ្ចឹមកូនដោយប្រើទឹកដោះគោម្សៅរយៈពេល២ខែមកហើយ តាំងពីកូនទើបនឹងកើតដោយសារតែអ្នកមានផ្ទុកមេរោគអេដស៍ ។ កូនរបស់អ្នកមានជំងឺរាកចំនួនពីរដងមកហើយ ។ អ្នកបានចំណាយលុយអស់ហើយដោយសារតែអ្នកមិនបានធ្វើការក្រោយពេលសម្រាលកូន ។ | |

## សកម្មភាពទី៤: ល្បែងដើរតួ: ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន (ត)

» ស្លាយទី១៤ សង្ខេបពីដំណាក់កាល ដែលអ្នកផ្តល់ប្រឹក្សាត្រូវពន្យល់ដល់ស្ត្រីជាម្តាយដែលចង់ផ្តាច់ដោះកូនភ្លាមៗ

> **តើត្រូវផ្តាច់ដោះកូនឱ្យបានរហ័សដោយរបៀបណា?**
>
> ១. នៅពេលម្តាយកំពុងបំបៅដោះកូន ចូរបង្រៀនកូនគាត់ឱ្យចេះផឹកទឹកដោះម្តាយ ដែលច្របាច់ចេញមករបស់ម្តាយ* ដោយប្រើពែង
>
> ២. នៅពេលដែលទារកអាចផឹកបានល្អប្រសើរជាមួយនឹងពែងហើយ ចូរជំនួសការបំបៅដោះ មកផឹកទឹកដោះម្តាយជំនួសវិញ
>
> ៣. រៀងរាល់ពីរ-បីថ្ងៃម្តង ឱ្យទារកផឹកទឹកដោះម្តាយជំនួសការបំបៅដោះ
>
> ៤. នៅពេលដែលការចិញ្ចឹមកូនដោយប្រើពែងអាចប្រព្រឹត្តទៅបានស្រួលហើយ ចូរបញ្ឈប់ការបំបៅដោះទាំងស្រុង ហើយឱ្យទារកផឹកទឹកដោះម្តាយដោយពែងវិញ **
>
> ៥. បន្តិចម្តងៗជំនួសទឹកដោះច្របាច់របស់ម្តាយ ដោយទឹកដោះគោម្សៅ
>
> *ទឹកដោះច្របាច់អាចយកមកកំដៅដើម្បីសំលាប់មេរោគអេដស៍បាន
>
> ** ជាការប្រសើរបំផុត ចាប់ពីពេលនេះតទៅត្រូវកំដៅទឹកដោះច្របាច់ឱ្យបានជាប់ជាប្រចាំ
>
> 14

## សកម្មភាពទី៥: ល្បែងដើរតួ: ការចិញ្ចឹមកូនដោយពែង ផ្ទុយគ្នានឹងការចិញ្ចឹមកូនដោយដប

### គោលបំណង

» គោលបំណងនៃលំហាត់នេះ គឺដើម្បីពិនិត្យអំពីគុណសម្បត្តិនិងគុណវិបត្តិនៃការចិញ្ចឹមកូនដោយពែងនិងដោយដប

» គ្រូស្នើឱ្យសិក្ខាកាមពីរនាក់ស្ម័គ្រចិត្តមកឈរនៅពីមុខបន្ទប់: ម្នាក់ជាប្រធានខាងក្រុមចិញ្ចឹមកូនដោយប្រើពែង ឯម្នាក់ទៀតជាប្រធានខាងក្រុមចិញ្ចឹមកូនដោយប្រើដប

» គោលបំណងរបស់ល្បែង គឺធ្វើយ៉ាងណាឱ្យ "ទទួលបាននូវការគាំទ្រ" អំពីវិធីចិញ្ចឹមកូនដែលខ្លួនជ្រើសរើស ដោយផ្តល់នូវហេតុផលថា តើហេតុអ្វីវិធីនេះល្អ ហើយហេតុអ្វីវិធីនេះមិនល្អ

### សកម្មភាព

» ប្រធានក្រុមខាងចិញ្ចឹមកូនដោយប្រើពែង ឡើងបញ្ជាក់អំពីគុណសម្បត្តិនៃការចិញ្ចឹមកូនដោយប្រើពែងនិងគុណវិបត្តិនៃការចិញ្ចឹមកូនដោយប្រើដប

» ប្រសិនជាចម្លើយរបស់គាត់ត្រឹមត្រូវ គាត់អាចជ្រើសរើសមនុស្សម្នាក់មកចូលក្នុងក្រុមខ្លួន។

### សកម្មភាព (ត)

» បន្ទាប់មកក្រុមចិញ្ចឹមកូនដោយប្រើដបឡើងនិយាយម្តង អំពីគុណសម្បត្តិនៃការចិញ្ចឹមកូនដោយប្រើដប និងគុណវិបត្តិនៃការចិញ្ចឹមកូនដោយប្រើពែង

» ប្រសិនជាចម្លើយរបស់គាត់ត្រូវ គាត់អាចជ្រើសរើសសិក្ខាកាមម្នាក់ឱ្យចូលរួមក្នុងក្រុមរបស់គាត់

» ធ្វើដូច្នេះ រហូតដល់ក្រុមនីមួយៗមិនអាចរកចម្លើយមកអះអាងអំពីវិធីចិញ្ចឹមរបស់ខ្លួនបានតទៅទៀត

» ក្រុមដែលមានសមាជិកច្រើនជាក្រុមដែលឈ្នះ

» **ចំណាំ:** ប្រសិនជាអស់គ្នាហើយ តែមានក្រុមណាមួយនៅមានយោបល់ត្រូវ ក្រុមនោះអាចយកមនុស្សពីក្រុមម្ខាងទៀតបាន

## ការចិញ្ចឹមកូនដោយប្រើពែង

- ការចិញ្ចឹមកូនដោយប្រើពែង ត្រូវបានគេនិយមប្រើជាងការចិញ្ចឹមកូនដោយប្រើដប ពីព្រោះ:
  - ពែងងាយស្រួលលាងសំអាតឱ្យស្អាតជាមួយនឹងទឹកនិងសាប៊ូ
  - ពែងមិនចាំបាច់ត្រូវយកតាមជាប់ខ្លួនយូរគ្រប់ពេលវេលាដែលអំណោយផលដល់មេរោគធ្វើការបំបែកកូនចៅដូចការប្រើដបទេ
  - ការចិញ្ចឹមកូនដោយប្រើពែង បង្កឱ្យមានរោគឆ្លងតិចតួចជាងការផ្តល់អាហារដល់កូនដោយប្រើដប
- ការចិញ្ចឹមកូនដោយប្រើពែង ត្រូវបានគេនិយមប្រើជាងការចិញ្ចឹមកូនដោយប្រើពែងជាមួយនឹងស្លាបព្រា ពីព្រោះ :
  - វាចំណាយពេលតិចជាង

16

## របៀបផ្តល់ទឹកដោះដល់ទារកដោយប្រើពែង

- លាងដៃរបស់អ្នក និងដាក់ទឹកដោះល្មមសំរាប់តែមួយដងទៅក្នុងពែង
- ដាក់កូនអោយអង្គុយលើភ្លៅរបស់អ្នក
- កាន់ដៃពែងទឹកដោះហើយដាក់ចូលទៅក្នុងមាត់កូន
- ផ្អៀងពែងបន្តិច ធ្វើដូច្នេះ ទឹកដោះអាចប៉ះនឹងបបូរមាត់កូន
- កូនអាចដឹងភ្លាមហើយបើកមាត់និងបើកភ្នែក
- ទុកអោយកូនបឺតទឹកដោះដោយខ្លួនឯង ។ **មិនត្រូវ**ចាក់ទឹកដោះទៅក្នុងមាត់កូនទេ
- នៅពេលដែលកូនបឺតឆ្អែតហើយ វានឹងបិតមាត់ឈប់ជញ្ជក់ទឹកដោះ
- វាស់មើលតើកូនបឺតទឹកដោះដោយខ្លួនឯងអស់ប៉ុន្មាន ក្នុងរយៈពេល២៤ម៉ោង ។

17

## របៀបលាយទឹកដោះគោម្សៅសំរាប់កូន

- លាងសំភារៈសំរាប់លាយ និងសំរាប់បំបៅកូនឱ្យបានស្អាតជាមួយសាប៊ូនិងទឹក
- ប្រើទឹកពុះសំរាប់លាយអាហារ ប្រសិនបើកូនអាយុតិចជាង ៦ខែ
- ស្ងោរសំភារៈដើម្បីរំងាប់មេរោគ បើសិនជាកូនមានអាយុតិចជាង ៦ខែ
- ត្រូវវាល់ទឹក និង ទឹកដោះគោម្សៅឱ្យបានត្រឹមត្រូវ- កំណត់ខ្នាតឱ្យបានសមស្រប
- បង្ហាញពីរបៀបលាយទឹកដោះគោម្សៅឱ្យបានត្រឹមត្រូវ
- ស្នើឱ្យម្តាយធ្វើការបង្ហាញពីរបៀបលាយទឹកដោះគោម្សៅដើម្បីឱ្យប្រាកដថាគាត់អាចអនុវត្តបានត្រឹមត្រូវ

18

## ការចិញ្ចឹមកូនដោយប្រើដប

មិនត្រូវបានលើកទឹកចិត្តម្តាយឱ្យចិញ្ចឹមទារកដោយប្រើដបទេ ពីព្រោះ:

- វាងាយប្រឈមនឹងជម្ងឺរាក ជម្ងឺធ្មេញ និងជម្ងឺរលាកត្រចៀកខ្លាំងណាស់
- ទារកអាចមិនបានទទួលការពញ្ញោចគ្រប់គ្រាន់នៅពេលបញ្ចុកអាហារ
- ដបនិងក្បាលដោះ
  - ត្រូវសំអាតនឹងច្រាស់ និងបន្ទាប់មក
  - ត្រូវស្ងោររំងាប់មេរោគ ដែលទាមទារពេលវេលា និង ភ្លើងសំរាប់សម្លាប់មេរោគ
  - ការចិញ្ចឹមកូនដោយប្រើដបអាចត្រូវចំណាយថវិកាច្រើនជាងប្រើពែង

19

## សកម្មភាពទី៦: ធ្វើការជាក្រុម: ការចិញ្ចឹមកូនដែលមានអាយុលើសពី៦ខែ

» គោលបំណងនៃលំហាត់នេះ គឺពិនិត្យទិដ្ឋភាពនៃការចិញ្ចឹមកូន ក្រោយពេលដែលកូនមានអាយុ៦ខែ

» គ្រូចែកសិក្ខាកាមជា៣ក្រុម និងចែកប្រធានបទឱ្យទៅក្រុមនីមួយៗដូចតទៅ:

ក្រុមទី១: ការចិញ្ចឹមក្មេងធំ
ក្រុមទី២: ការចិញ្ចឹមក្មេងឈឺ
ក្រុមទី៣: អនាម័យក្នុងការរៀបចំអាហារ

» ក្រុមនីមួយៗត្រូវគិតអំពីចំណុចសំខាន់ៗ ទាក់ទងនឹងប្រធានបទរបស់គេ

» ក្រុមនីមួយៗត្រូវឡើងមកបង្ហាញអំពីលទ្ធផលរបស់ក្រុមខ្លួនជូនដល់ក្រុមធំ

» និងសរសេរចម្លើយនៅលើក្ដារខៀនពីក្រោមចំណងជើងដែលសមស្រប

» បន្ទាប់ពីការបង្ហាញនៃក្រុមនីមួយៗ ក្រុមដទៃអាចបន្ថែមចំណុចខ្លះៗបាន

### ការចិញ្ចឹមកុមារធំ

ត្រូវចាប់ផ្ដើមផ្ដល់អាហារបន្ថែមដល់កូន នៅពេលដែលកូនមានអាយុ៦ខែ

- ចាប់ផ្ដើមឱ្យបន្តិចម្ដងៗ
- បង្កើនបរិមាណ និង ចំនួនដងនៃការផ្ដល់អាហារបន្តិចម្ដងៗ នៅពេលដែលកូនមានអាយុ កាន់តែច្រើនឡើងៗ
- កូនដែលមានសុខភាពមិនសូវល្អ និង កូនដែលខ្វះអាហារូបត្ថម្ភ ត្រូវការថាមពលខ្លាំង

កុមារនៅតែត្រូវការទឹកដោះម្ដាយ ឬ ទឹកដោះគោម្សៅជារៀងរាល់ថ្ងៃ

- ត្រូវឱ្យ១-២ ពែងក្នុង១ថ្ងៃ (២៥០-៥០០មល)

21

### ការចិញ្ចឹមកូនដែលមិនបំបៅដោយដោះម្ដាយ: ចាប់ពី៦ខែឡើងទៅ

កូនដែលមានអាយុចាប់ពី៦ខែឡើងទៅមិនបានបៅដោះម្ដាយ ត្រូវទទួលបាន:

- ទឹកក្រៅពីទឹកដោះគោម្សៅជារៀងរាល់ថ្ងៃ (៤-៦ពែង*)
- ទឹកដោះគោម្សៅ (១-២ពែង ក្នុង១ថ្ងៃ)
- អាហារបន្ថែម (១-២ដងក្នុង១ថ្ងៃ)

* ១ពែង ស្មើនឹង= ២៥០ម.ល

22

## សារគន្លឹះសំរាប់ការផ្តល់អាហារបន្ថែមដល់កុមារ (១)

១. ការបំបៅកូនដោយដោះរយៈពេល២ឆ្នាំ ឬយូរជាងនេះ ជួយធ្វើឱ្យកូនរីកចំរើន និងធំធាត់មាំមួន និងមានសុខភាពល្អ

២. ការផ្តើមឱ្យអាហារផ្សេងទៀត បន្ថែមពីលើទឹកដោះម្តាយពេលកូនមានអាយុគ្រប់៦ខែ ជួយកុមារឱ្យលូតលាស់ល្អ

៣. អាហារគោក ជួយផ្តល់ថាមពលបន្ថែមដល់កុមារ

៤. អាហារដែលមានប្រភពពីសត្វ គឺជាអាហារល្អពិសេសសំរាប់កុមារ

៥. សណ្តែកបារាំង គ្រាប់សណ្តែកសៀង សណ្តែកដី និងគ្រាប់ធញ្ញជាតិដទៃទៀតមានប្រយោជន៏ណាស់សំរាប់កុមារ

៦. ស្លឹករុក្ខជាតិពណ៌បៃតង និងផ្លែឈើទុំ ព្រមទាំងបន្លែ ជួយធ្វើឱ្យកុមារមិនសូវមានជម្ងឺ និង មានភ្នែកភ្លឺល្អ។

23

## សារគន្លឹះសំរាប់ការផ្តល់អាហារបន្ថែមដល់កុមារ (២)

៧. កុមារដែលកំពុងតែលូតលាស់ធំធាត់ ត្រូវការៈ

- អាហារ ៣ពេលក្នុង១ថ្ងៃ និងអាហារសំរន់ផ្សេងទៀត បើសិនជានៅតែបំបៅកូនដោយដោះម្តាយ ឬក៏បំបៅកូនដោយទឹកដោះគោម្សៅ
- អាហារ ៥ពេលក្នុង១ថ្ងៃ និងអាហារសំរន់ផ្សេងទៀត បើសិនជាឈប់បំបៅកូនដោយដោះម្តាយ ឬឈប់បំបៅកូនដោយទឹកដោះគោម្សៅ

៨. កុមារដែលកំពុងលូតលាស់ ត្រូវការអាហារកាន់តែច្រើនឡើង

៩. កុមារតូចៗត្រូវរៀនញ៉ាំអាហារៈ ត្រូវលើកទឹកចិត្តនិងជួយឱ្យគេរៀនញ៉ាំដោយចិត្តអំណត់

១០. លើកទឹកចិត្តកុមារឱ្យផឹកនិងញ៉ាំ នៅពេលគេមានជម្ងឺ និង ឱ្យអាហារបន្ថែមក្រោយពេលជាសះស្បើយដើម្បីឱ្យកូនបានធូរស្រាលឆាប់ ។

24

## ការផ្តល់អាហារដល់កុមារមានជម្ងឺ (១)

- កង្វះអាហារូបត្ថម្ភ និងមេរោគអេដស៏មានទំនាក់ទំនងនឹងគ្នា
- ការឆ្លងរោគញឹកញាប់ និងការផ្តល់អាហារមិនគ្រប់គ្រាន់ នាំឱ្យមានជម្ងឺកង្វះអាហារូបត្ថម្ភសាចុះសាឡើង មានជម្ងឺ ការលូតលាស់មិនបានល្អ និងបណ្តាលឱ្យកុមារស្លាប់ជាយថាហេតុ
- កុមារដែលឈឺអាចមិនចង់ញ៉ាំ ដោយសារៈ
  - បាត់បង់គម្លាន ខ្សោយ អស់កំលាំង
  - ក្អួត ឈឺមាត់ ពិបាកដកដង្ហើម
  - ផលប៉ះពាល់របស់ថ្នាំ
- អ្នកថែទាំកុមារ អាចៈ
  - ដកអាហារទុក
  - ផ្តល់អាហារមិនគ្រប់គ្រាន់
  - មិនអាចទទួលបាននូវអាហារសមស្រប ឬអាហារដែលកុមារចូលចិត្ត

25

## ការផ្តល់អាហារដល់កុមារមានជម្ងឺ (២)

- ទាមទារឱ្យមាន ការអត់ធ្មត់ ការលើកទឹកចិត្តកុមារឱ្យផឹក និងញ៉ាំ
- ផ្តល់អាហារតិចៗ ឱ្យបានច្រើនដងក្នុង១ថ្ងៃ
- ផ្តល់អាហារដែលកុមារចូលចិត្ត
- ផ្តល់អាហារដែលសំបូរដោយសារធាតុចិញ្ចឹមគ្រប់មុខ
- បន្តបំបៅកូនដោយដោះ ឬ ដោយទឹកដោះគោម្សៅ

26

## ការផ្តល់អាហារដល់កុមារដែលទើបនឹងជាពីជម្ងឺ

- ផ្តល់អាហារបន្ថែម ឬទឹកដោះគោម្សៅបន្ថែម
- បង្កើនការផ្តល់អាហារបន្ថែម
- បង្កើនបរិមាណអាហារ
- ផ្តល់អាហារដែលសំបូរជីវជាតិបន្ថែម
- ផ្តល់អាហារដោយភាពអត់ធ្មត់ឱ្យបានច្រើន

27

## អនាម័យក្នុងការរៀបចំអាហារ

- លាងដៃជាមួយនឹងសាប៊ូនិងទឹក មុនពេលរៀបចំអាហារ
- លាងសំភារៈសំរាប់លាយ និងសំរាប់បំបៅកូនឱ្យបានស្អាតជាមួយនឹងសាប៊ូនិងទឹក រួមទាំងផ្ទៃតុសំរាប់រៀបចំអាហារ
- រក្សាអាហារ និង ទឹកដាក់ក្នុងថូស្អាតដែលមានគំរប
- ការពារអាហារកុំឱ្យសត្វកណ្តុរ សត្វល្អិត ឬ សត្វដទៃទៀតមកប៉ះពាល់
- ជៀសវាងការដាក់អាហារឆៅ និង អាហារឆ្អិនឡូកឡំគ្នា
- ត្រូវរក្សាអាហារឆ្អិន តែនៅក្នុងទូទឹកកក ឬ នៅកន្លែងដែលត្រជាក់ប៉ុណ្ណោះ
- មុននឹងញ៉ាំត្រូវយកអាហារមកកំដៅជាមុនសិន

28

## ចំណុចគន្លឹះ

### ម៉ូឌុលទី១២: ចំណុចគន្លឹះ

- ការផ្តល់ប្រឹក្សា ការអប់រំ និងការគាំទ្របន្ត មានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ និងរក្សាបាននូវការអនុវត្តនីវិធីចិញ្ចឹមកូនប្រកបដោយសុវត្ថិភាព
- ការចិញ្ចឹមកូនដោយសុវត្ថិភាព អាចកាត់បន្ថយ:
  - ការប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
  - អត្រាឈឺនិងស្លាប់ដែលទាក់ទងទៅនឹងកង្វះអាហារូបត្ថម្ភនិងជំងឺឆ្លងនានា
  - ការប្រឈមនឹងការមាក់ងាយដល់ម្តាយនិងគ្រួសាររបស់គាត់
- ការផ្តល់ប្រឹក្សាក្រោយសម្រាល និងការតាមដានកុមារក្នុងរយៈពេល២ឆ្នាំដំបូងនៃជីវិតកូនមានសារៈសំខាន់ណាស់

## ឧបសម្ព័ន្ធទី១២

| **បញ្ជីផ្ទៀងផ្ទាត់ការផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន:** ត្រូវប្រើបញ្ជីផ្ទៀងផ្ទាត់នៅពេលផ្តល់ប្រឹក្សាស្តីអំពីការចិញ្ចឹមកូន |
|---|
| ១. ពន្យល់អំពីការប្រឈមនឹងការចម្លងមេរោគអេដស៍ពីម្តាយទៅកូន<br>២. ពន្យល់អំពីជម្រើសនៃការចិញ្ចឹមកូនខុសៗគ្នា និងគុណសម្បត្តិនិងគុណវិបត្តិនៃជម្រើសនីមួយៗ<br>៣. ស្រាវជ្រាវអំពីអាស័យដ្ឋានរបស់ម្តាយនិងស្ថានភាពគ្រួសាររបស់គាត់<br>៤. ជួយម្តាយឱ្យជ្រើសរើសវិធីចិញ្ចឹមកូនដែលសមស្រប<br>៥. ត្រិះរិះអំពីសំណួរដែលអាចនឹងសួរដោយគ្រួសារ និងមិត្តភ័ក្តិរបស់ស្ត្រី និងរកវិធីសម្រាប់ឆ្លើយតបទៅអ្នកទាំងនោះ<br>៦. ត្រូវឱ្យប្រាកដថា ម្តាយបានយល់ច្បាស់អំពីវិធីចិញ្ចឹមកូនដែលគាត់បានជ្រើសរើស:<br>ក) - ការចិញ្ចឹមកូនដោយទឹកដោះម្តាយតែមួយមុខគត់និងការផ្តាច់ដោះកូនភ្លាមៗ<br>ខ) - ទឹកដោះគោម្សៅ<br>គ) - ការចិញ្ចឹមកូនដោយអាហារជំនួសទឹកដោះម្តាយផ្សេងៗទៀត<br>៧. ផ្តល់ការប្រឹក្សានិងគាំទ្រជាបន្តរយៈពេល២ឆ្នាំ បើសិនជាអាចធ្វើបាន<br>៨. ការមកពិនិត្យក្រោយសម្រាល:<br>● តាមដានការលូតលាស់<br>● ពិនិត្យរករោគសញ្ញានៃជំងឺ<br>● ពិនិត្យពីការអនុវត្តវិធីចិញ្ចឹមកូន<br>● កំណត់រកតម្រូវការនៃការផ្លាស់ប្តូរវិធីចិញ្ចឹមកូន<br>៩. នៅពេលដែលទារកធំឡើង:<br>● ពិភាក្សាអំពីការចិញ្ចឹមកូនអាយុចាប់ពី៦ខែទៅ២ឆ្នាំ<br>❖ អាហារសមស្រប<br>❖ អនាម័យក្នុងការរៀបចំអាហារ<br>❖ ការចិញ្ចឹមកូនឈឺ |
| សូមអានព័ត៌មានលំអិតនៅក្នុងម៉ូឌុលទី៤ វគ្គទី៣  ភាគទី៣: ការចិញ្ចឹមកូនក្នុងបរិបទនៃមេរោគអេដស៍ |

| ១០ជំណាក់កាលដើម្បីជោគជ័យក្នុងការចិញ្ចឹមកូនដោយទឹកដោះម្ដាយ | |
|---|---|
| **គ្រប់សេវាសម្រាលកូនទាំងអស់ត្រូវ:** | |
| ១ | មានសៀវភៅគោលនយោបាយស្ដីអំពីការចិញ្ចឹមកូនដោយទឹកដោះម្ដាយ |
| ២ | បណ្ដុះបណ្ដាលដល់គ្រប់បុគ្គលិកទាំងអស់ពីគោលនយោបាយនេះ |
| ៣ | ផ្ដល់ព័ត៌មានដល់ស្ត្រីមានផ្ទៃពោះអំពីផលចំណេញនៃការចិញ្ចឹមកូនដោយទឹកដោះម្ដាយ |
| ៤ | ជួយបង្រៀនម្ដាយឱ្យចេះបំបៅដោះកូនក្នុងអំឡុងពេល១ម៉ោងក្រោយសម្រាល |
| ៥ | បង្ហាញម្ដាយអំពីរបៀបបំបៅដោះកូន និងអំពីរបៀបរក្សាដោះឱ្យនៅតែមានទឹកដោះនៅពេលដែលអ្នកទាំងពីរនៅបែកពីគ្នា |
| ៦ | មិនត្រូវឱ្យចំណីអាហារឬភេសជ្ជៈអ្វីដល់ទារកក្រៅពីទឹកដោះម្ដាយឡើយ លើកលែងតែថ្នាំព្យាបាល |
| ៧ | ឱ្យម្ដាយនិងទារករស់នៅជាមួយគ្នាឱ្យបាន២៤ម៉ោងក្នុង១ថ្ងៃ |
| ៨ | លើកទឹកចិត្តម្ដាយឱ្យបំបៅដោះតាមតម្រូវការរបស់កូន |
| ៩ | មិនត្រូវឱ្យក្បាលដោះសិប្បនិមិត្ត ឬសន្តិភាពករ (របស់លួងក្មេងឱ្យឈប់យំ) ដល់ទារកដែលបៅដោះម្ដាយឡើយ |
| ១០ | លើកកម្ពស់ឱ្យមានក្រុមគាំទ្រការចិញ្ចឹមកូនដោយទឹកដោះម្ដាយនិងបញ្ជូនម្ដាយទៅជួបក្រុមទាំងនោះ នៅពេលដែលម្ដាយចេញពីមន្ទីរពេទ្យ |

# សប្តាហ៍ទី២
## ចម្លើយ

### វត្ថុបំណង

ចម្លើយនៃសំណួរនិងលំហាត់ក្នុងករណីសិក្សា ដែលបានអនុវត្តក្នុងកម្មវិធីបណ្តុះបណ្តាលការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ត្រូវបានឃើញនៅក្នុងផ្នែកនេះ

## ម៉ូឌុលទី៧ សកម្មភាពទី៤

ករណីសិក្សា: ការផ្តល់ដំបូន្មានឬការផ្តល់ប្រឹក្សា?

**ចម្លើយនិងហេតុផលដែលអាចកើតមាន**

| |
|---|
| ១. ចាំបាច់ ស្រីមុំអាចមានកូនបាន |
| ■ ប្រសិនបើនាងចង់មានកូន គួរតែអនុញ្ញាតឱ្យគាត់មាន<br>■ ការមានកូននឹងធ្វើឱ្យសង្សាររបស់នាង ស្រលាញ់នាងកាន់តែខ្លាំងឡើង<br>■ ការមានកូននឹងផ្តល់កម្លាំងចិត្ត ឱ្យសង្សារនាងរកការងារសមស្របមួយធ្វើ ហើយ"ស្រីមុំ"អាចឈប់ធ្វើជាស្ត្រីរកស៊ីផ្លូវភេទបាន ។ |
| ២. ទេ "ស្រីមុំ"មិនគួរមានកូនទេ |
| ■ ព្រោះនាងអាចចម្លងមេរោគអេដស៍ទៅសង្សាររបស់នាង<br>■ កូនរបស់នាងក៏អាចឆ្លងមេរោគអេដស៍ដែរ<br>■ ប្រសិនជានាងឈឺ តើបានអ្នកណាមើលកូនរបស់នាង<br>■ ស្ត្រីរកស៊ីផ្លូវភេទមិនអាចធ្វើជាម្តាយល្អទេ<br>■ សង្សាររបស់នាងមិនមានប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់គ្រួសារទេ |
| ៣. ទុកឱ្យ "ស្រីមុំ" សម្រេចចិត្តថានាងត្រូវធ្វើអ្វីសម្រាប់ខ្លួននាង |
| ■ នាងត្រូវគិតគ្រប់បែបយ៉ាងពីការមានកូន នៅពេលដែលមានផ្ទុកមេរោគអេដស៍<br>■ នាងត្រូវពិចារណាពីផលវិបាកនៃការមានកូននិងការគ្មានកូន |

## ករណីសិក្សាទី ១

ក្រុមសីលធម៌ដែលអ្នកត្រូវគិតដល់ នៅក្នុងករណីសិក្សានេះមាន:

សមត្ថភាព

- គុណភាពនៃការផ្តល់ប្រឹក្សាដែលផ្តល់ដោយបុគ្គលិករួមការងាររបស់អ្នកមានការសំរបសំរួលទទួលខុសត្រូវ
- អ្នកត្រូវទទួលខុសត្រូវចំពោះបុគ្គលិករួមការងាររបស់អ្នក និងត្រូវព្យាយាមជួយគាត់ ឬជំរុញទឹកចិត្តគាត់ឱ្យស្វែងរកអ្នកជួយ
- អ្នកមានភារៈកិច្ចទទួលខុសត្រូវចំពោះសេវាផ្តល់ប្រឹក្សាដែលអ្នកកំពុងតែអនុវត្ត និងត្រូវរាយការណ៍ពីក្តីបារម្ភរបស់អ្នកទៅកាន់អ្នកអភិបាល ។

20

## ករណីសិក្សា ២

ក្រុមសីលធម៌ដែលអ្នកត្រូវគិតនៅក្នុងករណីសិក្សានេះមាន:

**កិច្ចព្រមព្រៀង**

- អតិថិជនមិនត្រូវបានបង្ខិតបង្ខំឱ្យទទួលការប្រឹក្សានិងធ្វើតេស្តឈាមទេ បើសិនជាគាត់ មិនទាន់ត្រៀមខ្លួននឹងធ្វើ និងមិនព្រមព្រៀង

**ការគោរព**

- អ្នកផ្តល់ប្រឹក្សាត្រូវគោរពការសំរេចចិត្តរបស់អតិថិជន ទោះបីជាគាត់មិនយល់ស្របក្តី
- អ្នកផ្តល់ប្រឹក្សាត្រូវផ្តោតអារម្មណ៍លើស្ថានភាពរបស់អតិថិជន និងទុកពេលឱ្យគាត់ព្យាយាមរកដំណោះស្រាយដោយខ្លួនឯង

21

## ករណីសិក្សាទី ៣

ក្រុមសីលធម៌ដែលអ្នកត្រូវគិត នៅក្នុងករណីសិក្សានេះមាន:

**ការលាក់ការណ៍សម្ងាត់**

- អ្នកផ្តល់ប្រឹក្សាមានភារកិច្ចរក្សាការសម្ងាត់ដល់អតិថិជន ការប្រាប់អាថិកំបាំងដល់អ្នកដទៃ
- ការប្រាប់អាថិកំបាំងឱ្យអ្នកដទៃដឹងទាក់ទងទៅនឹងអតិថិជន

**ជំលោះនៃផលប្រយោជន៍**

- វាអាចជាផលប្រយោជន៍របស់ប្រពន្ធដែលត្រូវដឹងពីស្ថានភាពផ្ទុកមេរោគរបស់ប្តី
- វាអាចមិនមានប្រយោជន៍ចំពោះប្តីដែលត្រូវប្រាប់ឱ្យគេដឹងពីស្ថានភាពខ្លួន

**ការទទួលខុសត្រូវ**

- អ្នកផ្តល់ប្រឹក្សាមានភារកិច្ចទទួលខុសត្រូវដល់អតិថិជនទាំងពីរ

**គោលការណ៍ "មិនត្រូវធ្វើឱ្យអ្នកដទៃមានការឈឺចាប់"**

- អ្នកផ្តល់ប្រឹក្សាមិនត្រូវធ្វើឱ្យបុគ្គលណាមួយឈឺចាប់ទេ ។ ការមិនប្រាប់លទ្ធផលឱ្យគេដឹងធ្វើឱ្យស្ត្រីប្រឈមនឹងការឆ្លងមេរោគអេដស៍

22

## ករណីសិក្សាទី ៤

ក្រុមសីលធម៌ដែលអ្នកត្រូវគិត នៅក្នុងករណីសិក្សានេះមាន:

- ភាពស្មោះត្រង់បុគ្គល
  - -តើអ្នកផ្តល់ប្រឹក្សាស្វែងរកលាភសក្ការៈសំរាប់ផ្ទាល់ខ្លួនដែរឬទេ?
  - -ការទុកចិត្តទូទៅលើអ្នកផ្តល់ប្រឹក្សាឬសេវាអាចត្រូវបានបំផ្លាញ
- រក្សាព្រំដែនការងារឱ្យបាន
  - -អ្នកផ្តល់ប្រឹក្សាអាចធ្វើអ្វីមួយហួសព្រំដែនដែលគាត់ត្រូវធ្វើដោយចូលរួមក្នុងសង្គមជាមួយអតិថិជន
- រក្សាការសម្ងាត់
  - -គឺជាគ្រោះប្រឈមមួយដែលការសម្ងាត់របស់អតិថិជនត្រូវបានធ្វើឱ្យបែកធ្លាយចេញមកក្រៅ

23

## ករណីសិក្សាទី ៥

ក្រុមសីលធម៌ដែលអ្នកត្រូវគិត នៅក្នុងករណីសិក្សានេះមាន៖

- គោរពសិទ្ធិមនុស្ស
  - អ្នកផ្តល់ប្រឹក្សាត្រូវគោរពអតិថិជន ដោយមិនគិតពីវប្បធម៌ សាសនា តម្លៃ ឬប្រព័ន្ធជំនឿ
  - អ្នកផ្តល់ប្រឹក្សាមានភារកិច្ចផ្តល់សេវាដល់មនុស្សគ្រប់រូបដែលមករកគាត់
- ធានាថា មិនធ្វើឱ្យអ្នកដទៃមានការឈឺចាប់ដោយបដិសេធផ្តល់ប្រឹក្សាដល់ស្ត្រីរកស៊ីផ្លូវភេទ អ្នកផ្តល់ប្រឹក្សាកំពុងតែធ្វើឱ្យអតិថិជនប្រឈមនឹងការ៖
  - មិនបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់គាត់
  - មិនដឹងពីរបៀបកាត់បន្ថយឥរិយាបថប្រឈមរបស់គាត់
  - មិនអាចការពារទារកក្នុងផ្ទៃបានដោយសារតែមិនបានទទួលសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

24

**ម៉ូឌុលទី១១៖ សកម្មភាពទី៧៖ លំហាត់រយៈពេលចំហនៃមេរោគអេដស៍**

| | ថ្ងៃខែឆ្នាំធ្វើតេស្តលើកទី១ | ថ្ងៃខែឆ្នាំធ្វើតេស្តលើកទី២ |
|---|---|---|
| ១ | ៧ មិថុនា ២០០៧ | ៧ កញ្ញា ២០០៧ |
| ២ | ២ វិច្ឆិកា ២០០៧ | ៤ កុម្ភៈ ២០០៨ |
| ៣ | ២៨ មីនា ២០០៧ | ២៨ មិថុនា ២០០៧ |
| ៤ | ១៤-០៩-២០០៧ | ១៤-១២-២០០៧ |
| ៥ | ១០-០៧-២០០៧ | ១៥-១០-២០០៧ |
| ៦ | ៣០-០៥-២០០៧ | ០១-០៩-២០០៧ |

# បញ្ជីរាយឯកសារយោង


1. National Maternal Child Health Centre Prevention of Mother-to-Child Transmission of HIV Training Curriculum
   MoH, National Maternal and Child Health Centre June 2002

2. WHO/CDC Prevention of Mother-to-Child Transmission of HIV Generic Training Package
   WHO 2004

3. Voluntary Confidential Counseling and Testing for HIV (VCCT), A Guide for Implementation
   MoH, NCHADS, January 2004

4. HIV Sentinel Survey Report
   MoH, NCHADS, 2004

5. Voluntary Confidential Counseling and Testing for HIV, VCCT Counseling Training Manual
   MoH, NCHADS October 2004

6. Continuum of Care for People Living with HIV/AIDS, Operational Framework
   MoH, NCHADS 1st edIrtion, April 2003

7. Cambodia National Guidelines for the use of PaedIratric ÀRV
   MoH, NCHADS 1st edIrtion, October 2004

8. Cambodia National Guidelines for the Prevention of Mother-to-Child Transmission of HIV
   MoH, National Maternal and Child Health Centre
   2nd edIrtion, September 2005

9. Cambodia National Training Programme: Clinicians Training on Management of Opportunistic Infection and Antiretroviral Therapy for Adults
   MoH, NCHADS 1st edIrtion, September 2004

10. Cambodia National Training Programme: Clinicians Training on Management of Opportunistic Infection and Antiretroviral Therapy for Children
    MoH, NCHADS 1st edIrtion, 2006

11. Cambodia National Training Programme: Opportunistic Infection and Antiretroviral Therapy Counseling for Nurses
    MoH, NCHADS 1st edIrtion, May 2005
12. Cambodia National Training Programme: Drugs and Logistic Management for Pharmacists of Referral Hospital Opportunistic Infection & Antiretroviral Services
    MoH, NCHADS 1st edIrtion, August 2005

13. Cambodia National Training Programme: Drugs and Logistic Management for Logistic Officers at Referral Hospital Opportunistic Infection & Antiretroviral Services
    MoH, NCHADS 1st edIrtion, February 2006

14. Infant and Young Child FeedIrng Counseling: An Integrated Course
    WHO, 2005

15. HIV Prevention in Maternal Health Services: Training Guide: Session 8, Voluntary Counseling and Testing for HIV
    UNFPA and EngenderHealth, 2004

16. Kenya PMCT Project, PMCT Training Curriculum: Module 4, Counseling Skills for the Prevention of Mother-to-child Transmission of HIV
    Population Council 2002

17. VCT Toolkit, Trainer's Manual: Counselling Supervision and Training
    Family Health International, August 2005
    Retrieved June 2006 from: www.fhi.org/en/HIVAIDS/pub/guide/VCTToolkitCounseling.htm

18. Voluntary HIV Counseling and Testing, Manual for Training of Trainers. Module 5, sub-module 5: Counsellor Ethics
    WHO Regional Office for SE Asia, 2004
    Retrieved June 2006 from:
    www.whosea.org /LinkFiles/Training_Materials_voluntary-intro.pdf

19. Projections for HIV/AIDS in Cambodia: 2000-2010
    The Cambodia Working Group on HIV/AIDS Projection
    November 2002

20. PMTCT Programme Management Training
    Thailand MOPH – US CDC collaboration
    March 2003

21. Transplacental transmission of HIV: a potential role for HIV binding lectins
    E.J. Soilleux, N. Coleman / The International Journal of Biochemistry & Cell Biology 35 (2003) 283–287
    Retrieved June 2006 from: www.chu.cam.ac.uk/~EJS17/transplac.pdf